មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

ខែតុលា ឆ្នាំ២០១៩

# សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា

# ការសង្កេតការណ៍នៅសាលាឧទ្ធរណ៍

## របាយការណ៍ប្រចាំឆ្នាំ (ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ ដល់ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨)



## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)

របាយការណ៍ស្តីពី "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា" ជាការបោះពុម្ពផ្សាយរបស់គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក")។ ម.ស.ម.ក គឺជាអង្គការមិនមែនរដ្ឋាភិបាល ("អង្គការ") ឯករាជ្យ មិនចូលបក្សសម្ពន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។ ចក្ខុវិស័យរបស់ ម.ស.ម.ក គឺកម្ពុជាគ្មានអំពើហិង្សាដែលប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន មានសិទ្ធិស្មើគ្នា និងត្រូវបានផ្តល់អំណាច ដើម្បីចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួលបានការចែករំលែកផលប្រយោជន៍ពីការអភិវឌ្ឍប្រទេសកម្ពុជា។ ម.ស.ម.ក មានគោលបំណងចង់បាននីតិរដ្ឋជាជាងនិទណ្ឌភាព ស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំង និងសង្គមសេរីពហុបក្សដែលភាពចម្រុះត្រូវបានគេស្វែងរក និងអបអរសាទរជាជាងការមិនអើពើ និងការដាក់ទោស។ ស្លាកសញ្ញារបស់ ម.ស.ម.ក មាន រូបសត្វស្លាបពណ៌ស កំពុងហើរបំបែកចេញពីរង្វង់មូលពណ៌ផ្ទៃមេឃ ដែលមានន័យថា គឺជាការទាមទារសេរីភាពនៅកម្ពុជា។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទស្សនាគេហទំព័រ www.cchrcambodia.org។

## ចម្ងល់ និងមតិចូលរួម

ប្រសិនបើលោកអ្នកមានសំណួរ ឬចង់បានព័ត៌មានបន្ថែមអំពីរបាយការណ៍នេះ សូមផ្ញើអ៊ីម៉ែលមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន info@cchrcambodia.org។

របាយការណ៍នេះ និងឯកសារបោះពុម្ពផ្សាយផ្សេងៗ អាចស្វែងរកបាននៅលើមូលដ្ឋានទិន្នន័យសង្កេតការណ៍ការជំនុំជម្រះរបស់ ម.ស.ម.ក តាមរយៈ www.tmp.sithi.org គេហទំព័រ www.cchrcambodia.org និងនៅលើ គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា តាមរយៈ www.sithi.org។

ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន៖

ផ្ទះលេខ ៧៩៨ ផ្លូវ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ទូរស័ព្ទ៖ +៨៥៥ (0) ២៣ ៧២ ៦៩ ០១

ទូរសារ៖ +៨៥៥ (0) ២៣ ៧២ ៦៩ ០២

# មាតិកា


មាតិកា ............ III

តារាងតួលេខ ............ V

បញ្ជីអក្សរកាត់ ............ VI

ខ្លឹមសារសង្ខេប ............ VIII

១. សេចក្តីផ្តើម ............ 1

១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ............ 1

១.១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌តាមច្បាប់អន្តរជាតិ ............ 1

១.១.២. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌តាមច្បាប់ជាតិ ............ 2

១.២. គោលបំណង វិសាលភាព និងវិធីសាស្ត្រ ............ 11

២. ទិដ្ឋភាពទូទៅ ............ 16

៣. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរព ............ 19

៣.១. សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី ............ 19

៣.២. សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ............ 22

៣.៣. សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ ............ 25

៣.៤. ការហាមឃាត់ប្រឆាំងនឹងការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ............ 27

៣.៥. ការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែល ............ 29

៤. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលមិនទាន់ត្រូវបានគោរពពេញលេញ ............ 31

៤.១. សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ............ 31

៤.២. សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ............ 33

៤.៣. សិទ្ធិមានមេធាវី និងមានវត្តមាននៅក្នុងសវនាការ ............ 37

៤.៤. សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ............ 43

៤.៥. សិទ្ធិបង្ហាញភស្តុតាង ............ 47

៤.៦. សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ ............ 50

៤.៧. សិទ្ធិរបស់អនីតិជន ............ 55

៥ .សេចក្តីសន្និដ្ឋាន ............ 64

៦. អនុសាសន៍ ....................................................................................................67
៦.១. អនុសាសន៍ទូទៅ ....................................................................................................67
៦.២. អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ....................................68
៦.៣. អនុសាសន៍ទាក់ទងនឹងសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ......68
៦.៤. អនុសាសន៍ទាក់ទងនឹងសិទ្ធិមានវត្តមាននៅពេលសវនាការ និងមានមេធាវី ...............68
៦.៥. អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ......................69
៦.៦. អនុសាសន៍ទាក់ទងនឹងសិទ្ធិបង្ហាញភស្តុតាង ..........................................................70
៦.៧. អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ...........................70
៦.៨. អនុសាសន៍ទាក់ទងនឹងការការពារសិទ្ធិរបស់អនីតិជន ..................................................71
៧. ឯកសារគន្លងនិទ្ទេស ..........................................................................................73
៧.១. នីតិជាតិ ..........................................................................................................73
៧.២. លិខិតូបករណ៍គោលនយោបាយកម្ពុជា ..........................................................................73
៧.៣. នីតិអន្តរជាតិ......................................................................................................74
៨. ឧបសម្ព័ន្ធ ......................................................................................................79
ឧបសម្ព័ន្ធទី១៖ តារាងសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍ ............................................79
ឧបសម្ព័ន្ធទី២៖ ក្រមសីលធម៌មន្ត្រីសង្កេតការណ៍សវនាការ......................................................98

# តារាងតួលេខ


តួលេខទី ១៖ ទិដ្ឋភាពទូទៅនៃសំណុំរឿងដែល មក បានសង្កេតការណ៍.ម.ស. ....... 11
តួលេខទី ២៖ សវនាការសាលាឧទ្ធរណ៍ដែលបានសង្កេតការណ៍៖ បទឧក្រិដ្ឋ បទមជ្ឈិម និង បទលហុ ....... 16
តួលេខទី ៣៖ ភាគីធ្វើបណ្តឹងឧទ្ធរណ៍ ....... 17
តួលេខទី ៤៖ សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី ....... 21
តួលេខទី ៥៖ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ....... 24
តួលេខទី ៦៖ សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ ....... 27
តួលេខទី ៧៖ ការហាមឃាត់ប្រឆាំងនឹងការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ....... 28
តួលេខទី ៨៖ ការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែល ....... 30
តួលេខទី ៩៖ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ....... 32
តួលេខទី ១០៖ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ - ទិដ្ឋភាពទូទៅ ....... 35
តួលេខទី ១១៖ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ - ទិដ្ឋភាពលម្អិត ....... 35
តួលេខទី ១២៖ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ការវិវឌ្ឍ - ....... 36
តួលេខទី ១៣៖ សិទ្ធិមានវត្តមាននៅក្នុងសវនាការ និងមានមេធាវី ....... 40
តួលេខទី ១៤៖ សិទ្ធិមានវត្តមាននៅក្នុងសវនាការ និងមានមេធាវី ចន្លោះចាប់ពីឆ្នាំ២០១៦-២០១៨ ....... 41
តួលេខទី ១៥៖ ការពន្យល់ប្រាប់សិទ្ធិ ....... 42
តួលេខទី ១៦៖ ការសន្មតទុកជាមុនថាគ្មានទោស ....... 46
តួលេខទី១៧៖ការវិវឌ្ឍនៃសំណុំរឿងដែលសេចក្តីសម្រេចមានសំអាងហេតុមិនលម្អិត និងច្បាស់លាស់នៅចន្លោះឆ្នាំ២០១៤ -២០១៨ ....... 53
តួលេខទី ១៨៖ ទិដ្ឋភាពទូទៅនៃសាលដីការបស់សាលាឧទ្ធរណ៍ ....... 54
តួលេខទី ១៩៖ អាយុជនជាប់ចោទនៅក្នុងពេលបើកសវនាការ ....... 60
តួលេខទី ២០៖ ចំនួនអនីតិជនត្រូវបានឃុំខ្លួននៅចន្លោះឆ្នាំ២០១៤ -២០១៨....... 60
តួលេខទី ២១៖ ការការពារឯកជនភាពរបស់អនីតិជន ....... 62
តួលេខទី ២២៖ ការវិវឌ្ឍនៃការការពារឯកជនភាពរបស់អនីតិជនចាប់តាំងពីឆ្នាំ២០១៤ ....... 63

# បញ្ជីអក្សរកាត់

| | |
|---|---|
| គណៈមេធាវី | គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| កម្ពុជា | ព្រះរាជាណាចក្រកម្ពុជា |
| ម.ស.ម.ក | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| ក្រមនីតិវិធីព្រហ្មទណ្ឌ | ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា |
| តារាងសង្កេតការណ៍ | តារាងសង្កេតការណ៍ប្រើដោយអ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ដើម្បីកត់ត្រាទិន្នន័យសវនាការនៅពេលសង្កេតការណ៍ |
| ការណែនាំអំពីតារាងសង្កេតការណ៍ | ឯកសារណែនាំលម្អិតដើម្បីជួយដល់អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ឱ្យមានការយល់ច្បាស់លាស់ចំពោះសំណួរនីមួយៗនៅក្នុងតារាងសង្កេតការណ៍ |
| ក្រមសីលធម៌ | ឯកសារកំណត់អំពីកាតព្វកិច្ចនានានៃការមិនជ្រៀតជ្រែក គោលបំណងមិនលម្អៀង និងការសម្ងាត់ដែលចងជាកាតព្វកិច្ចដល់អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក |
| រដ្ឋធម្មនុញ្ញ | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា |
| សាលាឧទ្ធរណ៍ | សាលាឧទ្ធរណ៍រាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា |
| អ.ស.ក | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| ប្រព័ន្ធគ្រប់គ្រងទិន្នន័យ | ប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដែលអ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក រក្សាទុកទិន្នន័យសវនាការ ដែលបានកត់ត្រានៅលើតារាងសង្កេតការណ៍ |
| ECHR | តុលាការសិទ្ធិមនុស្សអឺរ៉ុប |
| HRC | គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ |
| ក.អ.ស.ព.ន | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| មិនដឹង | ព័ត៌មានដែលមិនទទួលបាន ឬមិនបានតាមដានបន្ត |
| មិនពាក់ព័ន្ធ | ទិន្នន័យមិនពាក់ព័ន្ធ |
| ក.ស.ម.វ.ប | ការិយាល័យទទួលបន្ទុកសិទ្ធិមនុស្ស និងវិទ្យាស្ថានប្រជាធិបតេយ្យ |
| ការិយាល័យឧត្តមស្នងការ | ការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ |
| អ.ស.ស.អ | អង្គការសម្រាប់សន្តិសុខ និងសហប្រតិបត្តិការនៅអឺរ៉ុប |
| ក្រមព្រហ្មទណ្ឌ | ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា |
| គម្រោង | គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក |

| | |
|---|---|
| អំឡុងពេលធ្វើរបាយការណ៍ | ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ២០១៧ ដល់ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១៨ |
| រដ្ឋាភិបាល | រាជរដ្ឋាភិបាលកម្ពុជា |
| អ្នកសង្កេតការណ៍ | អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក |
| ស.ស.ស.ម | សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស |
| អ.ស.ប | អង្គការសហប្រជាជាតិ |
| យូនីសេហ្វ | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ |
| UNSRSHRC | អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា |
| អ៊ុនតាក់ | អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា |
| ច្បាប់អ៊ុនតាក់ | បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលឆ្នាំ ១៩៩២ |

# ខ្លឹមសារសង្ខេប

ប្រព័ន្ធយុត្តិធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយជាពិសេស ផ្នែករដ្ឋបាលគ្រប់គ្រងយុត្តិធម៌ បានក្លាយជាប្រធានបទដែលមានការពិភាក្សាគ្នាជាច្រើននៅក្នុង២០១៨។ មានការរិះគន់ទៅលើប្រព័ន្ធនេះ រួមមានដូចជា កង្វះឯករាជ្យភាពរបស់ប្រព័ន្ធយុត្តិធម៌ ការប្រើប្រាស់ប្រព័ន្ធយុត្តិធម៌មិនត្រឹមត្រូវក្នុងគោលបំណងនយោបាយ រាប់បញ្ចូលទាំងកាលកំណត់គោលដៅលើអ្នកការពារសិទ្ធិមនុស្ស ពន្ធនាគារមានទណ្ឌិតលើសចំនួនកំណត់ កង្វះ ឬលទ្ធភាពមិនគ្រប់គ្រាន់ក្នុងការស្វែងរកមេធាវី និទណ្ឌភាព កង្វះការប្រព្រឹត្តស្មើភាពចំពោះមុខច្បាប់ ការឃុំខ្លួនបណ្តោះអាសន្នលើសការកំណត់ កង្វះការយល់ដឹងអំពីយេនឌ័រ និងបញ្ហាប្រឈមពាក់ព័ន្ធនឹងការទទួលបានយុត្តិធម៌។ ជាលទ្ធផល ទំនុកចិត្តទៅលើប្រព័ន្ធយុត្តិធម៌នៅមានកម្រិត ហើយនីតិរដ្ឋក៏នៅមានភាពទន់ខ្សោយ។

រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") ទំនងជាបានស្តាប់ឮខ្លះៗអំពីការរិះគន់ទាំងនេះ ហើយនៅក្នុងឆ្នាំ២០១៨ រដ្ឋាភិបាលបានធ្វើការកែលម្អបញ្ហាមួយចំនួនពាក់ព័ន្ធនឹងប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសកម្ពុជានេះផងដែរ។ កិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើងក្នុងចំណោមកិច្ចការជាច្រើនផ្សេងទៀត រួមមាន ការអនុម័តគោលនយោបាយជំនួយផ្នែកច្បាប់ ការប្រកាសអំពីគម្រោងបង្កើតតុលាការឧទ្ធរណ៍នៅតាមខេត្ត និងចំណាត់ការដើម្បីដោះស្រាយបញ្ហាពន្ធនាគារមានជនជាប់ឃុំច្រើនលើសចំនួនកំណត់។ ជាពិសេសផងដែរ គឺការចេញសាលដីកាបណ្តឹងសារទុក្ខនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រឆាំងនឹង នួន ជា និង ខៀវ សំផន បានតំណាងឱ្យចំណុចគន្លឹះនៅក្នុងការលើកកម្ពស់គណនេយ្យភាព និងតម្លាភាព។

នៅចន្លោះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ និងថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ("អំឡុងពេលធ្វើរបាយការណ៍") គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក ("គម្រោង") បានធ្វើការសង្កេតការណ៍ និងប្រមូលទិន្នន័យសវនាការព្រហ្មទណ្ឌចំនួន ២១៣ ករណីនៅសាលាឧទ្ធរណ៍ ដើម្បីវាយតម្លៃអំពីការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់សាលាឧទ្ធរណ៍ ដូចដែលបានចែងនៅក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ របាយការណ៍នេះបង្ហាញ និងវិភាគទៅលើទិន្នន័យដែលប្រមូលបានក្នុងអំឡុងពេលធ្វើរបាយការណ៍ ហើយក៏មានគោលបំណងរួមចំណែកលើកកម្ពស់តម្លាភាព គណនេយ្យភាព និងការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងប្រទេសកម្ពុជាផងដែរ។

របាយការណ៍នេះមានរចនាសម្ព័ន្ធដូចខាងក្រោម៖

**សេចក្តីផ្តើម៖** ផ្តល់ទិដ្ឋភាពសង្ខេបអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលពាក់ព័ន្ធ មុននឹងឈានដល់ការកំណត់វិសាលភាព វិធីសាស្ត្រ និងគោលបំណងនៃរបាយការណ៍នេះ។

**ទិដ្ឋភាពទូទៅ៖** រៀបរាប់នូវទិន្នន័យដែលបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍នេះ ដូចជា ចំនួនសំណុំរឿងដែលបានសង្កេតការណ៍ និងចំនួនជនជាប់ចោទដែលជាប់ពាក់ព័ន្ធ។

**សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរព៖** កំណត់ថាតើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ណាខ្លះត្រូវបានគោរពនៅសាលាឧទ្ធរណ៍ តាមរយៈការវិភាគទិន្នន័យដែលបានប្រមូលនៅ

ក្នុងអំឡុងពេលធ្វើការសង្កេតការណ៍របស់ ម.ស.ម.ក ហើយទន្ទឹមនឹងនោះក៏គូសបញ្ជាក់អំពីនិន្នាការសំខាន់ៗ ទាក់ទងជាមួយការគោរពបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់សាលាឧទ្ធរណ៍ ផងដែរបើប្រៀបធៀបទៅនឹងទិន្នន័យប្រមូលបានចាប់តាំងពីខែកក្កដា ឆ្នាំ២០១៤ មក។ សិទ្ធិនីមួយៗ ត្រូវបាន លើកយកមកពិភាក្សានៅក្នុងអនុផ្នែកដាច់ដោយឡែកពីគ្នា ដែលបានកំណត់បញ្ញត្តិនៃច្បាប់ក្នុងប្រទេស និងអន្តរ ជាតិពាក់ព័ន្ធ ក៏ដូចជាពន្យល់អំពីអត្ថន័យនៃសិទ្ធិជាក់លាក់ផងដែរ។

**សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលមិនទាន់ត្រូវបានគោរពពេញលេញ៖** គូសបញ្ជាក់អំពី សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលមិនត្រូវបានគោរពពេញលេញនៅសាលាឧទ្ធរណ៍ ដោយបង្ហាញ អំពីទិន្នន័យសំខាន់ៗដែលបានប្រមូលនៅក្នុងអំឡុងពេលសង្កេតការណ៍របស់ ម.ស.ម.ក។ ការវិវឌ្ឍនៃកិច្ចប្រឹង ប្រែងជំរុញឱ្យប្រសើរឡើងនូវការគោរពនូវសិទ្ធិទាំងនេះចាប់តាំងពីខែកក្កដា ឆ្នាំ២០១៤ កន្លងមក ក៏ត្រូវបាន លើកមកពិភាក្សាផងដែរ។ សិទ្ធិនីមួយៗ ត្រូវបានលើកយកមកពិភាក្សាគ្នានៅក្នុងអនុផ្នែកដាច់ដោយឡែកពីគ្នា ដែលបានកំណត់បញ្ញត្តិនៃច្បាប់ក្នុងប្រទេស និងអន្តរជាតិពាក់ព័ន្ធ ក៏ដូចជាពន្យល់អំពីអត្ថន័យនៃសិទ្ធិជាក់លាក់ ផងដែរ។

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍៖** រួមមានអនុសាសន៍ជាក់ជូនចំពោះអង្គភាព និងស្ថាប័នពាក់ព័ន្ធផ្សេងៗ ក្នុងវិស័យយុត្តិធម៌ រួមទាំងរាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") ក្រសួងយុត្តិធម៌ ("ក្រ.យ") អាជ្ញាធរអនុវត្ត ច្បាប់ អាជ្ញាធរពន្ធនាគារ ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាល ដែលជាប់ពាក់ព័ន្ធនឹងលទ្ធផលដែលបានរកឃើញ នៅក្នុងរបាយការណ៍នេះ។

របាយការណ៍នេះ បានបង្ហាញថាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗមួយចំនួនត្រូវ បានធានានៅមុខសាលាឧទ្ធរណ៍ រួមមាន សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី និងសិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ។ លើសពីនេះទៅទៀត សាលាឧទ្ធរណ៍បានប្រកាន់ ភ្ជាប់នូវការការពារប្រឆាំងនឹងការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែល និងការហាមឃាត់ការអនុវត្តអានុភាព ប្រតិសកម្មនៃច្បាប់។ គួររំឭកផងដែរថា ឆ្នាំ២០១៧/២០១៨ បានបង្ហាញនូវចំណុចប្រសើរឡើងគួរឱ្យកត់ សម្គាល់ក្នុងការពង្រឹងការការពារខ្លួនប្រឆាំងការឆ្លើយដាក់បន្ទុកបទល្មើសលើខ្លួនឯង(សិទ្ធិមិនត្រូវបានបង្ខិតបង្ខំ ឱ្យសារភាពពីពិរុទ្ធភាព) ក្នុងសំណុំរឿងដែល ម.ស.ម.ក បានសង្កេតការណ៍។

| **សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរពនៅសាលាឧទ្ធរណ៍** |
| --- |
| • សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី |
| • សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព |
| • សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ |
| • ការហាមឃាត់ប្រឆាំងនឹងការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ |
| • ការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែល |

ប៉ុន្តែយ៉ាងណាក៏ដោយ ការសង្កេតការណ៍ក៏បានរកឃើញកង្វះការអនុលោមតាមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាមូលដ្ឋានមួយចំនួនផងដែរ។ សិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះជាសាធារណៈ មានការគោរពមិនទាន់បានពេញលេញនៅឡើយដោយសារតែពុំមានសវនាការណាមួយក្នុងចំណោមសវនាការដែល ម.ស.ម.ក បានសង្កេតការណ៍ មានបិទសេចក្តីប្រកាសនៅលើក្តារខៀននៅខាងក្រៅបន្ទប់សវនាការឡើយ ដែលធ្វើឱ្យសាធារណជនទូទៅមិនអាចទទួលបានដំណឹងអំពីសវនាការនោះ។ លើសពីនេះទៅទៀត សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ត្រូវបានចាត់ទុកថាក៏ពុំទាន់ត្រូវបានពេញលេញនោះទេ ពោលគឺមិនដូចគ្នានឹងអ្វីដែលមាននៅក្នុងឆ្នាំ២០១៦/២០១៧ ឡើយ ដោយសារតែភាគរយនៃសំណុំរឿងដែលជនជាប់ចោទត្រូវបានជូនដំណឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ បានធ្លាក់ចុះពី ៨៦% ដល់ ៦៩% បើធៀបទៅនឹងចំនួនសំណុំរឿងដែលបានសង្កេតការណ៍កាលពីឆ្នាំកន្លងទៅ។ សិទ្ធិមានមេធាវីសម្រាប់ជនជាប់ចោទជានីតិជននៃបទមជ្ឈិមមិនត្រូវបានគោរពពេញលេញនោះទេ បើធៀបនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ តែផ្អែកតាមច្បាប់ជាតិ ចៅក្រមអាចដំណើរការសវនាការបានដោយមិនមានមេធាវីតំណាងបាន ក្នុងករណីដែលជនជាប់ចោទមិនត្រូវការមេធាវីតំណាង។ ប្រហែលចំនួន ២៥% នៃជនជាប់ចោទក្នុងសំណុំរឿងនៃបទមជ្ឈិមដែល ម.ស.ម.ក បានសង្កេតការណ៍ពុំមានមេធាវីតំណាងឡើយ ដែលការអនុវត្តបែបនេះវាផ្ទុយនឹងបទដ្ឋាននៃច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលមិនបានកំណត់ថាការទទួលបានមេធាវីតំណាងដោយកម្រិតទៅលើប្រភេទនៃបទល្មើសនោះឡើយ។ ជនជាប់ចោទមានសិទ្ធិមានមេធាវីសម្រាប់គ្រប់ប្រភេទនៃបទល្មើសទាំងអស់។

ជាងនេះទៅទៀត សំណុំរឿងចំនួន ៣៤ នៅក្នុងចំណោមសំណុំរឿង ២១៣ ករណី ដែល ម.ស.ម.ក បានសង្កេតការណ៍ ចៅក្រមពុំបានប្រាប់ជនជាប់ចោទថាពួកគាត់មានសិទ្ធិមានមេធាវីឡើយ ដែលនេះគឺជានិន្នាការគួរឱ្យព្រួយបារម្ភមួយ។ ស្រដៀងគ្នានេះដែរ ការសន្មតទុកជាមុនថាគ្មានទោស នៅតែមិនទាន់បានគោរពពេញលេញនៅឡើយ ដោយសារសំណុំរឿងប្រមាណជា ២៦% នៃជនជាប់ចោទបានបង្ហាញខ្លួនដោយស្លៀកពាក់ឯកសណ្ឋានដូចគ្នាទៅនឹងទណ្ឌិតដែរ។ ភាគច្រើនដូចនឹងឆ្នាំមុនៗដែរ កង្វះការគោរពសិទ្ធិទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុពេញលេញ និងច្បាស់លាស់នៅតែជាបញ្ហាចោទដដែល។ នៅស្ទើរតែគ្រប់សំណុំរឿងទាំងអស់ដែលបានសង្កេតការណ៍ ដែលបានចេញសាលដីកា ចៅក្រមពុំបានបញ្ជាក់លម្អិតពីមាត្រាច្បាប់ និងភស្តុតាងដែលត្រូវប្រើប្រាស់ជាមូលដ្ឋានដើម្បីឈានដល់ការសម្រេចចេញសាលដីការបស់ខ្លួនឡើយ។ ជំនួសមកវិញ ចៅក្រមគ្រាន់តែបញ្ជាក់ថា សេចក្តីសម្រេចរបស់សាលាដំបូង ត្រូវបានតម្កល់ទុកដដែល ឬត្រូវបានបដិសេធចោលដោយពុំមានពន្យល់ប្រាប់មូលហេតុឱ្យបានលម្អិត និងច្បាស់លាស់នោះឡើយ។ ចុងក្រោយ សិទ្ធិរបស់ជនជាប់ចោទជាអនីតិជនដែលត្រូវបានការពារជាពិសេសនៅក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់កម្ពុជា ជា រឿយៗក៏ត្រូវបានព្រងើយកន្តើយផងដែរ ដោយមិនមានប្រើវិធានការពិសេសណាមួយត្រូវបានដាក់ឱ្យអនុវត្តដើម្បីការពារសិទ្ធិរបស់អនីតិជនឡើយ ជាពិសេស ឯកជនភាពរបស់ពួកគេតែម្តង។

| សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលមិនត្រូវបានគោរពពេញលេញនៅសាលាឧទ្ធរណ៍ |
|---|
| • សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ |
| • សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ |
| • សិទ្ធិមានមេធាវី និងមានវត្តមាននៅក្នុងសវនាការ |
| • សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស |
| • សិទ្ធិបង្ហាញភស្តុតាង |
| • សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ |
| • សិទ្ធិរបស់អនីតិជន |

របាយការណ៍នេះ ក៏ប្រៀបធៀបទិន្នន័យឆ្នាំនេះជាមួយនឹងទិន្នន័យឆ្នាំ២០១៤/២០១៥ និងឆ្នាំ២០១៦/២០១៧ ផងដែរ ដើម្បីកំណត់និន្នាការ និងវិភាគការវិវឌ្ឍនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជា[1]។ ថ្វីបើរបកគំហើញភាគច្រើនមានភាពប្រហាក់ប្រហែលគ្នាក៏ដោយ ក៏មានរបកគំហើញពីរចំណុចដែលខុសគ្នា៖ ទីមួយ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ដែល ម.ស.ម.ក បានរកឃើញថាត្រូវបានគោរពបានប្រសើរនៅក្នុងឆ្នាំ២០១៤/២០១៥(៨៥%) និងនៅឆ្នាំ២០១៦/២០១៧ (៨៦%) ត្រូវបានប្តូរទៅផ្នែក "មិនបានគោរពពេញលេញ"ដោយសារតែចំនួនភាគរយនៃសំណុំរឿងដែលជនជាប់ចោទត្រូវបានប្រាប់អំពីការចោទប្រកាន់ទាំងអស់ ដែលពាក់ព័ន្ធប្រឆាំងនឹងពួកគេបានធ្លាក់ចុះមកត្រឹមតែ ៦៩% នៅឆ្នាំ២០១៧/២០១៨។ ថ្វីបើបញ្ហានេះអាចបណ្តាលមកពីកត្តាជាច្រើនដូចជា ចំនួន និងប្រភេទសំណុំរឿងដែល ម.ស.ម.ក បានសង្កេតការណ៍ក៏ដោយ ប៉ុន្តែបញ្ហានេះនៅតែជាការរកឃើញគួរឱ្យព្រួយបារម្ភ ដោយហេតុថាសិទ្ធិដឹងអំពីការចោទប្រកាន់ គឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាមូលដ្ឋានសំខាន់ៗផ្សេងទៀត។ ម្យ៉ាងទៀត សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព (ការការពារខ្លួនប្រឆាំងការឆ្លើយដាក់បន្ទុកលើខ្លួនឯង) ដែលត្រូវបានកំណត់ថា "មិនបានគោរពពេញលេញ"នៅក្នុងឆ្នាំ២០១៤/២០១៥ និងឆ្នាំ២០១៦/២០១៧ បានប្រែល្អប្រសើរជាង ក្នុងឆ្នាំ២០១៧/២០១៨ ដោយក្នុងនោះសំណុំរឿងដែលការសារភាពពីពិរុទ្ធភាពដោយពុំមានការបង្ខិតបង្ខំមានការកើនឡើងដល់ ៩៥% (ឡើងខ្ពស់ជាង ៨៨% នៅក្នុងឆ្នាំ២០១៦/២០១៧)។ ទោះជាយ៉ាងណាក៏ដោយ គួរកត់សម្គាល់ថា មានជនជាប់ចោទចំនួន ២១ នាក់ ដែលការសារភាពទោសរបស់ពួកគេត្រូវបានទទួលតាមរយៈស្ថានភាពបង្ខិតបង្ខំ រួមទាំងការគំរាមកំហែង និងអំពើហិង្សាដោយនគរបាលយុត្តិធម៌ ដែលចំណុចនេះជាបញ្ហាគួរឱ្យព្រួយបារម្ភខ្លាំង។ សំណុំរឿងទាំងនេះ ត្រូវតែមានការស៊ើបអង្កេតជាបន្ទាន់ និងឱ្យបានហ្មត់ចត់ដោយអាជ្ញាធរមានសមត្ថកិច្ច។

[1] គម្រោងសង្កេតការណ៍សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានពន្យារពេលបណ្តោះអាសន្ននៅចន្លោះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ ដោយសារតែកង្វះមូលនិធិ។ ជាលទ្ធផល ពុំមានទិន្នន័យសម្រាប់រយៈពេលនេះឡើយ។

ជាងនេះទៅទៀត សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗមួយចំនួន ត្រូវបានសាលាឧទ្ធរណ៍គោរពយ៉ាងជាប់លាប់ចាប់តាំងពីឆ្នាំ២០១៤ មក ដែលក្នុងនោះរួមមាន សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការការពារក្តី សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ ការហាមឃាត់ការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ និងការហាមឃាត់ការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែល។ ប៉ុន្តែគួរឱ្យសោកស្តាយ សិទ្ធិផ្សេងទៀតក្នុងចំនួនដូចគ្នានេះដែរ ក៏មិនត្រូវបានគោរពពេញលេញចាប់តាំងពីឆ្នាំ២០១៤ មកដែរ រួមមានដូចជា សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ សិទ្ធិបង្ហាញភស្តុតាង សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ និងសិទ្ធិរបស់អនីតិជន។ បញ្ហានេះ បានបង្កឱ្យមានក្តីបារម្ភយ៉ាងធ្ងន់ធ្ងរ ជាពិសេស គឺត្រង់ចំណុចដែលថាបញ្ហាទាំងនោះបានដឹងឮដោយអាជ្ញាធររួចទៅហើយនៅក្នុងករណីជាច្រើន។

របាយការណ៍នេះ បញ្ចប់ដោយផ្តល់នូវអនុសាសន៍គន្លឹះមួយចំនួនសម្រាប់សាលាឧទ្ធរណ៍ដោះស្រាយបញ្ហាខកខានក្នុងការគោរពតាមនិយាមការជំនុំជម្រះដោយយុត្តិធម៌ដែលបានកំណត់នៅក្នុងរបាយការណ៍នេះ និងលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅទូទាំងប្រទេសកម្ពុជា។ អនុសាសន៍សំខាន់ៗរួមមានដូចខាងក្រោម៖

- អនុវត្តតាមការប្រតិបត្តិល្អរបស់ អ.វ.ត.ក និងផ្តល់វគ្គបណ្តុះបណ្តាលដល់ចៅក្រមស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌
- បង្កើតទម្រង់ជាបញ្ជីព័ត៌មានទាំងអស់ដែលចៅក្រមត្រូវផ្តល់ជូនជនជាប់ចោទ
- បិទផ្សាយកាលវិភាគសវនាការប្រចាំថ្ងៃទាំងអស់នៅលើក្តារខៀនព័ត៌មានខាងក្រៅបន្ទប់សវនាការ
- អនុញ្ញាតឱ្យជនជាប់ចោទបង្ហាញខ្លួននៅមុខតុលាការដោយស្លៀកសម្លៀកបំពាក់ស៊ីវិល
- ស៊ើបអង្កេតការចោទប្រកាន់ដែលការសារភាពមិនទទួលបានដោយស្ម័គ្រចិត្ត
- រៀបចំបង្កើតគោលការណ៍ណែនាំឱ្យបានច្បាស់លាស់ពាក់ព័ន្ធនឹងការបង្ហាញ និងការវាយតម្លៃភស្តុតាង
- ធានាថាការចេញសេចក្តីសម្រេចបានដាក់បញ្ចូលនូវច្បាប់ជាធរមានពាក់ព័ន្ធ និងភស្តុតាងសំខាន់ៗដែលប្រើប្រាស់ជាមូលដ្ឋាន និង
- ពង្រឹង និងពន្លឿនការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ជាពិសេស ពាក់ព័ន្ធនឹងឯកជនភាព និងជម្រើសជំនួសក្រៅពីការឃុំខ្លួន។

ម.ស.ម.ក សង្ឃឹមថាទិន្នន័យ ការវិភាគ និង អនុសាសន៍ដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ នឹងជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធយុត្តិធម៌ និងការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជួយគាំទ្រការងារទាំងនោះ ដើម្បីធានាថាប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា គឺយុត្តិធម៌ និងស្មើភាពសម្រាប់អ្នកទាំងអស់គ្នា។

# ១. សេចក្ដីផ្ដើម

## ១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាធាតុផ្សំដ៏សំខាន់នៃនីតិរដ្ឋ និងការគ្រប់គ្រងរដ្ឋបាលយុត្តិធម៌ដ៏ត្រឹមត្រូវ។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាសិទ្ធិជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកលនៅក្នុងច្បាប់អន្តរជាតិ ដូចមានចែងក្នុងសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ("ស.ស.ស.ម") និងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន")។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក៏ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ព្រមទាំងតាមរយៈបទប្បញ្ញត្តិជាក់លាក់មួយចំនួននៃច្បាប់ជាតិផងដែរ ជាពិសេស ក្រមនីតិវិធីព្រហ្មទណ្ឌ។

### ១.១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌តាមច្បាប់អន្តរជាតិ

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ជាផ្នែកសំខាន់នៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ហើយសិទ្ធិនេះផ្ដល់ឱ្យបុគ្គលគ្រប់រូបដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយ ទទួលបាននូវការគោរពដោយយុត្តិធម៌ និងស្មើភាពគ្នា នៅខណៈដែលរដ្ឋកំណត់អំពីពិរុទ្ធភាព ឬភាពគ្មានទោសរបស់អ្នកទាំងនោះ។ ការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ឱ្យបានត្រឹមត្រូវ នឹងការពារដល់សិទ្ធិរបស់ជនជាប់ចោទ និងជនរងគ្រោះ ព្រមទាំងធានាការផ្ដល់នូវយុត្តិធម៌ដ៏ត្រឹមត្រូវផងដែរ។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ រួមផ្សំដោយសិទ្ធិជាក់លាក់ផ្សេងៗមួយចំនួន ហើយក្ដោបនៅក្នុងនីតិវិធីច្បាប់ទាំងមូល ដោយគិតចាប់ពីដំណាក់កាលដំបូងនៃការឃាត់ខ្លួនជនសង្ស័យរហូតដល់ការប្ដឹងតវ៉ាត្រូវបានបញ្ចប់។

**មាត្រា ១០ នៃ ស.ស.ស.ម**
មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នា និងពេញលេញក្នុងការសុំឱ្យតុលាការឯករាជ្យ និងមិនលម្អៀង ត្រួតពិនិត្យរឿងក្ដីរបស់ខ្លួនជាសាធារណៈ និងដោយ [illegible] សិទ្ធិកាតព្វកិច្ច និងភាពសមហេតុផលចំពោះការចោទប្រកាន់ទោសព្រហ្មទណ្ឌនានា។

ទាំង ស.ស.ស.ម[2] និង ក.អ.ស.ព.ន[3] សុទ្ធតែធានាសិទ្ធិទទួលបានសវនាការយុត្តិធម៌ និងជាសាធារណៈ ដោយសាលាជម្រះក្ដីឯករាជ្យ និងឥតលម្អៀង។ ក.អ.ស.ព.ន បន្តបង្កើតនូវគោលការណ៍នៃសវនាការយុត្តិធម៌ដែលរួមមានជាអាទិ៍ សិទ្ធិ និងគោលការណ៍ ដូចរៀបរាប់តទៅនេះ៖ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ[4] សិទ្ធិទទួលបានការសន្មតជាមុនថា

[2] មាត្រា ១០ នៃសេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្សរបស់អង្គមហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៤៨ http://cambodia.ohchr.org/sites/default/files/Softlaw/BOOKLET_Kh%20V6Low.pdf។

[3] មាត្រា ១៤ (១)នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") របស់អង្គមហាសន្និបាតអង្គការសហប្រជាជាតិ ចុះនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ http://cambodia.ohchr.org/sites/default/files/Treaty/ICCPR_2009K.pdf។

[4] មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

គ្មានទោស[5] សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលមិនសមហេតុផល[6] សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់[7] សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី[8] សិទ្ធិមានមេធាវី[9] ការការពារខ្លួនប្រឆាំងការឆ្លើយដាក់បន្ទុកលើខ្លួនឯង (មិនសារភាពទោសកំហុសដោយសារតែការបង្ខិតបង្ខំ ឬការលួងលោម)[10] និងសិទ្ធិប្តឹងតវ៉ាទៅតុលាការជាន់ខ្ពស់លើផ្នែកអង្គហេតុ និងអង្គច្បាប់[11]។

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើ ក.អ.ស.ព.ន នៅឆ្នាំ១៩៩២ ហើយមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញបានដាក់បញ្ចូលកាតព្វកិច្ចគោរពសិទ្ធិមនុស្សអន្តរជាតិទៅក្នុងច្បាប់ជាតិ។[12] បន្ថែមលើនេះទៀត បទដ្ឋានគតិយុត្តិស្តីពីសិទ្ធិមនុស្សអន្តរជាតិនានា រួមទាំងបទប្បញ្ញត្តិនៃ ក.អ.ស.ព.ន មានអានុភាពអនុវត្តដោយផ្ទាល់នៅក្នុងតុលាការកម្ពុជា ដូចដែលបានបញ្ជាក់បន្ថែមតាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញកាលពីឆ្នាំ ២០០៧។[13]

### ១.១.២. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌តាមច្បាប់ជាតិ

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានការពារនៅកម្ពុជា តាមរយៈបទប្បញ្ញត្តិជាក់លាក់ និងទូទៅមួយចំនួន ដែលមានចែងនៅក្នុងលិខិតូបករណ៍មួយចំនួន។ រដ្ឋធម្មនុញ្ញបញ្ញត្តិអំពីក្របខ័ណ្ឌជាមូលដ្ឋានចំពោះការជំនុំជម្រះដោយយុត្តិធម៌។ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកំណត់អំពីសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរ និងការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដោយធានាថា៖

- មិនត្រូវឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។
- ការចោទប្រកាន់ ការចាប់ខ្លួន ឬការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តតាមបញ្ញត្តិច្បាប់។
- ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តកម្មខុសណាមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្មទៅចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារត្រូវហាមឃាត់។ ជនដៃដល់ ជនរួមប្រព្រឹត្ត និងអ្នកសមគំនិតត្រូវទទួលទោសតាមច្បាប់។

---

[5] មាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[6] មាត្រា ១៤(៣)(គ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[7] មាត្រា ១៤(៣)(ក) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[8] មាត្រា ១៤(៣)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[9] មាត្រា ១៤(៣)(ឃ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[10] មាត្រា ១៤(៣)(ឆ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[11] មាត្រា ១៤(៥) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[12] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ៖ "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ" http://www.national-assembly.org.kh/group-article/11។ កំណែថ្មីនៃរដ្ឋធម្មនុញ្ញដែលបានធ្វើបច្ចុប្បន្នភាពពេលធ្វើវិសោធកម្មចុងក្រោយ នៅខែកុម្ភៈ ឆ្នាំ២០១៨ មិនទាន់អាចរកបាននៅលើអ៊ីនធឺណែតឡើយ។

[13] សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ របស់ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០០៧ ទំព័រ២។ http://www.ccc.gov.kh/detail_info_kh.php?_txtID=214។

- ការសារភាព ដោយបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តីមិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។
- វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។
- ជនជាប់ចោទណាក៏ដោយ ត្រូវចាត់ទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។
- ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។

លើសពីនេះ មាត្រា ៥១ មាត្រា ១២៨ មាត្រា ១៣០ មាត្រា ១៣២ នៃរដ្ឋធម្មនុញ្ញ ក៏បានបញ្ញត្តិអំពីការបែងចែកអំណាច និងឯករាជ្យភាពរបស់តុលាការដែលជានាដោយព្រះមហាក្សត្រផងដែរ។

ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមនីតិវិធីព្រហ្មទណ្ឌ") ត្រូវបានអនុម័តក្នុងឆ្នាំ ២០០៧[14] ចែងយ៉ាងលម្អិតអំពីនីតិវិធីដែលត្រូវអនុវត្តលើជនសង្ស័យ។ ក្រមនេះបានកំណត់អំពីតួនាទី និងការទទួលខុសត្រូវរបស់ចៅក្រម ព្រះរាជអាជ្ញា និងភាគីវេងការចោទប្រកាន់ ដោយគិតចាប់ពីការផ្តួចផ្តើមនៃការស៊ើបអង្កេតបឋម រហូតដល់ពេលចាប់ខ្លួននៅក្នុងនីតិវិធីព្រហ្មទណ្ឌទាំងមូលរហូតដល់ការបញ្ចប់បណ្តឹងតវ៉ាជាស្ថាពរ។ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមព្រហ្មទណ្ឌ") ដែលត្រូវបានប្រកាសឱ្យប្រើក្នុងឆ្នាំ ២០០៩ និងបានចូលជាធរមានកាលពីខែធ្នូ ឆ្នាំ២០១០ ចែងអំពីចំណាត់ថ្នាក់នៃបទល្មើស គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងគោលការណ៍នៃការផ្តន្ទាទោស។[15]

បន្ថែមលើនេះទៀត ច្បាប់ជាមូលដ្ឋានទាំងបីពាក់ព័ន្ធជាមួយប្រព័ន្ធយុត្តិធម៌ រួមមាន ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ[16] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា[17] និងច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[18] ដែលបានអនុម័តក្នុងឆ្នាំ២០១៤ មានគោលបំណងជានាឯករាជ្យភាពរបស់អំណាចតុលាការ និងដើម្បីការពារសិទ្ធិ និងសេរីភាពរបស់ពលរដ្ឋកម្ពុជា។ គួរឱ្យសោកស្តាយ ច្បាប់ទាំងនេះត្រូវបានព្រាងដោយពុំបានពិគ្រោះយោបល់ និងផ្សព្វផ្សាយជាមុនជាមួយនឹងសង្គមស៊ីវិល សាធារណជន ឬភាគីពាក់ព័ន្ធផ្សេងទៀតឡើយ ដែលធ្វើឱ្យវេងការរិះគន់លើភាពកម្សោយនៃការបែងចែកអំណាច និងឯករាជ្យភាពរបស់ប្រព័ន្ធយុត្តិធម៌។ ច្បាប់ទាំងនេះបានផ្តល់នូវការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព និងដោយផ្ទាល់ដល់ផ្នែកនីតិប្រតិបត្តិទៅលើប្រព័ន្ធតុលាការ ដោយការបង្កើនកម្រិតឥទ្ធិពលរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ទៅលើចៅក្រម និង

[14] ក្រមនីតិវិធីព្រហ្មទណ្ឌជំនួសឱ្យផ្នែកមួយចំនួននៃបទប្បញ្ញត្តិទាក់ទិននឹងតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ឆ្នាំ ១៩៩២ ("ច្បាប់អ៊ុនតាក់")។ អាចស្វែងរកបាននៅលើគេហទំព័រ៖ http://sithi.org/temp.php?url=law_detail.php&id=190។

[15] ក្រមព្រហ្មទណ្ឌអាចស្វែងរកបាននៅលើគេហទំព័រ៖ http://sithi.org/temp.php?url=law_detail.php&id=154។

[16] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការអាចស្វែងរកបានតាមរយៈ៖ http://sithi.org/temp.php?title=Law-on-Organization-of-the-Courts&url=law_detail.php&lg=&id=262។

[17] ច្បាប់ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា អាចស្វែងរកបានតាមរយៈ៖ http://sithi.org/temp.php?title=Law-on-the-Statute-of-Judges-and-Prosecutors&url=law_detail.php&lg=&id=264។

[18] ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចស្វែងរកបានតាមរយៈ៖ http://sithi.org/temp.php?title=Law-on-the-Organization-and-Functioning-of-SCM&url=law_detail.php&lg=&id=263 ។

ព្រះរាជអាជ្ញាតាមរយៈការចូលរួមរបស់ក្រសួងនេះនៅក្នុងការចាត់ចែងថវិកាសម្រាប់ប្រព័ន្ធយុត្តិធម៌ ការតែងតាំង ការដំឡើងឋានៈ អាណត្តិ និងការដកហូតតំណែង[19]។

ជាចុងក្រោយ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនដែលត្រូវបានអនុម័តក្នុងខែកក្កដា ឆ្នាំ២០១៦ ហើយបានចូលជាធរមានក្នុងខែមករា ឆ្នាំ២០១៧[20] បានចែងអំពីបទដ្ឋានគតិយុត្តិ និងនីតិវិធីពាក់ព័ន្ធជាមួយអនីតិជនដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។[21] ច្បាប់នេះ ត្រូវតែអនុម័តឱ្យបានតឹងរឹងបំផុតដើម្បីការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជន។

កាលពីខែមិថុនា ឆ្នាំ ២០០៣ គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ក៏បានអនុម័តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ("យុទ្ធសាស្ត្រ")។[22] យុទ្ធសាស្ត្រនេះ កំណត់អំពីគោលការណ៍ណែនាំចំនួន ៤ ដែលមានប្រភពចេញពីរដ្ឋធម្មនុញ្ញដើម្បីជាមគ្គុទ្ទេសក៍ការធ្វើកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌រួមមាន៖ សិទ្ធិរបស់បុគ្គល គោលការណ៍លទ្ធិប្រជាធិបតេយ្យសេរី ការបែងចែកអំណាច និងនីតិរដ្ឋ។ យុទ្ធសាស្ត្រនេះក៏កំណត់

---

[19] "ការដាក់របាយការណ៍រួមនៃការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់លើកទីពីររបស់ព្រះរាជាណាចក្រកម្ពុជា (យូភីអ) ទៅក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ស្តីពីការទទួលបានយុត្តិធម៌នៅកម្ពុជា" JST7 - ការដាក់របាយការណ៍រួម ៧, ម.ស.ម.ក អង្គការគោលដៅយុត្តិធម៌ និង អាដហុក ថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៨ ផ្នែក ២ https://www.ohchr.org/EN/HRBodies/UPR/Pages/UPRKHStakeholdersInfoS32.aspx.។ ("ការដាក់របាយការណ៍យូភីអ ស្តីពីការទទួលបានយុត្តិធម៌ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨") *ក៏មើលផងដែរ* "ការវិភាគផ្លូវច្បាប់ សេចក្តីព្រាងច្បាប់ទាំងបីទាក់ទងនឹងប្រព័ន្ធយុត្តិធម៌" ម.ស.ម.ក ខែឧសភា ឆ្នាំ២០១៤ https://cchrcambodia.org/admin/media/analysis/analysis/english/2014_06_17_CCHR_Analysis_of_the_Draft_Laws_on_Judicial_Reforms_(ENG).pdf។ "មតិយោបល់ចំពោះបញ្ញត្តិជាក់លាក់នៃសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញាទាក់ទងនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ" ការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ("**ការិយាល័យឧត្តមស្នងការ**") ខែឧសភា ឆ្នាំ២០១៤ http://cambodia.ohchr.org/~cambodiaohchr/sites/default/files/OHCHR%20comments%20on%20draft%20Law%20on%20status%20of%20J%20and%20P,%20ENG%20May%202014%20final.pdf។ "មតិយោបល់ចំពោះបញ្ញត្តិជាក់លាក់នៃសេចក្តីព្រាងច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទាក់ទងនឹងបទដ្ឋានសិទ្ធិនុស្សអន្តរជាតិ" ការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា (**ការិយាល័យឧត្តមស្នងការ**) ខែឧសភា ឆ្នាំ២០១៤ http://cambodia.ohchr.org/~cambodiaohchr/sites/default/files/OHCHR%20comments%20on%20SCM%20Draft%20law,%20ENG%20May%202014%20final.pdf។ "មតិយោបល់អំពីបញ្ញត្តិជាក់លាក់នៃសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាកាទាក់ទងនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ" ការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ("**ការិយាល័យឧត្តមស្នងការ**") ខែឧសភា ឆ្នាំ២០១៤ http://cambodia.ohchr.org/~cambodiaohchr/sites/default/files/OHCHR%20comments%20on%20draft%20Law%20on%20org%20of%20courts,%20ENG%20May%202014%20final.pdf។

[20] ច្បាប់ពីយុត្តិធម៌អនីតិជន៖ http://sithi.org/temp.php?title=Law-On-Juvenile-Justice&url=law_detail.php&lg=&id=283។

[21] សូមមើលផងដែរ កម្រងសំណួរចម្លើយរបស់អង្គការ UNICEF អំពីច្បាប់ស្តីពីយុត្តិធម៌អនីតិជនដែលទើបនឹងអនុម័តថ្មីក្នុងប្រទេសកម្ពុជា ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០១៦ អាចស្វែងរកបានតាមរយៈ៖ https://unicefcambodia.blogspot.com/2016/09/q-on-newly-adopted-juvenile-justice-law.html។

[22] សូមមើល "អភិបាលកិច្ចគោលនយោបាយរបស់រដ្ឋាភិបាល" ក្រុមប្រឹក្សាភិបាលស្តារនីតិសម្បទា និងអភិវឌ្ឍកម្ពុជា ('CRBD') និងក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា ("CDC") ឆ្នាំ២០១៤ វាក្យសព្ទ ១៦ http://www.cdc-crdb.gov.kh/cdc/7cg_meeting/position_paper_eng2004/7cg_02_1.htm.

អំពីគោលដៅជាយុទ្ធសាស្ត្រ[23] ដែលបង្កើតបានជាមូលដ្ឋានគ្រឹះនៃផែនការសកម្មភាពកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨។[24] គោលដៅទីមួយនៃគោលដៅជាយុទ្ធសាស្ត្រទាំងនេះគឺ ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនូវការការពារសិទ្ធិជាមូលដ្ឋាន និងសេរីភាព។ បន្ថែមលើនេះទៀតក្នុងខែឧសភា ឆ្នាំ២០១៧ លេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មាធិការកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់ក្រសួងយុត្តិធម៌ បានផ្តួចផ្តើមគំនិតឱ្យមានយុទ្ធនាការ ១០០ ថ្ងៃ ដើម្បីវាយតម្លៃលទ្ធផលការងារ និងប្រសិទ្ធភាពរបស់តុលាការ។[25] យុទ្ធនាការនេះ មានគោលបំណងធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រ និងធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីធ្វើឱ្យប្រព័ន្ធយុត្តិធម៌កាន់តែមានលក្ខណៈគួរជាទីជឿជាក់ច្បាស់ និងអាចអនុវត្តបាន ហើយគោលបំណងរបស់យុទ្ធនាការនេះ ក៏ដើម្បីកែលម្អកិត្យានុភាពរបស់តុលាការ និងបង្កើនការទុកចិត្ត និងជំនឿជឿជាក់របស់សាធារណជនមកលើប្រព័ន្ធតុលាការផងដែរ។ នៅខែកញ្ញា ឆ្នាំ២០១៧ ដំណាក់កាលទីមួយនៃដំណើរការនៃយុទ្ធនាការនេះបានបញ្ចប់ ហើយលទ្ធផលបឋមបានបង្ហាញថាមានចំណុចខ្វះខាតសំខាន់ចំនួនបី៖ ការរៀបចំផែនការនិងយុទ្ធសាស្ត្រ ធនធានមនុស្សនិងធនធានហិរញ្ញវត្ថុ និងការប្រាស្រ័យទាក់ទងរវាងតុលាការនិងសាធារណជន។[26] ដំណាក់កាលទីពីរបានចាប់ផ្តើមនៅក្នុងខែកញ្ញា ឆ្នាំ២០១៧ ចាប់តាំងពីពេលនោះមកមិនមានព័ត៌មានបច្ចុប្បន្នភាពបន្ថែមទៀតអំពីដំណើរការនេះ ដែលអាចរកបានជាសាធារណៈឡើយ។[27]

---

[23] កម្មវត្ថុរួមមាន៖ ១) ការកែលម្អការការពារសិទ្ធិជាមូលដ្ឋាន និងសេរីភាព ២) ទំនើបកម្មក្របខ័ណ្ឌការងារផ្នែកច្បាប់ ៣) ការផ្តល់លទ្ធភាពកាន់តែប្រសើរដើម្បីទទួលបានព័ត៌មានផ្នែកច្បាប់ និងយុត្តិធម៌ ៤) ការពង្រឹងគុណភាពដំណើរការផ្នែកច្បាប់ និងសេវាពាក់ព័ន្ធ ៥) ការពង្រឹងសេវាយុត្តិធម៌ ពោលគឺអំណាចរបស់អង្គតុលាការ និងសេវាអយ្យការ ៦) ការដាក់ឱ្យមានយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ៧) ការពង្រឹងស្ថាប័នក្នុងវិស័យច្បាប់ និងយុត្តិធម៌ ដើម្បីបំពេញតាមអាណត្តិរបស់ខ្លួន។ សូមមើល "អភិបាលកិច្ចគោលនយោបាយរបស់រដ្ឋាភិបាល" ក្រុមប្រឹក្សាភិបាលស្តារនីតិសម្បទា និងអភិវឌ្ឍកម្ពុជា ('CRBD') និងក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា ("CDC") ឆ្នាំ២០១៤ វាក្យសព្ទ ១៥-២៤ http://www.cdc-crdb.gov.kh/cdc/7cg_meeting/position_paper_eng2004/7cg_02_1.htm។

[24] ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ផែនការសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលត្រូវបានអនុម័តដោយរដ្ឋាភិបាលកម្ពុជានៅក្នុងកិច្ចប្រជុំពេញអង្គនៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៥, សូមមើលផងដែរ ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិឆ្នាំ២០១៤-២០១៨ របស់រាជរដ្ឋាភិបាលកម្ពុជា ទំព័រ ៩-១២ វាក្យខ័ណ្ឌ ២.១១ ដល់ ២.២៣ អាចស្វែងរកបានតាមរយៈ៖ https://www.ilo.org/wcmsp5/groups/public/---asia/---ro-bangkok/---sro-bangkok/documents/genericdocument/wcms_364549.pdf (ការបកប្រែ)។ សំណៅច្បាប់ដើមអាចរកបាននៅ http://cdc-crdb.gov.kh/cdc/documents/NSDP_2014-2018.pdf។

[25] សេចក្តីជូនដំណឹងស្តីពីយុទ្ធនាការ ១០០ ថ្ងៃដើម្បីវាយតម្លៃលទ្ធផលការងារ និងប្រសិទ្ធផលរបស់តុលាការ ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១៧ ចេញដោយលេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការកំណែទម្រង់ផ្នែកច្បាប់ និងយុត្តិធម៌នៃក្រសួងយុត្តិធម៌៖ https://www.facebook.com/334873460054405/photos/a.336969683178116/654031978138550/?type=3&theater (មានតែសំណៅជាភាសាខ្មែរ) "ក្រសួងធ្វើការសិក្សាលើតុលាការដោយខ្លួនឯង "*ភ្នំពេញ ប៉ុស្តិ៍* ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ https://www.phnompenhpost.com/national/ministry-undertake-its-own-study-courts.

[26] "មន្ត្រី៖ លទ្ធផលបឋមយុទ្ធនាការ១០០ថ្ងៃរបស់ក្រសួងយុត្តិធម៌រកឃើញចំណុចខ្វះខាត៣ធំ" វិទ្យុវាយោ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៧ http://vayofm.com/news/detail/80228-555917756.html?option=tem&textid=49040។

[27] មន្ត្រី៖ លទ្ធផលបឋមយុទ្ធនាការ១០០ថ្ងៃរបស់ក្រសួងយុត្តិធម៌រកឃើញចំណុចខ្វះខាត៣ធំ" វិទ្យុវាយោ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៧ http://vayofm.com/news/detail/80228-555917756.html?option=tem&textid=49040។

នៅក្នុងឆ្នាំ២០១៨ អាជ្ញាធរសាធារណៈ បានធ្វើសេចក្តីប្រកាសមួយចំនួន ដែលអាចនាំឱ្យមានការកែលម្អគួរឱ្យកត់សម្គាល់នូវស្ថានភាពអ្នកដែលប្រឈមនឹងយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា៖

- ការបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលសម្រាប់មេធាវី ចៅក្រម និងព្រះរាជអាជ្ញា ដោយសហការជាមួយនឹងសាកលវិទ្យាល័យចិន[28] និងការបណ្តុះបណ្តាលប្រចាំឆ្នាំសម្រាប់ចៅក្រម និងព្រះរាជអាជ្ញាស្តីពីជំនាញបច្ចេកទេស ក្រមរដ្ឋប្បវេណី ក្រមវិជ្ជាជីវៈ និងច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ[29]។
- ការបង្កើតមណ្ឌលឃុំខ្លួនថ្មីសម្រាប់អ្នកជាប់ឃុំអាយុក្រោម ១៨ ឆ្នាំនៅក្នុងខេត្តកណ្តាល។ មណ្ឌលដែលគួរតែសាងសង់រួចនៅឆ្នាំ២០១៩ នឹងក្លាយជាមណ្ឌលឃុំខ្លួនទីមួយសម្រាប់គោលបំណងនេះនៅក្នុងប្រទេសកម្ពុជា។[30]
- ការរៀបចំគោលនយោបាយជំនួយផ្លូវច្បាប់ទូទាំងប្រទេស ដើម្បីផ្តល់មេធាវីដល់ក្រុមងាយរងគ្រោះនៅក្នុងតំបន់ជនបទនៅកម្ពុជា។[31]
- ការបង្កើនចំនួនមូលនិធិប្រចាំឆ្នាំសម្រាប់គណៈមេធាវីដល់ ៣០០ ០០០ ដុល្លារអាមេរិក ដើម្បីឱ្យគណៈមេធាវីនេះមានលទ្ធភាពផ្តល់សេវាមេធាវីដល់ជនជាប់ចោទក្រីក្រប្រមាណ ៣០០០ សំណុំរឿង។[32]

---

28 "សាកលវិទ្យាល័យគ្រោងរៀបចំការបណ្តុះបណ្តាលសម្រាប់មន្ត្រីច្បាប់ជាន់ខ្ពស់" *ខ្មែរថាមស៍* ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ https://www.khmertimeskh.com/50493617/university-plans-training-for-top-legal-officers/.

29 "របាយការណ៍ជាតិដែលបានដាក់ជូនដោយស្របតាមវាក្យខណ្ឌ ៥ នៃឧបសម្ព័ន្ធនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ១៦/២១ រាជរដ្ឋាភិបាលកម្ពុជា" នៅក្នុងឯកសាររបស់ អ.ស.ប លេខ. A/HR/WG.6/32/KHM/1 រាជរដ្ឋាភិបាលកម្ពុជាលេខ ១៩ https://documents-dds-ny.un.org/doc/UNDOC/GEN/G18/341/00/PDF/G1834100.pdf?OpenElement ("របាយការណ៍រដ្ឋាភិបាលសម្រាប់វដ្តទី ៣ នៃយូភីអ)។

30 "មណ្ឌលឃុំខ្លួនអ្នកជាប់ឃុំយុវជនទីមួយត្រូវបានគម្រោងបង្កើតឡើង" *ខ្មែរថាមស៍* ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ https://www.khmertimeskh.com/50505355/first-youth-detention-centre-planned/។

31 "គោលនយោបាយច្បាប់ស្តីពីក្រុមទីទាល់ក្រដែលបានបញ្ចប់ដោយរដ្ឋាភិបាល សហភាពអឺរ៉ុប" *ភ្នំពេញ ប៉ុស្តិ៍* ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៨ https://www.phnompenhpost.com/national/legal-policy-marginalised-groups-finished-govt-eu។ "សេចក្តីថ្លែងបញ្ចប់បេសកកម្ម" របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ("UNSRSHRC") ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ទំព័រ ៤, វាក្យខណ្ឌ ២ https://cambodia.ohchr.org/sites/default/files/pressstatementsource/181108%20_ENG_END%20OF%20MISSION%20STATEMENT.pdf ("ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ "សេចក្តីថ្លែងបញ្ចប់បេសកកម្ម" របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ("UNSRSHRC") "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ("UNSRSHRC") ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ វាក្យខណ្ឌ ៧៩ http://cambodia.ohchr.org/sites/default/files/Annual-reports/Annual%20Report%202018%20of%20SR%20-%20A_HRC_39_73_EN.pdf ("ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ របាយការណ៍ UNSRSHRC")។

32 "លែងខ្វះខាតមេធាវី" *ភ្នំពេញ ប៉ុស្តិ៍* ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨ https://www.phnompenhpost.com/national/no-more-lawyer-shortage។ "ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ "សេចក្តីថ្លែងបញ្ចប់បេសកកម្ម" របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ("UNSRSHRC") វាក្យខណ្ឌ ២។

- ការបង្កើត "បន្ទប់មេធាវី" ដែលរួមទាំងនៅក្នុងបន្ទប់សវនាការទាំងអស់នៅទូទាំងប្រទេស សម្រាប់អ្នកពុំមានមធ្យោបាយហិរញ្ញវត្ថុអាចពិគ្រោះយោបល់ជាមួយនឹងមេធាវីដោយឥតគិតថ្លៃ។[33]
- ការបង្កើតសាលាឧទ្ធរណ៍តំបន់ចំនួនបីនៅក្នុងខេត្តបាត់ដំបង ត្បូងឃ្មុំ និងព្រះសីហនុនឹងបញ្ចប់នៅចុងឆ្នាំ២០១៩[34] គម្រោងសាងសង់សាលាឧទ្ធរណ៍ចំនួនបួនទៀត[35] និងរៀបចំផែនការបណ្តុះបណ្តាលពេញលេញ និងពង្រាយចៅក្រមសាលាឧទ្ធរណ៍ទៅតាមសាលាឧទ្ធរណ៍តំបន់ទាំងនេះ។[36]
- ការបង្កើតក្រុមការងារដោះស្រាយបញ្ហាពន្ធនាគារចង្អៀតនៅកម្ពុជា។[37]
- ការអនុម័តថវិកាដាច់ដោយឡែកចំនួន ៥០០ លានរៀល (ប្រមាណ ១២៣ ៥១១ ដុល្លារអាមេរិក) សម្រាប់ "សេវាផ្លូវច្បាប់សម្រាប់ស្ត្រី"[38] និងសេចក្តីប្រកាសបង្កើតក្រុមមេធាវីចំនួន ៥០ នាក់ដែលគាំទ្រដោយរដ្ឋាភិបាល ដើម្បីផ្តល់សេវាឥតគិតថ្លៃសម្រាប់កម្មករស្ត្រីដែលទាក់ទងនៅក្នុងវិវាទផ្លូវច្បាប់។[39]

---

33 "របាយការណ៍ជាតិដែលបានដាក់ជូនដោយស្របតាមវាក្យខណ្ឌ ៥ នៃឧបសម្ព័ន្ធនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ១៦/២១ រាជរដ្ឋាភិបាលកម្ពុជា" ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ វាក្យខណ្ឌ ១៨ខ https://documents-dds-ny.un.org/doc/UNDOC/GEN/G18/341/00/PDF/G1834100.pdf?OpenElement ("របាយការណ៍រដ្ឋាភិបាលសម្រាប់វដ្តទី ៣ នៃយូភីអ")។

34 "សាលាឧទ្ធរណ៍ថ្មីចំនួនបីគ្រោងនឹងបញ្ចប់ការសាងសង់ឆ្នាំ២០១៩" *ទស្សនាវដ្តីសំណង់ និងអចលនទ្រព្យ* ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៨។ https://www.construction-property.com/khread-news-1240/ (មានតែជាភាសាខ្មែរ)។ សូមមើលផងដែរ របាយការណ៍រដ្ឋាភិបាលសម្រាប់វដ្តទី ៣ នៃយូភីអ វាក្យខណ្ឌ១៨គ ៤០ ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សេចក្តីថ្លែងបញ្ចប់បេសកកម្ម" របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ("UNSRSHRC") ទំព័រ ៤ វាក្យខណ្ឌ ២។

35 "សាលាឧទ្ធរណ៍ថ្មីចំនួនបីគ្រោងនឹងបញ្ចប់ការសាងសង់ឆ្នាំ២០១៩" *ទស្សនាវដ្តីសំណង់ និងអចលនទ្រព្យ* ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៨។ https://www.construction-property.com/khread-news-1240/ (មានតែជាភាសាខ្មែរ)។

36 ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ "សេចក្តីថ្លែងបញ្ចប់បេសកកម្ម" របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ("UNSRSHRC") វាក្យខណ្ឌ ៨១។

37 "ក្រុមការងារត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហាចង្អៀតនៅក្នុងពន្ធនាគារ" *ភ្នំពេញ ប៉ុស្តិ៍* ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ https://www.phnompenhpost.com/national/taskforce-set-address-overcrowding-prisons។

38 របាយការណ៍រដ្ឋាភិបាលសម្រាប់វដ្តទី ៣ នៃយូភីអ" វាក្យខណ្ឌ ១៧ "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា៖ ផ្តល់មតិយោបល់ដោយរដ្ឋ" ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ ២០១៨ ទំព័រ២៥ វាក្យខណ្ឌ ៤ http://cambodia.ohchr.org/sites/default/files/Annual-reports/Addendum% 202%20to %20the %20Annual%20Report%20of%20SR%202018.pdf. "របាយការណ៍ជាតិដែលបានដាក់ជូនដោយស្របតាមវាក្យខណ្ឌ ៥ នៃឧបសម្ព័ន្ធនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ១៦/២១ការិយាល័យឧត្តមស្នងការ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ វាក្យខណ្ឌ ១៧ https://documents-dds-ny.un.org/doc/UNDOC/GEN/G18/341/00/PDF/G1834100.pdf?OpenElement។

39 "លោក ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា សន្យាផ្តល់ជំនួយផ្លូវច្បាប់សម្រាប់ "ស្ត្រីងាយរងគ្រោះ" សំឡេងសហរដ្ឋអាមេរិក (VOA) ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៩ https://www.voacambodia.com/a/cambodia-legal-aid-women-garment-industry/4809828.html។ "លោកនាយករដ្ឋមន្ត្រីកម្ពុជា ជំរុញឱ្យកម្មករស្វែងរកជំនួយផ្លូវច្បាប់ពី ក្រុមការងារផ្លូវច្បាប់សម្តេច ហ៊ុន សែន" *Fresh News Asia* ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ http://www.freshnewsasia.com/index.php/en/localnews/113590-2019-02-20-05-18-48.html។

- ការសិក្សាលើលទ្ធភាពដើម្បីដាក់បញ្ចូលវិធានរបស់អង្គការសហប្រជាជាតិសម្រាប់ការប្រព្រឹត្តចំពោះជនជាប់ឃុំជាស្ត្រី និងវិធានមិនឃុំឃាំងជនល្មើសជាស្ត្រី (វិធានបាងកក)។[40]
- ការរៀបចំសេចក្តីព្រាងច្បាប់ដែលកំណត់នូវបទដ្ឋានអប្បបរមា ទាក់ទងនឹងអំពើហិង្សាផ្អែកលើយេនឌ័រ។[41]
- របាយការណ៍ដែលក្រសួងយុត្តិធម៌បានគ្រោងធ្វើសេចក្តីព្រាងច្បាប់ ដែលមានគោលបំណងផ្តល់សំណងដល់អ្នកដែលត្រូវឃុំខ្លួនខុសក្នុងពន្ធនាគារ។[42]

រដ្ឋាភិបាលហាក់បានបន្តខិតខំប្រឹងប្រែងធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ រួមទាំង ការកសាងសមត្ថភាព ការកែលម្អឯករាជ្យភាព និងភាពមិនលម្អៀងរបស់តុលាការ និងការបែងចែកអំណាច ការគោរពសិទ្ធិបុគ្គលដើម្បី "ទទួលបានការជឿជាក់របស់សាធារណជនកាន់តែខ្លាំងឡើងមកលើប្រព័ន្ធតុលាការ"។[43]

ទោះជាយ៉ាងនេះក្តី នៅមានក្តីបារម្ភមួយចំនួនលើប្រព័ន្ធយុត្តិធម៌ និងការគ្រប់គ្រងរដ្ឋបាលយុត្តិធម៌ ដូចជា៖

- ការឃុំខ្លួនបណ្តោះអាសន្នហួសពេលកំណត់ កង្វះការប្រើប្រាស់វិធានការឱ្យនៅក្រៅឃុំ ហើយជាលទ្ធផលធ្វើឱ្យពន្ធនាគារនៅកម្ពុជាមានភាពចង្អៀតណែន[44]។ គិតត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ មានជនជាប់ឃុំឃាំងចំនួន ២៨ ៨២៩ នាក់ ដែលក្នុងនោះមានតែជនជាប់ឃុំ ចំនួន ៧ ៦៨៤ នាក់

---

[40] របាយការណ៍រដ្ឋាភិបាលសម្រាប់វដ្តទី ៣ នៃយូភីអ" វាក្យខណ្ឌ ៤២។

[41] ជុំ ដោគជាតា, "សង្គមស៊ីវិលពិភាក្សាលើសេចក្តីព្រាងច្បាប់ជួយទៅដល់ស្ត្រីនិងកុមារីរងគ្រោះដោយអំពើហិង្សា(មានសំឡេង)", "[បកប្រែជាភាសាអង់គ្លេស៖ Civil Society Discusses Draft Laws to Address Violent Women and Girls] មណ្ឌលព័ត៌មានស្ត្រីកម្ពុជា ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨, https://wmc.org.kh/ngo-women/ [មានតែសំណៅជាភាសាខ្មែរ]។

[42] "ក្រសួងគ្រោងធ្វើសេចក្តីព្រាងច្បាប់ដែលមានគោលបំណងផ្តល់សំណងដល់អ្នកដែលត្រូវឃុំខ្លួនក្នុងពន្ធនាគារខុស។ *ខ្មែរថាមស៍* ថ្ងៃទី៣0 ខែសីហា ឆ្នាំ២០១៨ https://www.khmertimeskh.com/50528036/ministry-plans-law-to-compensate-those-wrongly-imprisoned-by-courts/។

[43] របាយការណ៍រដ្ឋាភិបាលសម្រាប់វដ្តទី ៣ នៃយូភីអ" វាក្យខណ្ឌ ៧៤។

[44] "ពេលដែលត្រូវដោះលែងឱ្យនៅក្រៅឃុំ៖ បញ្ឈប់ការឃុំខ្លួនបណ្តោះអាសន្នមិនបាច់នៅកម្ពុជា" *លីកាដូ* ថ្ងៃ០១ ខែវិច្ឆិកា ឆ្នាំ២០១៨ http://www.licadho-cambodia.org/collection/36/prisons, pre-trial detention, cambodia?khmer ការដាក់របាយការណ៍យូភីអស្តីពីការទទួលបានយុត្តិធម៌ នៅត្រឹមថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ ផ្នែក ៥.១ ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សេចក្តីថ្លែងបញ្ចប់បេសកកម្មរបស់ UNSRSHRC ទំព័រ៤ វាក្យខណ្ឌ ៣ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ របាយការណ៍ UNSRSHRC វាក្យខណ្ឌ ១៣ (ច) ៤៦ "កម្រងឯកសារស្តីពីកម្ពុជារបស់ការិយាល័យឧត្តមស្នងការ" ការិយាល័យឧត្តមស្នងការ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ វាក្យខណ្ឌ ៤៧ https://documents-dds-ny.un.org/doc/UNDOC/GEN/G18/337/25/PDF/G1833725.pdf?OpenElement

ប៉ុណ្ណោះដែលបញ្ជាក់ថាបានទទួលការផ្តន្ទាទោសជាស្ថាពរ[45]។ នៅខែកក្កដា ឆ្នាំ២០១៨ មានជនជាប់ឃុំឃាំងចំនួន ៣០ ៤៤៤ នាក់ ក្នុងនោះជនជាប់ឃុំ ២ ៦១៦ នាក់គឺជាស្ត្រី និង ១ ៥៥១ នាក់ជាអនីតិជន។[46]

- ការចោទប្រកាន់ថាកង្វះឯករាជ្យភាព និងភាពមិនលម្អៀងរបស់ប្រព័ន្ធតុលាការ។[47]
- និទណ្ឌភាពនៅតែបន្ត។[48]
- ការទទួលបានជំនួយផ្លូវច្បាប់នៅមានកម្រិត និងជាពិសេសកង្វះគោលនយោបាយជំនួយផ្លូវច្បាប់គ្រប់ជ្រុងជ្រោយ កង្វះថវិកាសម្រាប់ជំនួយផ្លូវច្បាប់ និងចំនួនមេធាវី និងសេវាជំនួយផ្លូវច្បាប់នៅមានកម្រិត។[49]
- ការដែលអាចទទួលបានសេវាយុត្តិធម៌នៅមានកម្រិតនៅខាងក្រៅទីក្រុងភ្នំពេញ។[50]
- លទ្ធភាពប្រើប្រាស់សេវាយុត្តិធម៌នៅតែជាបញ្ហាប្រឈមសម្រាប់ជនពិការ មិនថាជាជនរងគ្រោះ ឬជាជនជាប់ចោទក៏ដោយ។[51]
- ការទទួលបានព័ត៌មានផ្លូវច្បាប់មិនគ្រប់គ្រាន់ ដូចជា ច្បាប់ បទប្បញ្ញត្តិ សេចក្តីសម្រេចរបស់តុលាការ។[52]
- កង្វះការការពារស្ត្រីជាប់ឃុំ និងកូនរបស់ពួកគេ។[53]
- កង្វះស្ត្រីនៅក្នុងប្រព័ន្ធតុលាការ។[54]
- ការមិនមាននីតិវិធីជាក់លាក់ និងវិធានការសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាផ្អែកលើយែនឌ័ររួមទាំងអំពើហិង្សាក្នុងគ្រួសារ[55] និងហេតុការណ៍ដែលអ្នកប្រព្រឹត្តអំពើហិង្សាផ្លូវភេទ និងយែនឌ័រជារឿយៗ មិនត្រូវបានផ្តន្ទាទោសឡើយ។[56]

---

[45] "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា" UNSRHR, នៅក្នុងឯកសាររបស់ អ.ស.ប លេខ A/HRC/39/73 ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨, វាក្យខណ្ឌ ៤៦ https://documents-dds-ny.un.org/doc/UNDOC/GEN/G18/249/54/PDF/G1824954.pdf?OpenElement។

[46] របាយការណ៍រាជរដ្ឋាភិបាលសម្រាប់វដ្តទី ៣ នៃយូភីអ វាក្យខណ្ឌ ៤០។

[47] ការដាក់របាយការណ៍យូភីអ ស្តីពីការទទួលបានយុត្តិធម៌ យុត្តិធម៌ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ ផ្នែក ២។

[48] ការដាក់របាយការណ៍យូភីអ ស្តីពីការទទួលបានយុត្តិធម៌ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ ផ្នែក ២.៣។

[49] ការដាក់របាយការណ៍យូភីអ ស្តីពីការទទួលបានយុត្តិធម៌ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ ផ្នែក ៣។

[50] ការដាក់របាយការណ៍យូភីអ ស្តីពីការទទួលបានយុត្តិធម៌ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ ផ្នែក ៤.៣។

[51] របាយការណ៍ UNSRSHRC ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ វាក្យខណ្ឌ ៤៨។

[52] ការដាក់របាយការណ៍យូភីអ ស្តីពីការទទួលបានយុត្តិធម៌ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ ផ្នែក ៤។

[53] "ការបង្ក្រាបគ្រឿងញៀន ធ្វើឲ្យកូនតូចនៅជាមួយម្តាយជាប់ឃុំមានច្រើន", *ភ្នំពេញ ប៉ុស្តិ៍*, ០២ ឧសភា ២០១៨, https://www.phnompenhpost.com/national-post-depth/war-drugs-youngest-inmates។

[54] ការដាក់របាយការណ៍យូភីអ ស្តីពីការទទួលបានយុត្តិធម៌ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ ផ្នែក ៥.៥ វាក្យខណ្ឌ ៤៧។

[55] ការដាក់របាយការណ៍យូភីអ ស្តីពីការទទួលបានយុត្តិធម៌ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ ផ្នែក ៥.៥ វាក្យខណ្ឌ ៤៨ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ របាយការណ៍ UNSRSHRC វាក្យខណ្ឌ ១៤ (ក)។

[56] "របាយការណ៍សង្ខេបរបស់ភាគីពាក់ព័ន្ធ" អំពីកម្ពុជា" ការិយាល័យឧត្តមស្នងការ ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ វាក្យខណ្ឌ ៣៩ https://www.upr-info.org/sites/default/files/document/cambodia/session_32_-_january_2019/e_1.pdf ថ្ងៃទី១៥ ខែ

- កង្វះការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល។[57]
- ភាពមិនស៊ីសង្វាក់គ្នានៅក្នុងការប្រើប្រាស់ និងការវាយតម្លៃភស្តុតាងនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ។[58]
- កង្វះតម្លាភាពចំពោះថ្លៃសេវាពាក់ព័ន្ធនឹងតុលាការ[59] និងប្រតិបត្តិការរបស់ក្រសួងយុត្តិធម៌ និងស្ថាប័នយុត្តិធម៌។[60]
- ការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជននៅមិនទាន់គ្រប់គ្រាន់។[61]
- កង្វះការការពារឱ្យបានគ្រប់គ្រាន់សម្រាប់កុមារជាជនរងគ្រោះ ឬជាសាក្សីរបស់ជនរងគ្រោះ[62] កង្វះប្រព័ន្ធការពារសង្គម និងកុមារទូលំទូលាយ និងកង្វះបុគ្គលិកសង្គមដែលទទួលបានការបណ្តុះបណ្តាលនៅទូទាំងប្រទេស។[63]

រដ្ឋាភិបាលទទួលស្គាល់ថា "ការអនុវត្តរបស់អាជ្ញាធរមានសមត្ថកិច្ច ដូចជាចៅក្រម និងព្រះរាជអាជ្ញា ជាទូទៅ គឺផ្អែកលើច្បាប់ជាតិ ទាំងនៅក្នុងដំណើរការនីតិវិធី និងការធ្វើសេចក្តីសម្រេច ដោយមិនបានពិចារណាលើច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិឡើយ។"[64]

---

សីហា ឆ្នាំ២០១៨ របាយការណ៍ វាក្យខណ្ឌ ៤៩ "កម្រងរបាយការណ៍ស្តីពីកម្ពុជារបស់ការិយាល័យឧត្តមស្នងការ" ការិយាល័យឧត្តមស្នងការ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ វាក្យខណ្ឌ ៤៥ https://documents-dds-ny.un.org/doc/UNDOC/GEN/G18/337/25/PDF/G1833725.pdf?OpenElement។

[57] សេចក្តីថ្លែងបញ្ចប់បេសកកម្មរបស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ("UNSRSHRC") ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ទំព័រ ៤ វាក្យខណ្ឌ ៤ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា (UNSRSHRC) វាក្យខណ្ឌ ១៣ (ធ)។

[58] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា (UNSRSHRC) ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ វាក្យខណ្ឌ ៨០។

[59] សេចក្តីថ្លែងបញ្ចប់បេសកកម្មរបស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ("UNSRSHRC") ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ទំព័រ ៤ វាក្យខណ្ឌ ៦ ក្រសួងយុត្តិធម៌កំពុងរៀបចំបញ្ចប់បញ្ជីនៃថ្លៃសេវានេះ សូមមើល របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា (UNSRSHRC) ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ វាក្យខណ្ឌ ១៣ (ឃ)។

[60] សេចក្តីថ្លែងបញ្ចប់បេសកកម្មរបស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ("UNSRSHRC") ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ទំព័រ ៤ វាក្យខណ្ឌ ៦។

[61] ការដាក់របាយការណ៍ស្តីពីយូភីអ ស្តីពីការទទួលបានយុត្តិធម៌ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ ផ្នែក ៥.៦។ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា (UNSRSHRC) ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ វាក្យខណ្ឌ ២៧។

[62] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា (UNSRSHRC) ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ វាក្យខណ្ឌ ២៧។

[63] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា (UNSRSHRC) ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ វាក្យខណ្ឌ ២៨។

[64] របាយការណ៍រដ្ឋាភិបាលសម្រាប់វដ្តទី៣នៃយូភីអ វាក្យខណ្ឌ ៧០។

## ១.២. គោលបំណង ទំហំនិងវិធីសាស្ត្រ

គោលបំណងនៃគម្រោងនេះ គឺធ្វើការវិភាគលើទិន្នន័យដែលប្រមូលបានពីការសង្កេតការណ៍ប្រចាំថ្ងៃនៅសាលាឧទ្ធរណ៍ ដើម្បីកំណត់អំពីចំណុចខ្លាំង និងចំណុចខ្សោយដែលមាននៅក្នុងប្រព័ន្ធយុត្តិធម៌។ តាមរយៈការទាញចំណាប់អារម្មណ៍ទៅលើបញ្ហានានានៅក្នុងដំណើរការសវនាការ ដែលតម្រូវឱ្យមានការកែលម្អឱ្យប្រសើរឡើងថែមទៀត ដូចជាការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាដើម និងការផ្តល់អនុសាសន៍ជាក់លាក់ទៅកាន់ស្ថាប័នយុត្តិធម៌ពាក់ព័ន្ធមួយចំនួន ម.ស.ម.ក មានបំណងចង់ពង្រឹង និងកែទម្រង់ប្រព័ន្ធយុត្តិធម៌ សម្រាប់ជាប្រយោជន៍ចំពោះប្រជាពលរដ្ឋគ្រប់រូប។

ចន្លោះពីខែសីហា ឆ្នាំ ២០០៩ ដល់ ខែមករា ឆ្នាំ ២០១៣ គម្រោងនេះបានសង្កេតការណ៍សវនាការនៅសាលាដំបូងរាជធានីភ្នំពេញ សាលាដំបូងខេត្តកណ្តាល សាលាដំបូងខេត្តបន្ទាយមានជ័យ និងសាលាដំបូងខេត្តរតនគិរី ហើយបានចេញផ្សាយរបាយការណ៍ប្រចាំឆមាសស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ចំនួន ៦ លើក។[65] នៅខែមករា ឆ្នាំ ២០១៣ គម្រោងបានបញ្ចប់សកម្មភាពសង្កេតការណ៍របស់ខ្លួននៅតាមសាលាដំបូងដោយប្តូរមកផ្តោតលើការសង្កេតការណ៍នៅសាលាឧទ្ធរណ៍វិញម្តង។ គម្រោងបានសម្រេចធ្វើការសង្កេតការណ៍នៅសាលាឧទ្ធរណ៍ ដើម្បីវាយតម្លៃអំពីបទដ្ឋានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានអនុវត្តនៅតុលាការជាន់ខ្ពស់។ គោលដៅគឺដើម្បីផ្តល់ការវិភាគអំពីនិន្នាការទាក់ទងនឹងការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលកើតឡើងនៅសាលាឧទ្ធរណ៍ និងដើម្បីបង្កើតជាក្របខ័ណ្ឌមួយ ដែលអាចដាក់ចេញនូវអនុសាសន៍បន្ថែមទៀត ហើយធ្វើឱ្យប្រសើរឡើងក្នុងការអនុវត្ត។

*តួលេខទី ១៖ ទិដ្ឋភាពទូទៅនៃសំណុំរឿងដែល ម.ស.ម.ក បានសង្កេតការណ៍*

| | ទិដ្ឋភាពទូទៅនៃសំណុំរឿងដែលបានសង្កេតការណ៍ | | | |
|---|---|---|---|---|
| | ២០១៤/២០១៥ | ២០១៦/២០១៧ | ២០១៧/២០១៨ | សរុប |
| ចំនួនសំណុំរឿង | ១២៨ | ៣៤០ | ២១៣ | ៦៨១ |
| ចំនួនជនជាប់ចោទ | ១៦១ | ៥៥៨ | ៣១៥ | ១ ០៣៤ |
| បទឧក្រិដ្ឋ | ៤៦ | ១៩១ | ៩៩ | ៣៣៦ |
| បទមជ្ឈិម | ៧៧ | ១៤២ | ១១១ | ៣៣០ |
| បទលហុ | ៥ | ៧ | ៣ | ១៥ |
| អនីតិជន(នាក់) | ១១ | ៣៥ | ៩ | ៥៥ |
| ស្ត្រី (នាក់) | ១៤ | ៨៤ | ៣៦ | ១៣៤ |

[65] របាយការណ៍ប្រចាំមាសទាំងប្រាំមួយស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា អាចស្វែងរកនៅ http://tmp.sithi.org/index.php?p=report&l=en#go។

គម្រោងនេះផ្តោតទៅលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗមួយចំនួន។ ដើម្បីកំណត់ថាតើសិទ្ធិណាខ្លះដែលគួរពិចារណា ម.ស.ម.ក ពឹងផ្អែកលើប្រភពពីខាងក្រៅដូចជា របាយការណ៍ និងការសិក្សាផ្សេងៗអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា និងអំពីប្រព័ន្ធយុត្តិធម៌កម្ពុជា។ លើសពីនេះទៀត ការសង្កេតការណ៍នៅសាលាឧទ្ធរណ៍នាំឱ្យ ម.ស.ម.ក ផ្តោតលើជាតុផ្សំជាក់លាក់មួយចំនួននៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មានលក្ខណៈខុសប្លែកគ្នាពីអ្វីដែល ម.ស.ម.ក បានអនុវត្តសកម្មភាពសង្កេតការណ៍របស់ខ្លួននៅឯសាលាដំបូង។

សិទ្ធិខាងក្រោមត្រូវបានជ្រើសរើសសម្រាប់គោលបំណងនៃការសង្កេតការណ៍៖

- សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ
- សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់
- សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី
- សិទ្ធិមានមេធាវី និងមានវត្តមាននៅក្នុងសវនាការ
- សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស
- សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព
- សិទ្ធិបង្ហាញភស្តុតាង (រួមទាំងសិទ្ធិហៅ និងសាកសួរសាក្សី)
- សិទ្ធិទទួលបាននូវការប្រកាសសេចក្តីសម្រេចជាសាធារណៈ
- សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ
- ការហាមឃាត់ប្រឆាំងនឹងការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ (ត្រូវបានជំនុំជម្រះចំពោះបទល្មើស ដែលអំពើនោះមិនមែនជាបទល្មើសក្នុងពេលដែលសកម្មភាពនោះត្រូវបានប្រព្រឹត្ត)
- ការហាមឃាត់ចំពោះការផ្តន្ទាទោសពីរដងចំពោះអំពើដដែល និង
- សិទ្ធិរបស់អនីតិជន។

អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក បានធ្វើការសង្កេតការណ៍សវនាការព្រហ្មទណ្ឌនៅសាលាឧទ្ធរណ៍ជារៀងរាល់ថ្ងៃធ្វើការ។ ដើម្បីឱ្យការកត់ត្រាទិន្នន័យពាក់ព័ន្ធនឹងការជំនុំជម្រះឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល ម.ស.ម.ក បានបង្កើតតារាងសង្កេតការណ៍សវនាការ ("តារាងសង្កេតការណ៍") សម្រាប់ប្រើប្រាស់នៅសាលាឧទ្ធរណ៍[66]។ តារាងសង្កេតការណ៍នេះ ត្រូវបានបង្កើតឡើងស្របតាមបរិបទរបស់គម្រោង និងមានជាង ៧០ សំណួរ ដែលឆ្លើយតបទៅនឹង ថាតើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ណាខ្លះ ដែលត្រូវបានគោរពតាមដោយតុលាការ។

ជាកិច្ចប្រឹងប្រែងដើម្បីធានានូវនិរន្តរភាពនៃកិច្ចសហការក្នុងន័យស្ថាបនា ម.ស.ម.ក បានបង្ហាញ និងពន្យល់អំពីតារាងសង្កេតការណ៍ និងសកម្មភាពសង្កេតការណ៍របស់ខ្លួនដល់តំណាងរបស់សាលាឧទ្ធរណ៍។ ម.ស.ម.ក ក៏បានបង្កើតឧបសម្ព័ន្ធចំនួន ១ ទំព័រ ភ្ជាប់ជាមួយនឹងតារាងសង្កេតការណ៍សម្រាប់ប្រើប្រាស់ក្នុងសវ

---

[66] តារាងសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍របស់ ម.ស.ម.ក http://tmp.sithi.org/?p=detail&id=96&l=kh#go។

នាការដែលជាប់ពាក់ព័ន្ធជនជាប់ចោទជាអនីតិជនផងដែរ។ ដោយពិចារណាឃើញថាតារាងសង្កេតការណ៍មានលក្ខណៈសង្ខេបខ្លី ម.ស.ម.ក បានចងក្រងសេចក្តីណែនាំលម្អិតអំពីការប្រើប្រាស់តារាងសង្កេតការណ៍ (“ការណែនាំអំពីតារាងសង្កេតការណ៍”)[67] ដើម្បីផ្តល់ការយល់ដឹងលើមូលដ្ឋានច្បាប់ ព្រមទាំងគោលបំណងនៃសំណួរនីមួយៗ និងធានាឱ្យមានការបកស្រាយស៊ីសង្វាក់គ្នាលើសំណួរនីមួយៗ។ អ្នកសង្កេតការណ៍ក៏ត្រូវបានផ្តល់ជូននូវឯកសារស្តីពីក្របខ័ណ្ឌការងារផ្នែកច្បាប់ គូសបញ្ជាក់អំពីច្បាប់ជាតិ និងអន្តរជាតិពាក់ព័ន្ធ ដើម្បីគាំទ្រដល់សំណួរនីមួយៗ នៅក្នុងតារាងសង្កេតការណ៍។

ម.ស.ម.ក ផ្តោតការយកចិត្តទុកដាក់ជាពិសេសលើចំណុចស្តីពីសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍[68] គឺក្តោបទាំងសិទ្ធិបានទទួលការពិនិត្យឡើងវិញទាំងស្រុងលើសំណុំរឿងផងដែរ។ យើងអាចនិយាយម្យ៉ាងទៀតថា ការពិនិត្យឡើងវិញលើបណ្តឹងឧទ្ធរណ៍ ចាំបាច់ត្រូវរួមមានទិដ្ឋភាពផ្នែកច្បាប់ និងសម្ភារៈនៃសេចក្តីសម្រេចឱ្យមានទោស និងការជំនុំជម្រះរបស់ជននោះ។[69] ដោយហេតុនេះ ការពិនិត្យឡើងវិញចាំបាច់ត្រូវផ្តល់ “ការវាយតម្លៃពេញលេញលើភស្តុតាង និងដំណើរការនៃការជំនុំជម្រះ” [70]។

ម.ស.ម.ក គោរពតាមគោលការណ៍អន្តរជាតិដែលត្រូវអនុវត្ត ដើម្បីសង្កេតការណ៍សវនាការ[71] ហើយបានបង្កើតឱ្យមានជាក្រមសីលធម៌ (“ក្រមសីលធម៌”) សម្រាប់អ្នកសង្កេតការណ៍សវនាការរបស់ខ្លួន។[72] ក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍ គូសបញ្ជាក់ពីកាតព្វកិច្ចមិនជ្រៀតជ្រែក ភាពមិនលម្អៀង និងការរក្សាការសម្ងាត់ ដែលមន្ត្រីសង្កេតការណ៍ត្រូវគោរពតាម។

នៅក្នុងការអនុវត្តសកម្មភាពសង្កេតការណ៍របស់ខ្លួននៅសាលាឧទ្ធរណ៍ ការជំនុំជម្រះជាក់លាក់គឺពុំត្រូវបានផ្តោតជាគោលដៅសំខាន់ៗនោះទេ ផ្ទុយទៅវិញ សវនាការដែលត្រូវសង្កេតការណ៍ត្រូវបានជ្រើសរើសដោយ

---

[67] ឯកសារណែនាំសម្រាប់តារាងសង្កេតការណ៍នៅតុលាការឧទ្ធរណ៍របស់ ម.ស.ម.ក http://tmp.sithi.org/?p=detail&id=96&l=kh#go។

[68] ក.អ.ស.ព.ន មាត្រា ១៤ (៥) ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៧៥។

[69] គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ សេចក្តីសម្រេចលេខ ៧០១/១៩៩៦ *សំណុំរឿង Gómez ទល់នឹងប្រទេសអេស្ប៉ាញ* ថ្ងៃទី០៦ ខែមេសា ឆ្នាំ ១៩៩៨ នៅក្នុងឯកសាររបស់ អ.ស.ប លេខ *GAOR*, A/55/40 (vol. II) ទំព័រ ១០៩ វាក្យខណ្ឌ ១១.១ http://www.un.org/documents/ga/docs/55/a5540vol2.pdf។

[70] គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ សេចក្តីសម្រេចលេខ ៦២៣, ៦២៤, ៦២៦, ៦២៧/១៩៩៥, *សំណុំរឿង V. P. Domukovsky et al. ទល់នឹងប្រទេស Georgia* ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ ១៩៩៨ នៅក្នុងឯកសាររបស់ អ.ស.ប លេខ *GAOR*, A/53/40 (vol. II), ទំព័រ ១១១ វាក្យខណ្ឌ ១៨.១១ http://juris.ohchr.org/Search/Details/833។

[71] អង្គការលើកលែងទោសអន្តរជាតិ សៀវភៅស្តីពីការជំនុំជម្រះដោយយុត្តិធម៌របស់អង្គការលើកលែងទោសអន្តរជាតិ ឆ្នាំ១៩៩៨ https://www.amnesty.org/en/documents/POL30/002/1998/en/។ “តើអ្វីជាការជំនុំជម្រះដោយយុត្តិធម៌៖ គោលការណ៍ណែនាំមូលដ្ឋានសម្រាប់បទដ្ឋានផ្នែកច្បាប់ និងការអនុវត្ត គណៈកម្មាធិការមេធាវីដើម្បីសិទ្ធិមនុស្ស ឆ្នាំ២០០០។ https://www.humanrightsfirst.org/wp-content/uploads/pdf/fair_trial.pdf; “សង្កេតការណ៍សវនាការ៖ សៀវភៅជំនួយស្មារតីសម្រាប់អ្នកប្រកបវិជ្ជាជីវៈ” អង្គការសម្រាប់សន្តិសុខ និងសហប្រតិបត្តិការនៅអឺរ៉ុប (OSCE) / ការិយាល័យទទួលបន្ទុកសិទ្ធិមនុស្ស និងវិទ្យាស្ថានប្រជាធិបតេយ្យ ឆ្នាំ២០០៨ https://www.osce.org/odihr/94216 “ការសង្កេតការណ៍សវនាការ” គណៈកម្មាធិការអ្នកច្បាប់អន្តរជាតិ ឆ្នាំ២០០២ https://www.osce.org/odihr/94216។

[72] ក្រមសីលធម៌សង្កេតការណ៍សវនាការរបស់ ម.ស.ម.ក http://tmp.sithi.org/?p=detail&id=60&l=kh#go។

ចែជន្យអាស្រ័យលើកាលវិភាគរបស់តុលាការ ដើម្បីធានាថា ដំណើរការនៃការប្រមូលទិន្នន័យនៅតែមិនលម្អៀង និងមានលក្ខណៈតំណាង។ នៅពេលដែលអ្នកសង្កេតការណ៍ចុះទៅធ្វើការសង្កេតសវនាការណាមួយ ព័ត៌មានត្រូវបានកត់ត្រាទុកដោយផ្ទាល់ទៅក្នុងតារាងសង្កេតការណ៍។ ទិន្នន័យដែលប្រមូល គឺកម្រិតនៅត្រឹមតែដំណើរការសវនាការផ្ទាល់ ដោយពុំមានកិច្ចសម្ភាសន៍ ឬកិច្ចពិភាក្សាបន្ថែមទៀតត្រូវបានធ្វើឡើងនោះទេ លើកលែងតែនៅពេលដែលអ្នកសង្កេតការណ៍សវនាការ ខិតខំស្វែងរកព័ត៌មានទាក់ទិនទៅនឹងសាលដីកានៃការជំនុំជម្រះដែលពុំត្រូវបានប្រកាសនៅថ្ងៃសវនាការ តែត្រូវបានលើកទៅប្រកាសនៅកាលបរិច្ឆេទក្រោយៗទៀត។ បន្ទាប់ពីសវនាការនីមួយៗ ទិន្នន័យដែលប្រមូលបានត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ("ប្រព័ន្ធគ្រប់គ្រងទិន្នន័យ")។[73]

ម.ស.ម.ក បានវិភាគទិន្នន័យសវនាការដែលកត់ត្រាទុកនៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ហើយព្យាយាមកំណត់រកការអនុវត្តវិជ្ជមាន ក៏ដូចជាបញ្ហាគួរឱ្យព្រួយបារម្ភដែលកើតមាននៅសវនាការជំនុំជម្រះនីមួយៗផងដែរ។ គោលបំណងសំខាន់បំផុតនៃការវិភាគគឺដើម្បីកំណត់ចំណុចខ្លាំង និងចំណុចខ្សោយទាំងឡាយនៅសាលាឧទ្ធរណ៍ ក៏ដូចជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ព្រមទាំងដើម្បីពិភាក្សាអំពីបញ្ហាទាំងអស់នេះជាមួយនឹងតុលាការ និងដៃគូពាក់ព័ន្ធនឹងវិស័យច្បាប់ផ្សេងទៀតក្នុងន័យបង្កើត និងអនុវត្តវិធីសាស្ត្រមួយចំនួន ដើម្បីធ្វើឱ្យប្រសើរឡើងដល់ការការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅតុលាការកម្ពុជា។ នៅខណៈពេលដែលសកម្មភាពសង្កេតការណ៍សវនាការនឹងនៅតែបន្ត ប្រព័ន្ធគ្រប់គ្រងទិន្នន័យនឹងត្រូវប្រើសម្រាប់វិភាគបែបប្រៀបធៀប និងកំណត់អំពីនិន្នាការក្នុងការអនុវត្តរបស់សាលាឧទ្ធរណ៍ វាយតម្លៃអំពីភាពប្រសើរឡើង និងចង្អុលបង្ហាញពីអនុសាសន៍បន្ថែមទៀត។

ខុសពីឆ្នាំមុន ដែលសំណុំរឿងភាគច្រើនដែលបានសង្កេតការណ៍គឺជាបទឧក្រិដ្ឋ (៥៦%) នៅក្នុងឆ្នាំ ២០១៧/២០១៨ ភាគច្រើននៃសំណុំរឿងដែលបានសង្កេតការណ៍ពាក់ព័ន្ធនឹងការចោទប្រកាន់ពីបទមជ្ឈិម (៥២%)។ ចំនួនសំណុំរឿងសរុបដែលបានសង្កេតការណ៍ក៏មានចំនួនតិចជាង ពោលគឺ ៣៤០ សំណុំរឿងនៅក្នុងឆ្នាំ២០១៦/២០១៧ បើធៀបទៅនឹង ២១៣ សំណុំរឿងនៅចន្លោះឆ្នាំ២០១៧/២០១៨ ដូច្នេះហើយរបកគំហើញនេះក៏ត្រូវបានពិនិត្យមើលដោយផ្អែកលើករណីទាំងនេះផងដែរ។

សេចក្តីព្រាងចុងក្រោយនៃរបាយការណ៍នេះត្រូវបានផ្ញើជូនប្រធានសាលាឧទ្ធរណ៍ ដើម្បីផ្តល់មតិយោបល់ និងអនុសាសន៍ ហើយបន្ទាប់មក ម.ស.ម.ក ក៏បានជួបប្រជុំជាមួយភាគីសាលាឧទ្ធរណ៍ ដើម្បីពិភាក្សា

[73] ប្រព័ន្ធគ្រប់គ្រងទិន្នន័យសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក
http://tmp.sithi.org/data/advanced_search/search.php?tmp&l=kh#go។

អំពីរបកគំហើញដែលប្រមូលបានពីការសង្កេតការណ៍ មិនតែប៉ុណ្ណោះមតិឆ្លើយតបលើរបកគំហើញសំខាន់ៗពីកិច្ចពិភាក្សានេះត្រូវបានដាក់បញ្ចូលក្នុងរបាយការណ៍។[74]

នៅពេលដែលរបាយការណ៍នេះត្រូវបានបោះពុម្ព ម.ស.ម.ក អាចស្នើសុំឱ្យមានកិច្ចប្រជុំដាក់លាក់មួយចំនួនជាមួយនឹងតំណាងរបស់សាលាឧទ្ធរណ៍ និងជាមួយអង្គការ អង្គភាព និងស្ថាប័នធ្វើការលើវិស័យយុត្តិធម៌ផ្សេងៗទៀតដែលស្ថាប័នទាំងនោះ អាចដោះស្រាយអនុសាសន៍ដែលបានលើកឡើង។ កិច្ចប្រជុំបែបនេះ ជាមូលដ្ឋានគ្រឹះសម្រាប់ការផ្លាស់ប្តូរគំនិត និងផ្តល់ការយល់ដឹងលម្អិតអំពីបញ្ហាប្រឈមរបស់ស្ថាប័នដែលធ្វើការដើម្បីពង្រឹងប្រព័ន្ធយុត្តិធម៌ និងមានគោលបំណងក្នុងការលើកកម្ពស់ការអនុវត្តអនុសាសន៍ដាក់ចេញដោយរបាយការណ៍នេះ។

[74] នៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១៩ ម.ស.ម.ក បានជួបជាមួយប្រធាន អនុប្រធានទាំងអស់ អគ្គព្រះរាជអាជ្ញា តំណាងចៅក្រម ព្រមទាំងអគ្គលេខាធិការរដ្ឋបាលនៅសាលាឧទ្ធរណ៍ ដើម្បីពិភាក្សាលើរបកគំហើញនៅក្នុងរបាយការណ៍នេះ។

## ២. និន្នាការទូទៅ

ផ្នែកនេះនៃរបាយការណ៍ កំណត់អំពីទិន្នន័យ "ដើម" ដែលបានកត់ត្រាក្នុងតារាងសង្កេតការណ៍សវនាការចំនួន២១៣ សំណុំរឿង ដែលបានសង្កេតការណ៍នៅសាលាឧទ្ធរណ៍ ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ២០១៧ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ដែលនឹងត្រូវវាយតម្លៃនៅក្នុងរបាយការណ៍នេះ។ ក្នុងផ្នែកនេះក៏ធ្វើការប្រៀបធៀបរបកគំហើញនៅក្នុងរបាយការណ៍នេះជាមួយនឹងរបបគំហើញនៅក្នុងរបាយការណ៍មុនៗផងដែរ ក្នុងគោលបំណងគូសបញ្ជាក់អំពីរបត់ និងឆ្លុះបញ្ចាំងផ្នែកដែលមានភាពប្រសើរឡើង និងផ្នែកផ្សេងទៀតដែលឃើញថាមានការធ្លាក់ចុះ។

| ២១៣ សំណុំរឿង | ជនជាប់ចោទ ៣១៥ នាក់ | | |
|---|---|---|---|
| ៨ សំណុំរឿងពាក់ព័ន្ធនឹងជនជាប់ចោទជាអនីតិជន (៣,៧៥%) | ស្ត្រី ៣៦ នាក់ (១១,៤%) | បុរស ២៧៩ នាក់ (៨៨,៦%) | អនីតិជន ៩ នាក់ (២,៨%) |

*តួលេខទី ២៖ សវនាការសាលាឧទ្ធរណ៍ដែលបានសង្កេតការណ៍៖ បទឧក្រិដ្ឋ បទមជ្ឈិម និង បទលហុ*




តួលេខទី ២ ខាងលើ បង្ហាញអំពីចំនួនសវនាការព្រហ្មទណ្ឌដែលបានសង្កេតការណ៍ដោយអ្នកសង្កេតការណ៍នៅក្នុងអំឡុងពេលធ្វើរបាយការណ៍ និងបែងចែកបទចោទប្រកាន់ទៅតាមចំណាត់ថ្នាក់នៃបទល្មើសផ្សេងគ្នា។

មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌកំណត់និយមន័យបទឧក្រិដ្ឋថា ជាបទល្មើសទាំងឡាយណាដែលអតិបរិមានៃទោសដាក់ពន្ធនាគារលើសពីរយៈពេលប្រាំឆ្នាំ។ បទមជ្ឈិមត្រូវបានកំណត់និយមន័យនៅក្នុងមាត្រា៤៧ ថាជាបទល្មើសទាំងឡាយណាដែលអតិបរមានៃទោសដាក់ពន្ធនាគារលើសពីប្រាំមួយថ្ងៃ និងក្រោម ឬស្មើនឹង

ប្រាំឆ្នាំ។ យោងតាមមាត្រា ៤៨ បទលហុ គឺជាបទល្មើសដែលផ្តន្ទាទោសអតិបរមាឱ្យជាប់ពន្ធនាគាររយៈពេលប្រាំមួយថ្ងៃ ឬតិចជាងនេះ ឬផ្តន្ទាទោសដោយការផាកពិន័យតែម្យ៉ាងប៉ុណ្ណោះ។[75]

*តួលេខទី ៣៖ ភាគីធ្វើបណ្ដឹងឧទ្ធរណ៍*




*សំដៅលើតំណាងអយ្យការអមសាលាដំបូង និងមហាអយ្យការអមសាលាឧទ្ធរណ៍។

តួលេខទី ៣ បង្ហាញអំពីអ្នកដែលបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមរបស់សាលាដំបូង។ សាលក្រមចេញដោយសាលាដំបូង អាចត្រូវបានប្តឹងដោយព្រះរាជអាជ្ញាអមសាលាដំបូង និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី (អ្នកទាំងពីរនេះអាចប្តឹងបានចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី)។[76] តួលេខនេះបង្ហាញបណ្តឹងឧទ្ធរណ៍ភាគច្រើន (៩៥%) ធ្វើឡើងដោយភាគីជនជាប់ចោទ។

តារាងខាងក្រោមនេះ បង្ហាញអំពីសវនាការដែលបានសង្កេតការណ៍ដោយ ម.ស.ម.ក អំពីសិទ្ធិដែលត្រូវបានគោរព និងសិទ្ធិមិនត្រូវបានគោរពពេញលេញ៖

| សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរព | សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរពមិនពេញលេញ |
|---|---|
| • សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី<br>• សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព<br>• សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ | • សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ<br>• សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់<br>• សិទ្ធិមានមេធាវី និងមានវត្តមាននៅក្នុងសវនាការ<br>• សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស |

[75] ក្រមព្រហ្មទណ្ឌ មាត្រា ៤៨។

[76] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៧៥។

| | |
|---|---|
| • ការហាមឃាត់ប្រឆាំងនឹងការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ<br>• ការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែល | • សិទ្ធិបង្ហាញភស្តុតាង<br>• សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ<br>• សិទ្ធិរបស់អនីតិជន |

ផ្នែកបន្ទាប់នេះ វិភាគអំពីការអនុវត្តជាក់ស្តែងផ្សេងៗនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដោយសាលាឧទ្ធរណ៍នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ។ សម្រាប់គោលបំណងនៃការវិភាគ ជាដំបូងរបាយការណ៍នេះ គូសបញ្ជាក់អំពីទិដ្ឋភាពផ្សេងៗនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរពនៅក្នុងសាលាឧទ្ធរណ៍ មុននឹងឈានដល់ការឆ្លុះបញ្ចាំងលើការអនុវត្តនានាដែលមិនបានគោរពពេញលេញតាមនិយាមនៃការជំនុំជម្រះដោយយុត្តិធម៌។

## ៣. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរព

ស្របពេលដែលសកម្មភាពសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក បានកត់សម្គាល់នូវការអនុវត្តដែលប៉ះពាល់ និងជាការរារាំងដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដូចដែលបានរៀបរាប់ខាងលើនេះ ម.ស.ម.ក ក៏ស្វាគមន៍ និងគួរឱ្យលើកទឹកចិត្តផងដែរ ដែលសង្កេតឃើញថា ធាតុផ្សំជាក់លាក់មួយចំនួននៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានគោរព និងអនុវត្តបានយ៉ាងប្រសើរនៅសាលាឧទ្ធរណ៍។

| សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរពនៅសាលាឧទ្ធរណ៍ |
| --- |
| • សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី |
| • សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព |
| • សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ |
| • ការហាមឃាត់ប្រឆាំងនឹងការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ |
| • ការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែល |

### ៣.១. សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
| --- | --- |
| ក.អ.ស.ព.ន មាត្រា ១៤ (៣)(ខ) | "ក្នុងការសម្រេចសេចក្តីចោទប្រកាន់បទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ត្រូវមានពេលវេលា និងសម្ភារបរិក្ខាគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៤៨ | "[...] ប្រសិនបើជនជាប់ចោទសុំរយៈពេល ឬប្រសិនបើតុលាការយល់ឃើញថា រឿងក្តីនោះមិនទាន់អាចជំនុំជម្រះភ្លាមៗបានទេនោះ សំណុំរឿងត្រូវលើកទៅពេលសវនាការក្រោយ [...]" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៩៨ | "ក្នុងរយៈពេល ២៤ ម៉ោងបានកន្លងផុតទៅ តាំងពីពេលផ្តើមនៃការឃាត់ខ្លួនមកនោះ បុគ្គលដែលឃាត់ខ្លួនអាចសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស [...]។ ជនដែលត្រូវបានជ្រើសរើសនេះអាចចូលទៅកាន់កន្លែងឃាត់ខ្លួន និងទាក់ទងជាមួយបុគ្គលសាមីខ្លួនបាន ៣០ (សាមសិប) នាទី ក្នុងលក្ខខណ្ឌធានាការសម្ងាត់នៃការ |

| | |
|---|---|
| | សន្ធនានេះ។ ក្រោយការសន្ធនាជននេះ អាចធ្វើកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរដែលត្រូវភ្ជាប់ជាមួយសំណុំរឿង។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៤៥ | "កាលណាជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរ ត្រូវកោះហៅមេធាវីយ៉ាងតិចបំផុត ៥ (ប្រាំ) ថ្ងៃមុន ការសួរចម្លើយ។ ក្នុងថេរវេលានេះ មេធាវីអាចពិនិត្យមើលសំណុំរឿងនៃនីតិវិធី [...]" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២៥៩ | "អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងមេធាវី អាចពិនិត្យមើលសំណុំរឿងរហូតដល់ពេលបើកសវនាការ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវប្រគល់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដល់ក្រឡាបញ្ជីយ៉ាងយូរបំផុត ១ (មួយ) ថ្ងៃ មុនពេលសវនាការ [...]" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣១៩ | "មុនពេលសវនាការ មេធាវីអាចពិនិត្យមើលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីនៃតុលាការនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី [...]" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ២៩ | "ក្នុងករណីណាក៏ដោយ ការសម្រេចចោទប្រកាន់របស់ព្រះរាជអាជ្ញា ត្រូវឱ្យដំណឹងភ្លាមដោយផ្ទាល់ និងជាលាយលក្ខណ៍អក្សរទៅអនីតិជន ហើយប្រសិនបើសមស្របត្រូវឱ្យដំណឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងមេធាវីរបស់អនីតិជន ដើម្បីរៀបចំមធ្យោបាយការពារអនីតិជន។" |

បុគ្គលណា ដែលប្រឈមនឹងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ គួរត្រូវបានផ្តល់ពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីត្រៀមការពារខ្លួនចំពោះបទចោទប្រកាន់ទាំងនោះ។ រយៈពេលដែលថា "គ្រប់គ្រាន់" អាស្រ័យលើប្រភេទ និងភាពស្មុគស្មាញនៃបទចោទប្រកាន់ ចំនួននៃបទចោទប្រកាន់ និងប្រភេទនៃភស្តុតាងព្រមទាំងកត្តាដទៃទៀត។[77] ជាគោលការណ៍ ជនជាប់ចោទចាំបាច់ត្រូវអាចរៀបចំការពារក្តីរបស់ខ្លួនឱ្យបានសមស្របពេលគឺ អាចរៀបចំដើម្បីឆ្លើយតបទៅនឹងភស្តុតាង ការស៊ើបអង្កេតរបស់តំណាងអយ្យការ និងបង្ហាញសាក្សីការពារខ្លួន។ មធ្យោបាយចាំបាច់ក្នុងការរៀបចំការពារខ្លួន រាប់បញ្ចូលទាំងការទទួលបាននូវឯកសារ និងភស្តុតាងនានានៃសំណុំរឿង ដើម្បីឱ្យជនជាប់ចោទបានដឹងពីបទចោទប្រកាន់មកលើខ្លួនបានពេញលេញ ហើយជនជាប់ចោទអាចមានលទ្ធភាពផ្តល់ព័ត៌មានពេញលេញដល់មេធាវីរបស់ខ្លួន។[78] បន្ថែមលើនេះទៀត សិទ្ធិមានមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី ក៏រួមបញ្ចូលទាំងការផ្តល់មធ្យោបាយអំណោយផលដែលអនុញ្ញាតឱ្យជនជាប់ចោទអាចប្រាស្រ័យទាក់ទងដោយមិនបើកចំហឱ្យអ្នកផ្សេងបានដឹង ជាមួយមេធាវីការពារក្តីរបស់ខ្លួន

[77] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ១៣៖ ១៩៨៤ វាក្យខណ្ឌ ៩ https://tbinternet.ohchr.org/_layouts/treatybodyexternal/TBSearch.aspx?Lang=en&TreatyID=8&DocTypeID=11 ("UN HRC សេចក្តីពន្យល់ទូទៅលេខ ១៣")។

[78] UN HRC សេចក្តីពន្យល់ទូទៅលេខ ១៣ វាក្យខណ្ឌ ៩។

ផងដែរ។[79] នៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ ប្រការនេះក៏មានន័យថា ជនជាប់ចោទគួរតែមានសិទ្ធិក្នុងការទទួលបានសេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់សាលាដំបូង និងប្រតិចារឹកនៃសវនាការជំនុំជម្រះ ដើម្បីឱ្យគាត់អាចរៀបចំការពារក្តីរបស់ខ្លួន។

*តួលេខទី ៤៖ សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី*[80]







ថ្វីបើការសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍ ពុំបានផ្តល់ព័ត៌មានដែលចាំបាច់ទាំងអស់ដល់ ម.ស.ម.ក ដើម្បីវាយតម្លៃបានថាតើជនជាប់ចោទមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តីរបស់ខ្លួន ឬពុំមានក៏ដោយ បើយោងតាមព័ត៌មានដែលមាន ម.ស.ម.ក បានកត់សម្គាល់ឃើញជាវិជ្ជមានថា មានការគោរពសិទ្ធិនេះ នៅក្នុងសំណុំរឿងភាគច្រើនលើសលប់។ ម.ស.ម.ក សង្កេតឃើញថាមានតែ ៥% ប៉ុណ្ណោះនៃជនជាប់ចោទនៅសំណុំរឿងដែលបានសង្កេតការណ៍ទាំងអស់ បង្ហាញថាមេធាវីការពារជនជាប់ចោទត្រូវបានចាត់តាំងនៅក្នុងថ្ងៃសវនាការលើបណ្តឹងឧទ្ធរណ៍ ហើយសំណុំរឿងភាគច្រើន គឺសុទ្ធតែមានមេធាវីនៅមុនពេលនោះ។ ខណៈដែលមានការបង្ហាញអំពីការកើនឡើង បើធៀបទៅនឹងឆ្នាំ ២០១៦/២០១៧ ដែលមានតែ ២% នៃជនជាប់ចោទមាននៅក្នុងសំណុំរឿងដែលបានសង្កេតការណ៍ និងខណៈដែលគួរតែមានការចាត់វិធានការរឹងមាំដើម្បីកុំឱ្យមានការចាត់តាំងមេធាវីការពារជនជាប់ចោទនៅថ្ងៃសវនាការក៏ដោយ ម.ស.ម.ក នៅតែគិតថាសិទ្ធិនេះ ជារួម គឺត្រូវបានការពារនៅចំពោះមុខសាលាឧទ្ធរណ៍។ លើសពីនេះទៅទៀត ពុំមានមេធាវីការពារជនជាប់

[79] UN HRC សេចក្តីពន្យល់ទូទៅលេខ ១៣ វាក្យខណ្ឌ ៩។ UN HRC សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣៤។

[80] ទិន្នន័យនេះគឺផ្អែកលើចំនួនជនជាប់ចោទសរុប (៣១៥ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ២១៣ ដែលបានសង្កេតការណ៍។ "មិនពាក់ព័ន្ធ" សំដៅលើសំណុំរឿងដែលជនជាប់ជនមិនមានមេធាវីតំណាង។

ចោទណាមួយលើកឡើងអំពីបញ្ហានៃកង្វះការរៀបចំការពារក្តីឡើយ។ ជារួម ការគោរពសិទ្ធិនេះគឺមិនប្រែប្រួលបើធៀបទៅនឹងឆ្នាំ២០១៦/២០១៧។

### ៣.២. សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ស.ស.ស.ម<br>មាត្រា ៥ | "គ្មានជនណាម្នាក់ ត្រូវទទួលទារុណកម្ម ឬការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោកបានឡើយ។" |
| ក.អ.ស.ព.ន<br>មាត្រា ១៤<br>(៣)(ធ) | "ក្នុងការសម្រេចសេចក្តីចោទប្រកាន់បទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ មិនត្រូវបានបង្ខិតបង្ខំឱ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬសារភាពថាមានពិរុទ្ធ។" |
| រដ្ឋធម្មនុញ្ញ<br>មាត្រា ៣៨ | "ច្បាប់នេះហាមឃាត់មិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។ ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ [...]" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ១៤៥ | "[...] ជនត្រូវចោទអាចត្រូវសួរចម្លើយបានតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយ មិនចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរអាចសួរចម្លើយជន ត្រូវចោទដោយគ្មានវត្តមានរបស់មេធាវី។ និទ្ទេសស្តីអំពីអវត្តមាននេះ ត្រូវចុះនៅក្នុងកំណត់ហេតុសួរចម្លើយជនត្រូវចោទ [...]" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ៣២១ | "[...] ការសារភាពក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរ ត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង។ ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្តនេះ គ្មានតម្លៃជាភស្តុតាងទេ [...]" |
| ច្បាប់ស្តីពីយុត្តិធម៌<br>អនីតិជន<br>មាត្រា ៥ | "គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធនឹងអនីតិជន ត្រូវធានាឱ្យមានការគោរពគោលការណ៍ដូចតទៅ៖ [...] មិនត្រូវប្រើទារុណកម្ម ទណ្ឌកម្ម ឬប្រព្រឹត្តកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក តាមគ្រប់រូបភាពទៅលើរូបកាយ និងផ្លូវចិត្តរបស់អនីតិជនឡើយ [...]" |
| ច្បាប់ស្តីពីយុត្តិធម៌<br>អនីតិជន<br>មាត្រា ៦ | "អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ៖ [...] សិទ្ធិមិនទទួលការបង្ខិតបង្ខំឱ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង [...]" |

មាត្រា ១៤(៣)(ធ) នៃ ក.អ.ស.ព.ន ធានានូវសិទ្ធិ "មិនត្រូវបានបង្ខិតបង្ខំឱ្យផ្ដល់សក្ខីកម្មប្រឆាំងខ្លួនឯង ឬឱ្យសារភាពពីពិរុទ្ធភាព"។[81] សិទ្ធិនេះមានពីរផ្នែក៖ ទីមួយ ជនសង្ស័យ ឬជនត្រូវចោទមិនត្រូវបានបង្ខិតបង្ខំ ឬជំរុញឱ្យផ្ដល់ភស្តុតាងប្រឆាំងខ្លួនឯងឡើយ។ នៅពេលជនសង្ស័យ ឬជនត្រូវចោទសារភាព ការសារភាពនោះ ចាំបាច់ត្រូវធ្វើឡើងដោយពុំមានការបង្ខិតបង្ខំផ្លូវកាយ ឬផ្លូវចិត្តដោយផ្ទាល់ ឬដោយប្រយោលណាមួយឡើយ។[82] និយាយម្យ៉ាងទៀតបានន័យថា ជនសង្ស័យ/ជនត្រូវចោទទទួលបានសិទ្ធិដែលមិនអាចដកហូតបានក្នុងការមិនផ្ដល់ភស្តុតាងដែលអាចត្រូវបានយកទៅប្រើប្រាស់ប្រឆាំងរូបខ្លួន។[83] ប្រសិនបើជនម្នាក់បដិសេធក្នុងការផ្ដល់សក្ខីកម្មប្រឆាំងខ្លួនឯង ឬសារភាពទោសកំហុសទេនោះ ស្ថានភាពដែលចៅក្រមចេញសេចក្ដីសន្និដ្ឋានជាអវិជ្ជមានពីការនៅស្ងៀមនេះ ត្រូវបានហាមឃាត់។[84] ក្នុងករណីរបស់អនីតិជន ច្បាប់នេះមានលក្ខណៈកាន់តែទូលាយថែមទៀត៖ អនីតិជនមិនត្រូវបានបង្ខិតបង្ខំ "ឱ្យផ្ដល់សក្ខីកម្ម"ឡើយ។[85] សិទ្ធិនេះក៏ត្រូវបានធានាតាមមាត្រាទាំងអស់នៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ជាពិសេស គឺមាត្រា ១៥[86] ពីព្រោះសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាពនេះគ្របដណ្ដប់លើការហាមឃាត់ដាច់ខាតប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។

[81] ក៏សូមមើលផងដែរអនុសញ្ញាស្ដីពីសិទ្ធិកុមារ មាត្រា ៤០(២)(ខ)(iv)។

[82] UN HRC សេចក្ដីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៤១។ សូមមើលផងដែរ គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ *សំណុំរឿង Deolall ទល់នឹង Guyana* សេចក្ដីសម្រេចលេខ ៩១២/២០០០ នៅក្នុងឯកសាររបស់ អ.ស.ប លេខ CCPR/C/៨២/D/៩១២/២០០០ ឆ្នាំ២០០៤ វាក្យខណ្ឌ ៥.១ http://juris.ohchr.org/Search/Details/1149។ UN HRC *សំណុំរឿង Singarasa ទល់នឹងប្រទេសស្រីលង្កា*, សេចក្ដីសម្រេចលេខ ១០៣៣/២០០១ នៅក្នុងឯកសាររបស់ អ.ស.ប លេខ CCPR/C/៨១/D/១០៣៣/២០០ ឆ្នាំ២០០៤ វាក្យខណ្ឌ ៧.៤http://juris.ohchr.org/Search/Details/1125។ UN HRC *សំណុំរឿង Khuseynova and Butaeva ទល់នឹងប្រទេសតាជីគីស្ថាន* សេចក្ដីសម្រេចលេខ ១២៦៣/២០០៤ និង ១២៦៤/២០០៤ នៅក្នុងឯកសាររបស់ អ.ស.ប CCPR/ C/៩៤/D/១២៦៣–១២៦៤/២០០៤ ឆ្នាំ២០០៨ វាក្យខណ្ឌ ៨.៣ http://juris.ohchr.org/Search/Details/1457។

[83] ក.អ.ស.ព.ន, មាត្រា ១៤(៣)(ធ) សូមមើលផងដែរ អនុសញ្ញាស្ដីពីសិទ្ធិកុមារ មាត្រា ៤០(២)(ខ)(iv)។

[84] តុលាការសិទ្ធិមនុស្សអឺរ៉ុប ("ECtHR") សំណុំរឿង Condron ទល់នឹងប្រទេសចក្រភពអង់គ្លេស ចុះនៅឆ្នាំ ២០០០ វាក្យខណ្ឌ ៥៦ http://hudoc.echr.coe.int/eng?i=001-58798 ECtHR សំណុំរឿង *Beckles v.* ប្រទេសចក្រភពអង់គ្លេស ចុះនៅឆ្នាំ ២០០០ វាក្យខណ្ឌ ៥៨ http://hudoc.echr.coe.int/eng?i=001-60672។

[85] អនុសញ្ញាស្ដីពីសិទ្ធិកុមារ, មាត្រា ៤០(២)(ខ)(iv)។

[86] អនុសញ្ញាស្ដីពីការប្រឆាំងទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប ចែងថា ("CAT") មាត្រា ១៥៖ *"រដ្ឋភាគី ត្រូវធានាថា ឯកសាររាយការណ៍ទាំងឡាយ ដែលបង្កើតឡើងបានមកពីអំពើទារុណកម្ម មិនត្រូវយកមកសំអាងជាធាតុនៃភស្តុតាងក្នុងនីតិវិធីណាមួយឡើយ លើកលែងតែឯកសាររាយការណ៍នោះ ត្រូវបានធ្វើសម្រាប់ជាភស្តុតាងប្រឆាំងនឹងជនជាប់ចោទនៅអំពើទារុណកម្ម។"* http://cambodia.ohchr.org/sites/default/files/Treaty/CAT-KH.pdf។

### *តួលេខទី ៥៖ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព*[87]

តើមានអ្វីមួយដែលបង្ហាញថា ជនជាប់ចោទត្រូវបានសួរចម្លើយដោយគ្មានវត្តមានមេធាវីដែរឬទេ?




តើមានអ្វីមួយដែលបង្ហាញថា ជនជាប់ចោទត្រូវបានគំរាមកំហែងឱ្យសារភាព ដែរឬទេ?




តើមានអ្វីមួយដែលបង្ហាញថា ជនជាប់ចោទទទួលរងអំពើហិង្សា ឬទារុណកម្មបង្ខំឱ្យសារភាព ដែរឬទេ?




* ទាំងជនជាប់ចោទ និងមេធាវីពុំមានវត្តមាននៅក្នុងសវនាការ ហេតុនេះ ពុំមាននរណាលើកបញ្ហានេះឡើង។

ក្នុងអំឡុងពេលធ្វើរបាយការណ៍ មានការកត់សម្គាល់ថា មានតែជនជាប់ចោទម្នាក់ប៉ុណ្ណោះ ក្នុងចំណោម ៣១៥ នាក់ ដែលបានលើកឡើងថា ពួកគេត្រូវបានស្តាប់ចម្លើយដោយគ្មានវត្តមានមេធាវី។ ជនជាប់ចោទចំនួន១០ នាក់បានលើកឡើងថា ពួកគេបានរងការគំរាមកំហែងឱ្យសារភាព (៣%) ខណៈដែលជនជាប់ចោទចំនួន ២១ នាក់ផ្សេងទៀត (៧%) ដែលពួកគេមួយចំនួនក៏ជាអ្នកដែលបានលើកឡើងថាទទួលរងការគំរាមកំហែងចំពោះពួកគេនោះ បានបញ្ជាក់ទៀតថា ពួកគេទទួលរងការប្រើអំពើហិង្សា ឬទារុណកម្ម ដើម្បីឱ្យពួកគេសារភាពចំពោះបទល្មើសដែលត្រូវបានចោទប្រកាន់ ក្នុងអំឡុងពេលសាកសួរដោយនគរបាលយុត្តិធម៌។ ជា

[87] ទិន្នន័យនេះគឺផ្អែកលើចំនួនជនជាប់ចោទសរុប (៣១៥ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ២១៣ ដែលបានសង្កេតការណ៍។

រួម នៅពេលប្រៀបធៀបជាមួយនឹងឆ្នាំ២០១៦/២០១៧ និន្នាការគឺវិជ្ជមាន ដោយហេតុថាសំណុំរឿងដែលពុំមានការបង្ខិតបង្ខំឱ្យសារភាពបានកើនឡើងចាប់ពី ៨៨% ដល់ ៩៥%។ ខណៈដែលនេះមានន័យថាសិទ្ធិនេះត្រូវបានចាត់ទុកថាត្រូវបានគោរពនៅក្នុងរបាយការណ៍នេះ ដោយហេតុការលើកឡើងថាមានការគំរាមកំហែង ឬអំពើហិង្សា ចាំបាច់ត្រូវតែមានវិធានការបន្ទាន់ដើម្បីធានាថាការសារភាពគឺធ្វើឡើងដោយសេរី មានការជូនដំណឹងជាមុន និងយល់ព្រមជាមុន និងដោយមិនមានកាបង្ខិតបង្ខំឡើយ។

ខណៈដែលចំនួនសំណុំរឿងដែលមានសញ្ញាណបញ្ជាក់អំពីការបង្ខិតបង្ខំ ឬការធ្វើទារុណកម្មនៅអំឡុងពេលស្តាប់ចម្លើយ (លើផ្លូវចិត្ត ឬផ្លូវកាយ) មានចំនួនតិចតួចក្តី ប៉ុន្តែនេះជាបញ្ហាគួរឱ្យព្រួយបារម្ភយ៉ាងខ្លាំង។ ទោះជានៅក្នុងសំណុំរឿងភាគច្រើនដែលជនជាប់ចោទ ឬមេធាវីការពារជនជាប់ចោទបានលើកឡើងអំពីបញ្ហាទាក់ទងនឹងការសារភាពក៏ដោយ ក៏ចៅក្រមនៅតែតម្កល់សាលក្រមដែលសម្រេចឱ្យជនជាប់ចោទមានពិរុទ្ធភាពនៅដដែល។ សាលាឧទ្ធរណ៍ចាំបាច់ត្រូវស៊ើបអង្កេតលើអំណះអំណាងទាំងអស់នេះឱ្យសព្វជ្រុងជ្រោយ។ ប្រសិនបើការលើកឡើងអំពីការបង្ខិតបង្ខំណាមួយ ត្រូវបានបង្ហាញជាភស្តុតាងថាជាការពិតក្រោយការស៊ើបអង្កេត ចៅក្រមមានកាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការចេញសេចក្តីសម្រេច ឱ្យរាល់ភស្តុតាងក្រោមការសារភាពដែលបានធ្វើឡើងនោះ ជាភស្តុតាងមិនអាចទទួលយកបានក្នុងតុលាការ និងមានមូលដ្ឋានសមហេតុផលដើម្បីជឿជាក់ថាការសារភាពនោះត្រូវបានធ្វើឡើងដោយការបង្ខិតបង្ខំ។ ម្យ៉ាងទៀត ថ្វីបើបញ្ហានេះគួរត្រូវបានដោះស្រាយក្នុងដំណាក់កាលស៊ើបសួរក្តីក៏ចៅក្រមសាលាឧទ្ធរណ៍ចាំបាច់ត្រូវរក្សាការប្រុងប្រយ័ត្ន និងធានាថា រាល់អំណះអំណាងស្តីពីការបង្ខិតបង្ខំដែលពុំត្រូវបានដោះស្រាយក្នុងអំឡុងពេលមុនសវនាការនោះ ត្រូវបានស៊ើបអង្កេតសព្វជ្រុងជ្រោយ មុនពេលសវនាការត្រូវបានអនុញ្ញាតឱ្យបន្តទៅមុខទៀត។

## ៣.៣. សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ក.អ.ស.ព.ន មាត្រា ១៤(១) | [...] ប៉ុន្តែការចេញសាលក្រមទាំងអស់អំពីរឿងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ត្រូវប្រកាសជាសាធារណៈ លើកលែងតែផលប្រយោជន៍អនីតិជន តម្រូវផ្សេងពីនេះ ឬរឿងក្តីអំពីទំនាស់គ្រួសារ ឬអាណាព្យាបាលរបស់កុមារ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣១៧ | "នៅក្នុងគ្រប់ករណីទាំងអស់សាលក្រមត្រូវប្រកាសនៅពេលសវនាការជាសាធារណៈ។" |
| ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៧ | "[...] នៅគ្រប់ករណីទាំងអស់ សាលក្រម និងសាលដីកាតុលាការ ត្រូវប្រកាសនៅក្នុងសាលសវនាការដែលបើកជាសាធារណៈ [...]" |

សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ គឺជាចំណុចគន្លឹះដើម្បីធានាឱ្យបាននូវតម្លាភាព និងគណនេយ្យភាព។ ប្រជាពលរដ្ឋគ្រប់រូបត្រូវតែអាចមើលឃើញថាយុត្តិធម៌ពិតជាត្រូវបានផ្តល់ជូនពិតប្រាកដមែន ហើយការអនុញ្ញាតឱ្យសាធារណជនចូលរួមនៅក្នុងសវនាការ ក៏នឹងរឹតត្បិតសមត្ថភាពរបស់ចៅក្រមក្នុងការប្រព្រឹត្តតាមតែចិត្តរបស់ខ្លួនផងដែរ។ ប្រការសំខាន់មួយទៀត គឺការទទួលបានព័ត៌មានផ្លូវច្បាប់ ដោយហេតុថាព័ត៌មានទាំងនេះនឹងអាចឱ្យសាធារណជនដឹងអំពីប្រភេទនៃឥរិយាបថដែលបានអនុញ្ញាត ឬហាមឃាត់ដោយច្បាប់។

ផែនការយុទ្ធសាស្ត្រជាតិរបស់រដ្ឋាភិបាល ឆ្នាំ២០១៤-២០១៨ មានគោលបំណងចង់ "ដាក់ឱ្យប្រើប្រាស់នូវទិន្នន័យបញ្ជីតុលាការតាមប្រព័ន្ធព័ត៌មាន" និងលើកកម្ពស់លទ្ធភាពទទួលបានព័ត៌មានប្រព័ន្ធយុត្តិធម៌ រួមបញ្ចូលទាំង ព័ត៌មានអំពីសេចក្តីសម្រេចរបស់តុលាការ និងរបាយការណ៍ស្តីពីដំណើរការនីតិវិធី របាយការណ៍រដ្ឋបាលតាមពេលកំណត់ និងព័ត៌មានរដ្ឋបាលទាក់ទងនឹងសំណុំរឿងដែលមិនទាន់ជំនុំជម្រះ ដូចជាព័ត៌មានអំពីស្ថានភាព និងកាលវិភាគសវនាការ" ផងដែរ។[88] ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែង ថ្វីបើមានកិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងក្តី ឧទាហរណ៍ ដើម្បីផ្សព្វផ្សាយកាលវិភាគសវនាការតុលាការជាដើមនោះ ប៉ុន្តែព័ត៌មានសំខាន់ៗ ជាពិសេស សេចក្តីសម្រេចរបស់តុលាការ ភាគច្រើននៅតែមិនទាន់ផ្សព្វផ្សាយជាសាធារណៈនៅឡើយ។ ថ្វីបើក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ ធ្វើការផ្សព្វផ្សាយជាប្រចាំនូវសេចក្តីសម្រេចរបស់ខ្លួនក្តី[89] ប៉ុន្តែសេចក្តីសម្រេចរបស់តុលាការផ្សេងទៀត ភាគច្រើននៅតែមិនអាចរកបានជាសាធារណៈនៅឡើយ។ កង្វះលទ្ធភាពទទួលបានព័ត៌មាននេះ ធ្វើឱ្យការអនុវត្តយុទ្ធសាស្ត្រមិនអាចទៅរួច និងរារាំងដល់មេធាវីក្នុងការការពារក្តីប្រកបដោយប្រសិទ្ធភាពទៀតផង។ ទោះជាយ៉ាងណាក៏ដោយ តាមការសន្យារបស់ខ្លួន សាលាឧទ្ធរណ៍បានផ្តួចផ្តើមធ្វើសេចក្តីសម្រេចជាមួយនឹងការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ("ការិយាល័យឧត្តមស្នងការ") នៅកម្ពុជាអំពីការផ្សព្វផ្សាយសេចក្តីសម្រេច។[90] តម្លាភាពកាន់តែល្អប្រសើរនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត នឹងនាំឱ្យមានការធ្វើសេចក្តីសម្រេចចិត្តកាន់តែស៊ីសង្វាក់ មានភាពប្រាកដប្រជាផ្លូវច្បាប់ និងបង្កើនការជឿជាក់របស់សាធារណៈមកលើឯករាជ្យភាពរបស់ប្រព័ន្ធយុត្តធម៌"។[91]

---

[88] "ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិឆ្នាំ ឆ្នាំ២០១៤-២០១៨ រាជរដ្ឋាភិបាល វាក្យខណ្ឌ ២.១៦ http://cdc-crdb.gov.kh/cdc/documents/NSDP_2014-2018.pdf។

[89] "រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា" គេហទំព័រ http://www.ccc.gov.kh។

[90] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ("UNSRSHRC") ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ វាក្យខណ្ឌ ៨១។

[91] "*តម្លាភាពកាន់តែល្អប្រសើរនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់ប្រព័ន្ធយុត្តិធម៌ គួរតែនាំទៅរកភាពប្រាកដប្រជាផ្លូវច្បាប់កាន់តែល្អប្រសើរ ការធ្វើសេចក្តីសម្រេចចិត្តកាន់តែស៊ីសង្វាក់លើកស្ទួតាង និងការអនុវត្តច្បាប់ ហើយដូច្នេះនឹងពង្រឹងទស្សនៈរបស់សាធារណៈមកលើឯករាជ្យភាពរបស់ប្រព័ន្ធយុត្តធម៌*" "សេចក្តីថ្លែងបញ្ចប់បេសកកម្ម" UNSRSHRC ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨, http://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=22819&LangID=E ("សេចក្តីថ្លែងបញ្ចប់បេសកកម្មរបស់ UNSRSHRC ចុះនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨")។

នៅក្នុងខែមីនា ឆ្នាំ២០១៨ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិមនុស្សនៅប្រទេសកម្ពុជាបានជួបជាមួយនឹងមន្ត្រីតុលាការ និងបានកត់សម្គាល់ឃើញថាសាលាឧទ្ធរណ៍បានពង្រឹងលើការងារសេចក្ដីសម្រេចមានសំអាងហេតុច្បាស់លាស់[92] និងបានចូលរួមពិភាក្សាអំពីសេចក្ដីសម្រេចបោះពុម្ពផ្សាយផងដែរ បើទោះបីជាមិនទាន់មានការវិវឌ្ឍកើតមានពីភាគីនេះក្ដី។[93]

*តួលេខទី ៦៖ សិទ្ធិទទួលបានការប្រកាសសេចក្ដីសម្រេចជាសាធារណៈ* [94]




នៅគ្រប់សំណុំរឿងទាំងអស់ដែលយើងទទួលបានព័ត៌មាន សិទ្ធិទទួលបានការប្រកាសសេចក្ដីសម្រេចជាសាធារណៈត្រូវបានគោរព។

## ៣.៤. ការហាមឃាត់ប្រឆាំងនឹងការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ស.ស.ស.ម<br>មាត្រា ១១(២) | "គ្មានជនណាម្នាក់ត្រូវបានផ្ដន្ទាទោសពីបទល្មើសព្រហ្មទណ្ឌដោយអំពើណាមួយ ឬការមិនប្រតិបត្តិតាមណាមួយដែលមិនចាត់ជាបទល្មើសព្រហ្មទណ្ឌ ក្រោមច្បាប់ជាតិ ឬអន្តរជាតិនៅខណៈពេលដែលបទល្មើសបានប្រព្រឹត្តឡើង។ គ្មានទោសបញ្ញត្តិណាមួយត្រូវបានគេយកមកដាក់បង្ខំទៅលើជនណាម្នាក់ ឱ្យធ្ងន់ជាងទោសបញ្ញត្តិដែលបានអនុវត្តនៅខណៈពេលដែលបទល្មើសព្រហ្មទណ្ឌនោះបានប្រព្រឹត្តឡើយ។ |
| ក.អ.ស.ព.ន<br>មាត្រា ១៥ | "គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើ ឬការខកខានណាមួយដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ក្នុង |

[92] របាយការណ៍របស់ UNSRSHRC ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ វាក្យខណ្ឌ ៨១។

[93] របាយការណ៍របស់ UNSRSHRC ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ វាក្យខណ្ឌ វាក្យខណ្ឌ ១៤ (ឃ)។

[94] ទិន្នន័យនេះគឺផ្អែកលើចំនួនជនជាប់ចោទសរុប (៣១៥ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ២១៣ ដែលបានសង្កេតការណ៍។ "មិនដឹង" សំដៅលើសំណុំរឿងមិនទទួលបានព័ត៌មាន ឬសំណុំរឿងដែលមិនត្រូវបានតាមដានបន្តដោយសារអ្នកសង្កេតការណ៍សវនាការមិនមានវត្តមាននៅថ្ងៃប្រកាសសាលដីកា។

| | |
|---|---|
| | ខណៈពេលប្រព្រឹត្តនោះឡើយ។ ដូចគ្នានេះ មិនត្រូវដាក់ទោសឱ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងខណៈពេលប្រព្រឹត្តបទល្មើសឡើយ។ ប្រសិនបើក្រោយពីការប្រព្រឹត្តបទល្មើសហើយ ច្បាប់បានបញ្ញត្តិឱ្យមានការដាក់ទោសស្រាលជាងមុន ជនល្មើសត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងមុន។ គ្មានបញ្ញត្តិណាមួយក្នុងមាត្រានេះប្រឆាំងនឹងការជំនុំជម្រះក្តី ឬការផ្តន្ទាទោសដល់ជនណាម្នាក់ចំពោះអំពើ ឬការខកខានណាមួយ ដែលជននោះបានប្រព្រឹត្ត ក្នុងខណៈពេលដែលអំពើឬការខកខាននោះ ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមគោលការណ៍ទូទៅនៃច្បាប់ ដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ។" |
| ក្រមព្រហ្មទណ្ឌ មាត្រា ៣ | "មានតែអំពើដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះ មានចែងនៅក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបផ្តន្ទាទោសព្រហ្មទណ្ឌបាន។" |
| ក្រមព្រហ្មទណ្ឌ មាត្រា ១០ | "បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម។ ប៉ុន្តែការផ្តន្ទាទោសជាស្ថាពរ ហើយនោះ ត្រូវអនុវត្តទោះបីជាទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ។ បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាង នឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ។" |

គោលការណ៍ជាមូលដ្ឋាននៃច្បាប់ព្រហ្មទណ្ឌ គឺថាពុំមានជនណាម្នាក់ត្រូវបានរកឃើញពីពិរុទ្ធភាពនៃបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬការខកខានដែលមិនបានបង្កើតជាបទល្មើសព្រហ្មទណ្ឌ ពេលដែលអំពើ ឬការខកខាននោះ បានកើតឡើងឡើយ។ ស្រដៀងគ្នានេះ ទោសធ្ងន់ជាងមិនអាចអនុវត្តក្រៅតែពីទោសដែលត្រូវអនុវត្តនៅពេលដែលបទល្មើសព្រហ្មទណ្ឌនោះ ត្រូវបានប្រព្រឹត្តឡើយ។

*តួលេខទី ៧៖ ការហាមឃាត់ប្រឆាំងនឹងការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ*

| ទិន្នន័យ | មាន | | គ្មាន | |
|---|---|---|---|---|
| | ចំនួន | % | ចំនួន | % |
| តើជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទល្មើសស្ថិតក្នុងច្បាប់ជាធរមាននៅពេលប្រព្រឹត្តបទល្មើសដែរឬទេ ? * | ៣១៥ | ១០០ | ០ | ០ |

* ទិន្នន័យនេះផ្អែកលើជនជាប់ចោទសរុប (៣១៥ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿង ២១៣ សំណុំរឿងដែលបានសង្កេតការណ៍។

ពុំមានករណីណាមួយដែលបានសង្កេតបានបង្ហាញថា ច្បាប់ដែលចោទប្រកាន់លើជនជាប់ចោទណាមួយពុំមានអានុភាពអនុវត្តនៅពេលដែលបទល្មើសនោះបានកើតឡើងនោះទេ។ ហេតុនេះការរកឃើញរបស់

ម.ស.ម.ក បង្ហាញថា ការការពារប្រឆាំងនឹងការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ត្រូវបានការពារ។ និន្នាការនេះ បានកើតឡើងចាប់តាំងពីឆ្នាំ២០១៤ មកម្លេះ។

## ៣.៥. ការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែល

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ក.អ.ស.ព.ន<br>មាត្រា ១៤ (៧) | "គ្មានជនណាម្នាក់ត្រូវយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសារជាថ្មីឡើងវិញចំពោះបទល្មើសដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗរួចហើយ។" |
| ក្រមព្រហ្មទណ្ឌ<br>មាត្រា ២៣ | "ពុំមានការចោទប្រកាន់ណាមួយ អាចប្រព្រឹត្តប្រឆាំងនឹងបុគ្គលណាម្នាក់ ដែលត្រូវបានជំនុំជម្រះជាស្ថាពរនៅឯបរទេសចំពោះអំពើល្មើសដដែល ហើយដែលក្នុងករណីការផ្តន្ទាទោស បុគ្គលនោះបានបង្ហាញថា ខ្លួនបានអនុវត្តទោសរបស់ខ្លួនរួចហើយ ឬក៏ទោសត្រូវបានរលត់ដោយការផុតអាជ្ញាយុកាល។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ១២ | "ដោយអនុវត្តតាមគោលការណ៍*អាជ្ញាអស់ជំនុំ* ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ។" |

ការវិច្ឆ័យទោសពីរដងចំពោះអំពើដដែល ឬគោលការណ៍ *អាជ្ញាអស់ជំនុំ* (ពោលគឺថា "បានវិនិច្ឆ័យរួចហើយ") សំដៅលើសិទ្ធិរបស់បុគ្គលដែលមិនត្រូវឱ្យមានការជំនុំជម្រះលើសពីម្តងចំពោះអំពី ឬបទល្មើសដដែល។ ករណីនេះ កំណត់ថាសេចក្តីសម្រេចស្ថាពររបស់តុលាការ ទោះបីជាការលើកលែង ឬការផ្តន្ទាទោសជនជាប់ចោទក្តី នឹងក្លាយជារបាំងហាមចំពោះការចោទប្រកាន់បន្ថែមទៀតទៅលើអំពើល្មើសដដែលនោះ។ មានអត្ថប្រយោជន៍ជាច្រើន សម្រាប់ទាំងបុគ្គលជាជនជាប់ចោទ និងសង្គមជារួមក្នុងការទទួលយកសេចក្តីសម្រេចចុងក្រោយនេះ រួមទាំងការផ្តល់ភាពច្បាស់លាស់ផ្នែកច្បាប់ និងបង្ការនូវភាពខ្ជះខ្ជាយធនធានផ្នែកច្បាប់នៅពេលដែលសេចក្តីសម្រេចត្រូវបានធ្វើរួចរាល់ហើយនោះ។

### *តួលេខទី ៨៖ ការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែល* [95]

**តើមានអ្វីមួយដែលបង្ហាញថាជនជាប់ចោទត្រូវបានជំនុំជម្រះ និងដាក់ទោសចំពោះបទល្មើសនេះ ពីមុនដែរឬទេ?**




ទោះបីនៅមានក្ដីបារម្ភក៏ដោយ ប៉ុន្តែនេះគឺជាចំណុចគួរឱ្យកត់សម្គាល់ថា មានតែមួយករណីប៉ុណ្ណោះក្នុងចំណោមជនជាប់ចោទចំនួន ៣១៥ នាក់ ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ២១៣ សំណុំរឿងដែលបានសង្កេតការណ៍ដោយ ម.ស.ម.ក ធ្លាប់បានជំនុំជម្រះ និងវិនិច្ឆ័យទោសចំពោះអំពើដដែលក្នុងពេលអតីតកាល នេះបើតាមការលើកឡើងរបស់មេធាវីការពារជនជាប់ចោទ។ ដូច្នេះសិទ្ធិនេះត្រូវបានធានា។ គួរឱ្យកត់សម្គាល់ផងដែរថា និន្នាការនេះ បានកើតឡើងចាប់តាំងពីឆ្នាំ២០១៤ មកម្ល៉េះ។

[95] ទិន្នន័យនេះគឺផ្អែកលើចំនួនជនជាប់ចោទសរុប (៣១៥ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ២១៣ ដែលបានសង្កេតការណ៍។

## ៤. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលមិនទាន់ត្រូវបានគោរពពេញលេញ

នៅមានចំណុចខ្វះខាតក្នុងការធានាអនុវត្តសិទ្ធិមួយចំនួន និង/ឬការអនុវត្តនៅពុំទាន់បានពេញលេញនៅឡើយ ហេតុដូច្នេះអាចប៉ះពាល់ដល់សិទ្ធិបុគ្គលក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

| សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មិនទាន់ត្រូវបានគោរពពេញលេញនៅសាលាឧទ្ធរណ៍ |
|---|
| • សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ |
| • សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ |
| • សិទ្ធិមានមេធាវី និងមានវត្តមាននៅក្នុងសវនាការ |
| • សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស |
| • សិទ្ធិបង្ហាញភស្តុតាង |
| • សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ |
| • សិទ្ធិរបស់អនីតិជន |

### ៤.១. សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ក.អ.ស.ព.ន មាត្រា ១៤ (១) | "ក្នុងការសម្រេចសេចក្តីចោទប្រកាន់បទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ឬសិទ្ធិរបស់ខ្លួន ជនគ្រប់រូបត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួនដោយសមធម៌ និងជាសាធារណៈ [...]" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៩២ | "ការពិភាក្សាដេញដោលប្រព្រឹត្តទៅនៅពេលសវនាការជាសាធារណៈ។" |
| ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៧ | "ការពិភាក្សាដេញដោលប្រព្រឹត្តទៅនៅពេលសវនាការជាសាធារណៈ។" |

មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការសម្រេចថាមានពិរុទ្ធភាព ឬគ្មានទោសនៅក្នុងសវនាការជាសាធារណៈ លើកលែងតែក្នុងករណីពិសេសជាក់លាក់មួយចំនួន ឧទាហរណ៍៖ នៅពេលដែលតុលាការយល់ឃើញថា សវនាការជាសាធារណៈនឹងបង្កឱ្យមាន *"ការប៉ះពាល់ធ្ងន់ធ្ងរ"* ដល់សណ្តាប់ធ្នាប់សង្គម ជនជាប់ជនជាអនីតិ

ជន ឬដល់ទំនៀមទម្លាប់ដ៏ល្អប្រពៃ។[96] សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈពាក់ព័ន្ធនឹងធាតុផ្សំមួយចំនួនៈ សវនាការគួរតែបើកចំហជាទូទៅសម្រាប់សាធារណជន និងត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ព័ត៌មានពីទីកន្លែង និងកាលបរិច្ឆេទនៃសវនាការ គួរតែអាចរកបានជាសាធារណៈ ហើយគួរតែមានសម្ភារៈរូបវន្តគ្រប់គ្រាន់ ដើម្បីធានាការចូលរួមពីសាធារណជន។[97]

### *តួលេខទី ៩៖ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ*




ការជូនដំណឹងអំពីសវនាការ ជាវិធីសាស្ត្រមួយដើម្បីលើកកម្ពស់ការយល់ដឹងអំពីសវនាការជាសាធាណៈ តាមរយៈការផ្តល់ដំណឹងជូនដល់សាធារណជន ថាតើនរណាខ្លះដែលត្រូវបានអនុញ្ញាតឱ្យចូលទៅក្នុងបន្ទប់សវនាការ ឬសវនាការណាមួយដែលនឹងមាន។ នៅក្នុងសំណុំរឿងមួយ មានសាធារណជនម្នាក់ត្រូវបានរាំងក្នុងការចូលរួមនៅក្នុងបន្ទប់សវនាការ នោះគឺជាព្រះសង្ឃ ត្រូវជាបងប្អូនរបស់ជនជាប់ចោទ ដែលត្រូវបាននិមន្តឱ្យចាកចេញពីបន្ទប់សវនាការដោយប្រធានសវនាការ ដែលបានលើកឡើងថាគឺជា "ការមិនល្អ" សម្រាប់ព្រះសង្ឃមាន

[96] មាត្រា ៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថាប្រសិនបើតុលាការយល់ឃើញថាសាធារណភាពបង្កឱ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬដល់ទំនៀមទម្លាប់ នោះតុលាការតាមសេចក្តីសម្រេចមានសំអាងហេតុ អាចបង្គាប់ឱ្យការពិភាក្សាដេញដោលទាំងស្រុង ឬមួយផ្នែកប្រព្រឹត្តិទៅជាសម្ងាត់ ប៉ុន្តែតុលាការសម្រេចតាមសាលក្រមមួយដាច់ដោយឡែកពីសាលក្រមអង្គសេចក្តី ឬតាមសេចក្តីសម្រេចពិសេសនៃសាលក្រមលើអង្គសេចក្តី។ មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយបញ្ញត្តិថា សារព័ត៌មាន និងសាធារណជនមិនអាចចូលរួមទាំងស្រុង ឬផ្នែកមួយនៃសវនាការសម្រាប់ផលប្រយោជន៍នៃ "*ទំនៀមទម្លាប់ល្អ សណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិក្នុងសង្គមប្រជាធិបតេយ្យ*" ដែលថាការធ្វើជាសាធារណៈនឹងនាំឱ្យខូចខាតដល់ផលប្រយោជន៍យុត្តិធម៌ ឬនៅពេលផលប្រយោជន៍នៃជីវិតរបស់គូភាគីតម្រូវឱ្យធ្វើដូច្នេះ។ មាត្រា ៤៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនចែងថា ការពិភាក្សាដេញដោល និងការប្រកាសសាលក្រមរឿងក្តីអនីតិជន ត្រូវធ្វើឡើងក្នុងសវនាការជាអសាធារណៈ។

[97] UN HRC សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ២៨ បានកំណត់ថា៖ តុលាការត្រូវតែជូនដំណឹងអំពីពេលវេលា និងទីកន្លែងនៃសវនាការផ្ទាត់មាត់ដល់សាធារណជន ព្រមទាំងផ្តល់មធ្យោបាយគ្រប់គ្រាន់សម្រាប់ការចូលរួមរបស់សាធារណជន។ HRC CCPR *សំណុំរឿង Van Meurs ទល់នឹងប្រទេសហូឡង់ដ៍* សេចក្តីសម្រេចលេខ ២១៥/១៩៨៦ នៅក្នុងឯកសាររបស់ អ.ស.ប លេខ CCPR/C/39/D/215/1986, ឆ្នាំ១៩៩០ វាក្យខណ្ឌ ៦.២ http://juris.ohchr.org/Search/Details/311។

វត្តមាននៅក្នុងបន្ទប់សវនាការ។ ចាប់តាំងពីឆ្នាំ២០១៤ មក កង្វះការជូនដំណឹងអំពីសវនាការ បានក្លាយជាបញ្ហាមួយ ហើយបញ្ហានេះចាំបាច់ត្រូវតែមានវិធានការរឹងមាំដើម្បីដោះស្រាយចំណុចខ្វះខាតទាំងនេះ។

នៅក្នុងខែមេសា ឆ្នាំ២០១៧ អនុប្រធានសាលាឧទ្ធរណ៍[98] បានយល់ស្របថា ពិតជាមានកង្វះខាតចំពោះការបិទផ្សាយការជូនដំណឹងដល់សាធារណជនពាក់ព័ន្ធនឹងកាលវិភាគរបស់តុលាការមែន និងបានជូនដំណឹងដល់ ម.ស.ម.ក ថាសាលាឧទ្ធណ៍នឹងចាត់វិធានការ ដើម្បីធ្វើឱ្យការទទួលបានព័ត៌មានទាក់ទងនឹងសវនាការមានការមានភាពប្រសើរឡើងសម្រាប់សាធារណជន ប៉ុន្តែនៅក្នុងអំឡុងពេលធ្វើរបាយការណ៍ ពុំមានការបិទផ្សាយដំណឹងជាសាធារណៈអំពីសវនាការនៅខាងក្រៅបន្ទប់សវនាការឡើយ។ ក្នុងកិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងភាគីសាលាឧទ្ធរណ៍អំពីសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ភាគីសាលាឧទ្ធរណ៍បានលើកឡើងថាសាលាឧទ្ធរណ៍កំពុងរៀបចំឱ្យមានការបិទផ្សាយកម្មវិធី សវនាការនេះ តែក៏បានលើកឡើងថា សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈគឺសម្រាប់តែភាគីនៃរឿងក្តីតែប៉ុណ្ណោះ ហើយការបិទផ្សាយកម្មវិធីសវនាការនាំឱ្យមានការបំពានសិទ្ធិបុគ្គល ដែលឈានដល់ការរំលោភលើសិទ្ធិសន្មតទុកជាមុនថាគ្មានទោស មិនតែប៉ុណ្ណោះវាត្រូវចំណាយថវិកាច្រើនសម្រាប់ដំណើរការកិច្ចការនេះ ហើយមិនមានក្របខ័ណ្ឌច្បាប់ណាមួយតម្រូវឱ្យតុលាការបិទកម្មវិធីសវនាការនេះទេ។[99] ទោះជាមានការលើកឡើងបែបនេះក្តី តែយោងតាមសេចក្តីពន្យល់ទូទៅរបស់អង្គការសហប្រជាជាតិលេខ ៣២ បានតម្រូវថា តុលាការត្រូវតែជូនដំណឹងអំពីពេលវេលា និងទីកន្លែងនៃសវនាការផ្ទាល់មាត់ដល់សាធារណជន ព្រមទាំងផ្តល់មធ្យោបាយគ្រប់គ្រាន់សម្រាប់ការចូលរួមរបស់សាធារណជន។[100]

## ៤.២. សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ក.អ.ស.ព.ន មាត្រា ១៤ (៣)(ក) | "ក្នុងការសម្រេចសេចក្តីចោទប្រកាន់បទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ត្រូវបានព័ត៌មានភ្លាមៗ និងដោយលម្អិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន ជាភាសាដែលជននោះចេះ។" |
| ក.អ.ស.ព.ន មាត្រា ១៤(៣)(ច) | "ក្នុងការសម្រេចសេចក្តីចោទប្រកាន់បទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ត្រូវទទួល |

[98] ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៨ ក្រុមការងារគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌បានជួបជាមួយអនុប្រធានសាលាឧទ្ធរណ៍ ឯកឧត្តម ប្លង់ សំណាង ឯកឧត្តម ញូង ធុល ព្រមទាំងអគ្គលេខាធិការរងរដ្ឋបាល លោកស្រី ស្រេង សូយ៉េត ដើម្បីពិភាក្សាលើរបកគំឃើញនៅក្នុងរបាយការណ៍ ឆ្នាំ២០១៦/២០១៧។

[99] នៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១៩ ម.ស.ម.ក បានជួបជាមួយប្រធាន អនុប្រធានទាំងអស់ អគ្គព្រះរាជអាជ្ញា តំណាងចៅក្រម ព្រមទាំងអគ្គលេខាធិការរដ្ឋបាលនៅសាលាឧទ្ធរណ៍ ដើម្បីពិភាក្សាលើរបកគំហើញនៅក្នុងរបាយការណ៍នេះ។

[100] UN HRC សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ២៨។

| | |
|---|---|
| | បានអ្នកបកប្រែភាសាដោយឥតគិតឈ្នួល បើជនជាប់ចោទមិនយល់ ឬមិនចេះភាសាដែលប្រើប្រាស់ក្នុងសវនាការ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣២២ | "ក្រឡាបញ្ជីហៅឈ្មោះជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ ព្រមទាំងផ្ទៀងផ្ទាត់មើលអត្តសញ្ញាណជនទាំងនោះ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣២៥ | "ប្រធានសវនាការប្រាប់ដល់ជនជាប់ចោទឱ្យបានដឹងអំពីអំពើដែលគេចោទប្រកាន់លើខ្លួន" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៣០ | ក្នុងករណីចាំបាច់ ប្រធានអាចហៅរកអ្នកបកប្រែ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៣១ | "កាលណាសំណួរត្រូវសួរដល់ជនគ និងថ្លង់ ក្រឡាបញ្ជីត្រូវសរសេរសំណួរ ហើយឱ្យសាមីខ្លួនអាន និងឆ្លើយជាលាយល័ក្ខណ៍អក្សរ។ ក្នុងករណីសាមីជនមិនចេះអាន ឬមិនចេះអក្សរ ប្រធានត្រូវរកអ្នកបកប្រែក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៣៣០ [...] ប្រធានសវនាការអាចហៅរកអ្នកធ្លាប់ប្រាស្រ័យទាក់ទងជាមួយជនគ និងថ្លង់នោះ មកបកប្រែ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៩៦ | "វិធានដែលអនុវត្តចំពោះតុលាការជាន់ដំបូង ក៏ត្រូវយកមកអនុវត្តចំពោះសាលាឧទ្ធរណ៍។" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៦ | "អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ៖[...] សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី [...] សិទ្ធិទទួលបានការឱ្យដំណឹងអំពីបទចោទប្រកាន់[...]" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៥១ | "នៅពេលចាប់ផ្តើមសវនាការ តុលាការត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសាដែលអនីតិជនយល់បានអំពីសិទ្ធិដូចខាងក្រោម៖ សិទ្ធិដែលទាក់ទងនឹងដំណាក់កាលនៃការជំនុំជម្រះដូចមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ [...]." |

ជនទាំងឡាយណាដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវតែទទួលបាននូវការជូនដំណឹងអំពីបទចោទប្រកាន់ ដែលជននោះត្រូវបានចោទប្រកាន់។ ប្រសិនបើពុំមានព័ត៌មានដ៏សំខាន់នេះទេ គេពិតជាមិនអាចរៀបចំការការពារក្តីឱ្យបានត្រឹមត្រូវ ឬផ្តល់ការណែនាំឱ្យបានល្អិតល្អន់ដល់មេធាវីនៅក្នុងសំណុំរឿងដែលជនជាប់ចោទមានមេធាវីការពារតាមផ្លូវច្បាប់។ អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ប្រមូលទិន្នន័យទាក់ទងនឹងព័ត៌មាន ដែលត្រូវបានប្រាប់ដល់ជនជាប់ចោទនៅពេលចាប់ផ្តើមសវនាការ។ ទោះបីជាព័ត៌មាននេះ គួរតែត្រូវបានប្រាប់ដល់ជនជាប់ចោទរួចហើយនៅក្នុងអំឡុងពេលនៃនីតិវិធីមុនសវនាការ/ការស៊ើបសួរ ក៏នៅតែមាន

សារៈសំខាន់សម្រាប់ចៅក្រមក្នុងការរំឭកដល់ជនជាប់ចោទអំពីព័ត៌មាននេះ មុនពេលសវនាការចាប់ផ្តើម ហើយត្រូវប្រាកដថាជនជាប់ចោទយល់ព័ត៌មាននេះ។ នេះជាការងារដ៏មានសារៈសំខាន់ជាពិសេសដោយសារតែពេលខ្លះ បទចោទអាចត្រូវបានផ្លាស់ប្តូរ ឬកែប្រែនៅចន្លោះពេលនៃការចាប់ខ្លួនដំបូង/ការចោទប្រកាន់ ក្នុងអំឡុងពេលសវនាការជាក់ស្តែង។

### *តួលេខទី ១០៖ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ - ទិដ្ឋភាពទូទៅ*

**តើចៅក្រមបានប្រាប់ពីបទចោទប្រកាន់ដែលពាក់ព័ន្ធដល់ជនជាប់ចោទគ្រប់រូបដែរឬទេ?**




ក្នុងសំណុំរឿងភាគច្រើន (១៤៧ សំណុំរឿងក្នុងចំណោមសំណុំរឿងទាំង ២១៣ ឬ ៦៩%) ចៅក្រមបានប្រាប់អំពីបទចោទប្រកាន់ដែលពាក់ព័ន្ធទាំងអស់ដល់ជនជាប់ចោទ។ ប្រសិនបើប្រៀបធៀបជាមួយនឹងឆ្នាំ ២០១៦/២០១៧ សំណុំរឿងដែលជនជាប់ចោទត្រូវប្រាប់អំពីបទចោទប្រកាន់ដែលពាក់ព័ន្ធទាំងអស់ បានធ្លាក់ចុះគួរឱ្យកត់សម្គាល់ ដោយបានធ្លាក់ចុះចាប់ពី ៨៦% មកត្រឹមតែ ៦៩%។ ដោយហេតុថាស្ទើរតែមួយភាគបីនៃសំណុំរឿង ដែល ម.ស.ម.ក បានសង្កេតការណ៍ក្នុងអំឡុងពេលធ្វើរបាយការណ៍ ជនជាប់ចោទមិនត្រូវបានប្រាប់អំពីបទចោទប្រកាន់ដែលពាក់ព័ន្ធទាំងអស់មកលើខ្លួនឡើយ ដែលនេះគឺគួរឱ្យព្រួយបារម្ភជាខ្លាំង ដែលបន្ទាប់ពីនេះ ម.ស.ម.ក បានសម្រេចចំណាត់ថ្នាក់សិទ្ធិនេះថាមិនទាន់ត្រូវបានគោរពពេញលេញនៅឡើយ។

### *តួលេខទី ១១៖ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ - ទិដ្ឋភាពលម្អិត*

| ទិន្នន័យ | មាន | | គ្មាន | | មិនពាក់ព័ន្ធ[101] | |
|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % |
| តើចៅក្រមបានប្រាប់ពីមាត្រាច្បាប់ដែលពាក់ព័ន្ធ ដែរឬទេ? | ១៣៤ | ៦៣% | ៧៩ | ៣៧% | 0 | 0% |

101 "មិនពាក់ព័ន្ធ" សំដៅលើជនជាប់ចោទជាជនជាតិខ្មែរ ឬជនជាប់ចោទគ្មានពិការភាព។

| | | | | | | |
|---|---|---|---|---|---|---|
| តើចៅក្រមបានប្រាប់ពីកាលបរិច្ឆេទនៃការប្រព្រឹត្តបទល្មើស ដែរឬទេ? | ២០២ | ៩៤,៨% | ១១ | ៥,២% | ០ | ០% |
| តើចៅក្រមបានប្រាប់ពីកន្លែងប្រព្រឹត្តបទល្មើស ដែរឬទេ? | ១៦៧ | ៧៨,៤% | ៤៦ | ២១,៦% | ០ | ០% |
| តើចៅក្រមបានរៀបរាប់ពីឈ្មោះអ្នកចូលរួម ដែរឬទេ? | ១៩៧ | ៩២,៥% | ១៦ | ៧,៥% | ០ | ០% |
| ប្រសិនបើត្រូវការ តើអ្នកបកប្រែត្រូវបានផ្តល់ឱ្យ ដែរឬទេ? | ៨ | ៣,៧% | ០ | ០% | ២០៥ | ៩៦,៣% |
| ប្រសិនបើត្រូវការ តើជនពិការត្រូវបានគេផ្តល់ជំនួយ ដែរឬទេ? | ១ | ០,៥% | ០ | ០% | ២១២ | ៩៩,៥% |

តួលេខខាងលើនេះបង្ហាញថា ក្នុងសំណុំរឿងជាច្រើន ចៅក្រមនៅសាលាឧទ្ធរណ៍ថ្លែងឡើងវិញអំពីបទចោទប្រកាន់ អង្គហេតុ កាលបរិច្ឆេទ និងព័ត៌មានទាក់ទងនឹងបទចោទ។ ហេតុនេះ សិទ្ធិយល់ដឹងអំពីប្រភេទនៃការចោទប្រកាន់នៅក្នុងនីតិវិធីបណ្តឹងឧទ្ធរណ៍ជាញឹកញាប់ត្រូវបានគោរព។ ប៉ុន្តែនៅពេលប្រៀបធៀបជាមួយនឹងការរកឃើញនៅក្នុងការសង្កេតការណ៍កាលពីឆ្នាំ២០១៦/២០១៧ ការគោរពសិទ្ធិនេះគឺមានការធ្លាក់ចុះយ៉ាងគំហុក ជាពិសេស ការជូនដំណឹងអំពីច្បាប់ពាក់ព័ន្ធ និងទីកន្លែងប្រព្រឹត្តបទល្មើស គឺមានលក្ខណៈគួរឱ្យព្រួយបារម្ភនៅឡើយ ដូចមានបញ្ជាក់នៅក្នុងតារាងខាងក្រោម។

*តួលេខទី ១២៖ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ - ការវិវឌ្ឍ*

| | ២០១៦/២០១៧ | ២០១៧/២០១៨ |
|---|---|---|
| ផ្នែកនៃសំណុំរឿងដែលចៅក្រមបានប្រាប់ពីមាត្រាច្បាប់ដែលពាក់ព័ន្ធ | ៩៦% | ៦៣% |
| ផ្នែកនៃសំណុំរឿងដែលចៅក្រមបានលើកឡើងអំពីកាលបរិច្ឆេទនៃការប្រព្រឹត្តបទល្មើស | ៩៦% | ៩៤.៨% |
| ផ្នែកនៃសំណុំរឿងដែលចៅក្រមបានប្រាប់ពីទីកន្លែងប្រព្រឹត្តបទល្មើស | ៩១% | ៧៨.៤% |
| ផ្នែកនៃសំណុំរឿងដែលចៅក្រមបានរៀបរាប់ពីឈ្មោះអ្នកចូលរួម | ៩៨% | ៩២.៥% |

នៅក្នុងអំឡុងពេលធ្វើរបាយការណ៍ ព័ត៌មានដែលចៅក្រមមិនបានផ្តល់ភាគច្រើនគឺទាក់ទងនឹងមាត្រាច្បាប់ដែលពាក់ព័ន្ធ និងទីកន្លែងប្រព្រឹត្តបទល្មើស ដែលជាព័ត៌មានលម្អិតសំខាន់ដែលត្រូវប្រាប់ដល់ជនជាប់

ចោទនៅក្នុងសវនាការព្រហ្មទណ្ឌ។ ភាគីខាងសាលាឧទ្ធរណ៍បានអះអាងថា ការប្រាប់ និងពន្យល់អំពីសិទ្ធិនីមួយៗដល់ជនជាប់ចោទគឺសាលាដំបូងបានប្រាប់ និងពន្យល់អំពីសិទ្ធិទាំងនោះរួចហើយ ដូច្នេះនីតិវិធីក្នុងពេលជំនុំជម្រះនៅសាលាឧទ្ធរណ៍មិនតម្រូវឱ្យអនុវត្តដូចនីតិវិធីសាលាដំបូងទេ។[102] ថ្វីបើមានការថ្លែងយ៉ាងដូច្នោះក៏ដោយ ប៉ុន្តែតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា វិធានទាំងឡាយដែលបានអនុវត្តចំពោះតុលាការជាន់ដំបូង ក៏ត្រូវយកមកអនុវត្តចំពោះសាលាឧទ្ធរណ៍ដែរ។[103]

## ៤.៣. សិទ្ធិមានមេធាវី និងមានវត្តមាននៅក្នុងសវនាការ

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ក.អ.ស.ព.ន<br>មាត្រា ១៤(៣)(ឃ) | "ក្នុងការសម្រេចសេចក្តីចោទប្រកាន់បទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ត្រូវជំនុំជម្រះដោយវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់ តាមការជ្រើសរើសរបស់ខ្លួន និងត្រូវបានប្រាប់ឱ្យដឹងអំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានជំនួយការច្បាប់ ហើយត្រូវទទួលបានជំនួយការច្បាប់សម្រាប់ខ្លួន ក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ និងដោយឥតបង់ថ្លៃ នៅគ្រប់ករណីបែបនេះ បើជនជាប់ចោទគ្មានមធ្យោបាយគ្រប់គ្រាន់ ដើម្បីចំណាយទៅលើជំនួយការច្បាប់ទេ។" |
| រដ្ឋធម្មនុញ្ញ<br>មាត្រា ៣៨ | "ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ១៤៣ | "នៅពេលដែលជនត្រូវចោទដែលជាអនីតិជន ចូលបង្ហាញខ្លួនជាលើកដំបូង ជននេះត្រូវតែមានមេធាវីអមជានិច្ច។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេ តុលាការត្រូវចាត់តាំងមេធាវីនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ៣០០ | "ជនជាប់ចោទត្រូវចូលបង្ហាញខ្លួន នៅពេលសវនាការរបស់តុលាការដោយផ្ទាល់។ ជនជាប់ចោទ ត្រូវអមដោយមេធាវីម្នាក់ដែលខ្លួនជ្រើសរើស។ ជនជាប់ចោទក៏អាចសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួនបានដែរ នៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ៣០១ | "ជំនួយពីមេធាវីត្រូវតែមានជាចំាំបាច់ខាតនៅក្នុងករណីដូចតទៅ៖ ១. ករណីបទឧក្រិដ្ឋ ២. កាលណា ជនជាប់ចោទជាអនីតិជន។" |

[102] នៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១៩ ម.ស.ម.ក បានជួបជាមួយប្រធាន អនុប្រធានទាំងអស់ អគ្គព្រះរាជអាជ្ញា តំណាងចៅក្រម ព្រមទាំងអគ្គលេខាធិការរដ្ឋបាលនៅសាលាឧទ្ធរណ៍ ដើម្បីពិភាក្សាលើរបកគំហើញនៅក្នុងរបាយការណ៍នេះ។

[103] មាត្រា ៣៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

| | |
|---|---|
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ៣៨៩ | "ជនជាប់ចោទដែលជាប់ឃុំ ត្រូវតែផ្ទេរនៅក្នុងរយៈពេលយ៉ាងខ្លីបំផុតតាមបញ្ជារបស់អគ្គព្រះរាជអាជ្ញាឱ្យទៅនៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួនដែលនៅជិតជាងគេបំផុតនៃទីស្នាក់ការរបស់សាលាឧទ្ធរណ៍។" |
| **ច្បាប់ស្តីពីពន្ធនាគារ<br>មាត្រា ៦២** | "ក្រៅពីទណ្ឌិត ការផ្ទេរជនជាប់ឃុំពីពន្ធនាគារមួយទៅពន្ធនាគារមួយ ក៏ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាមានសមត្ថកិច្ចខាងដែនដីបញ្ជូន និងព្រះរាជអាជ្ញាមានសមត្ថកិច្ចខាងដែនដីទទួល ឬព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចកំពុងចាត់ការរឿងក្តី។" (ការបកប្រែរបស់ ម.ស.ម.ក) |
| ច្បាប់ស្តីពីយុត្តិធម៌<br>អនីតិជន<br>មាត្រា ៦ | "អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថា បានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅៈ [...] សិទ្ធិទទួលបានជំនួយពីមេធាវី [...]" |
| **ច្បាប់ស្តីពីយុត្តិធម៌<br>អនីតិជន<br>មាត្រា ៥០** | "ជំនួយរបស់មេធាវី ត្រូវតែមានដាច់ខាតនៅក្នុងសវនាការ [...]" |
| ច្បាប់ស្តីពីយុត្តិធម៌<br>អនីតិជន<br>មាត្រា ៥១ | "នៅពេលចាប់ផ្តើមសវនាការ តុលាការត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសាដែលអនីតិជនអាចយល់បាន អំពីសិទ្ធិដូចខាងក្រោមៈ<br>• សិទ្ធិដែលទាក់ទងនឹងដំណាក់កាលនៃការជំនុំជម្រះដូចមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ<br>• សិទ្ធិមានវត្តមាននៅពេលជំនុំជម្រះក្តី<br>• សិទ្ធិទទួលបានការការពារពីតុលាការនូវទង្វើមិនគប្បី ឬការសួរដេញដោលមិនសមរម្យ<br>• សិទ្ធិប្តឹងជំទាស់ចំពោះសាលក្រមកំបាំងមុខ<br>• សិទ្ធិធ្វើសំណូមពរចុងក្រោយ និង<br>• សិទ្ធិប្តឹងឧទ្ធរណ៍។" |

ការដែលត្រូវបានចោទប្រកាន់ពីបទល្មើសណាមួយ អាចជាបទពិសោធន៍គួរឱ្យខ្លាច ហើយនីតិវិធីច្បាប់អាចមានភាពស្មុគស្មាញ និងច្របូកច្របល់។ ហេតុដូច្នោះ ជាការសំខាន់ណាស់ដែលបុគ្គលគ្រប់រូបមានឱកាសទទួលបានមេធាវី។ បន្ថែមលើនេះទៀត ជនជាប់ចោទដែលពុំមានលទ្ធភាពអាចជួលមេធាវីដោយខ្លួនឯង អាជ្ញាធរដែលពាក់ព័ន្ធគួរផ្តល់មេធាវីដោយឥតគិតថ្លៃក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ។[104] សិទ្ធិមានមេធាវីធានាថាជនជាប់ចោទមានឱកាសក្នុងការទទួលបានការណែនាំផ្នែកវិជ្ជាជីវៈពីអ្នកជំនាញផ្នែកតស៊ូ

[104] ក.អ.ស.ព.ន មាត្រា ១៤(៣)(ឃ)។

មតិ ដែលមានលទ្ធភាពពន្យល់នូវបទចោទប្រកាន់ប្រឆាំងខ្លួន ពន្យល់ពីសិទ្ធិ ណែនាំពីដំណើរការជំនុំជម្រះ និងការពារផលប្រយោជន៍ដល់ខ្លួននៅក្នុងតុលាការ។ នៅក្នុងប្រទេសកម្ពុជា ជាលក្ខខណ្ឌតម្រូវសម្រាប់បុគ្គលម្នាក់ត្រូវទទួលបានមេធាវី ប្រសិនបើបុគ្គលនោះត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬជននោះជាអនីតិជន។ ថ្វីបើពុំមានការតម្រូវដោយច្បាប់ចំពោះការទទួលបានមេធាវី ប្រសិនជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទមជ្ឈិម (លើកលែងតែជាអនីតិជន) ជននោះនៅតែមានជម្រើសមានមេធាវី ប្រសិនបើខ្លួនត្រូវការរក្សាឱ្យមានមេធាវី។ នៅក្នុងករណីបែបនេះ បន្ទុកក្នុងការរក្សាឱ្យមានមេធាវី ពុំមែនជាបន្ទុករបស់តុលាការឡើយ។ បន្ថែមលើនេះទៀត សវនាការចាំបាច់ត្រូវធ្វើឡើងដោយមានវត្តមានរបស់ជនជាប់ចោទ[105] ដើម្បីអនុញ្ញាតឱ្យជនជាប់ចោទអាចបានឮ និងឆ្លើយតបចំពោះសំណុំរឿងដែលបានប្ដឹងប្រឆាំងរូបខ្លួន ព្រមទាំងបង្ហាញការការពារខ្លួន។

ទាក់ទងជាមួយអនីតិជន សវនាការត្រូវធ្វើឡើងដោយមានវត្តមាន "ជំនួយផ្នែកច្បាប់ ឬជំនួយសមស្របដទៃទៀត" ព្រមទាំងឪពុកម្ដាយ ឬអាណាព្យាបាលស្របច្បាប់របស់កុមារ លើកលែងតែរកឃើញថា ការធ្វើបែបនេះពុំមែនជាឧត្តមប្រយោជន៍របស់កុមារ។[106] សិទ្ធិមានវត្តមានផ្ទាល់ ត្រូវអនុវត្តចំពោះនីតិវិធីបណ្ដឹងឧទ្ធរណ៍ ប្រសិនបើសំណុំរឿងនោះពាក់ព័ន្ធសំណួរផ្នែកអង្គហេតុផង និងអង្គច្បាប់ផង[107] ដែលករណីនេះកើតមាននៅក្នុងប្រទេសកម្ពុជា។ ថ្វីបើសវនាការ *កំបាំងមុខ* អាចត្រូវបានអនុញ្ញាតឱ្យមានតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិក្ដី សវនាការកំបាំងមុខ អាចត្រូវបានអនុញ្ញាតឱ្យធ្វើឡើងបានតែក្នុងស្ថានភាពពិសេស និងនៅពេលការធ្វើបែបនេះផ្ដល់ផលប្រយោជន៍ដល់ការអនុវត្តត្រឹមត្រូវផ្នែកយុត្តិធម៌ប៉ុណ្ណោះ។ ចាំបាច់ត្រូវមានការផ្ដល់ហេតុផលសមស្របដើម្បីអាចធ្វើសវនាការកំបាំងមុខបាន។[108] បន្ថែមលើនេះទៀត ចាំបាច់ត្រូវមានការបញ្ជាក់ច្បាស់ពីជនជាប់ចោទថាខ្លួនបោះបង់សិទ្ធិមានវត្តមាននៅពេលសវនាការ។[109]

---

[105] ក.អ.ស.ព.ន មាត្រា ១៤(៣)(ឃ)។

[106] អនុសញ្ញាស្ដីពីសិទ្ធិកុមារ មាត្រា ៤០(២)(ខ)(iii)។

[107] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិសំណុំរឿង Karttunen ទល់នឹងប្រទេសហ្វាំងឡង់ដ៍ សេចក្ដីសម្រេចលេខ ៣៨៧/១៩៨៩ នៅក្នុងឯកសាររបស់ អ.ស.ប លេខ CCPR/C/46/D/387/1989 ចុះនៅឆ្នាំ១៩៩២ វាក្យខណ្ឌ ៧.៣, http://juris.ohchr.org/Search/Details/402។

[108] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ , សេចក្ដីសម្រេចលេខ ០១៦/១៩៧៧ សំណុំរឿង Mbenge ទល់នឹង Zaire, នៅក្នុងឯកសាររបស់ អ.ស.ប លេខ CCPR/C/18/D/16/1977, ចុះនៅក្នុងឆ្នាំ១៩៨៣ វាក្យខណ្ឌ ១៤.១ http://juris.ohchr.org/Search/Details/573។

[109] UN HRC សេចក្ដីពន្យល់ទូទៅលេខ ៣២, ២០០៧ វាក្យខណ្ឌ ៣៦។

### *តួលេខទី ១៣៖ សិទ្ធិមានវត្តមាននៅក្នុងសវនាការ និងមានមេធាវី*[110]




ទិន្នន័យរវាងឆ្នាំ២០១៦/២០១៧ និងឆ្នាំ២០១៧/២០១៨ មានចំណុចខុសគ្នាយ៉ាងខ្លាំង។ ថ្វីបើភាគរយនៃជនជាប់ចោទដែលមានវត្តមាននៅក្នុងអំឡុងពេលសវនាការ មានចំនួនកើនឡើងគួរឱ្យកត់សម្គាល់គឺចាប់ពី ៧២,៤ ដល់ ៨២,៥% ក្តី ប៉ុន្តែចំនួនជនជាប់ចោទជានីតិជនដែលមានមេធាវីតំណាងសម្រាប់បទមជ្ឈិម បានធ្លាក់ចុះពី ៧៨,៧% ដល់ ៧៦,៥% ដែលតាមច្បាប់ជាតិចៅក្រមអាចដំណើរសវនាការបាន ប្រសិនបើជនជាប់ចោទជានីតិជននោះមិនត្រូវការមេធាវីតំណាង តែនេះគឺជាការអនុវត្តមិនស្របនឹងបទដ្ឋាននៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលច្បាប់សិទ្ធិមនុស្សអន្តរជាតិ មិនបានកំណត់ពីការទទួលបានមេធាវីតំណាងដោយផ្អែកលើប្រភេទនៃបទល្មើសឡើយ។ ទោះបីជាមានការប្រែប្រួលយ៉ាងនេះក្តី ប៉ុន្តែសម្រាប់ទិដ្ឋភាពជារួមគឺ មាននិន្នាការវិជ្ជមាន។ នៅតែមានក្តីបារម្ភ ដោយសារមានតែជនជាប់ចោទប្រមាណតែ ៣/៤ ប៉ុណ្ណោះ ដែលមានមេធាវីតំណាង។

---

[110] ទិន្នន័យនេះគឺផ្អែកលើចំនួនជនជាប់ចោទសរុប (៣១៥ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ២១៣ ដែលបានសង្កេតការណ៍។

*តួលេខទី ១៤៖ សិទ្ធិមានវត្តមាននៅក្នុងសវនាការ និងមានមេធាវី ចន្លោះចាប់ពីឆ្នាំ២០១៦-២០១៨*




ថ្វីបើសិទ្ធិមានមេធាវីត្រូវបានការពារនៅក្នុងសំណុំរឿងភាគច្រើន (៧៦,៥០%) ក៏ដោយ ប៉ុន្តែបើគិតទៅលើលក្ខណៈជាមូលដ្ឋាននៃសិទ្ធិមានវត្តមាននៅក្នុងសវនាការ និងមានមេធាវី គឺជនជាប់ចោទ ចំនួន ២៣,៥០% ពុំមានមេធាវីតំណាង និងសំណុំរឿងចំនួន ១៧,៥% ដែលជនជាប់ចោទមិនមានវត្តមាននៅក្នុងសវនាការ ដែលនៅតែជាមូលហេតុគួរឱ្យព្រួយបារម្ភនៅឡើយ។ នៅខែមេសា ឆ្នាំ២០១៧ អនុប្រធានសាលាឧទ្ធរណ៍[111] បានគូសបញ្ជាក់ថាសំណុំរឿងភាគច្រើនដែលជនជាប់ចោទអវត្តមានពេលសវនាការ គឺដោយសារបញ្ហាកង្វះខាតនៃការដឹកជញ្ជូនជនជាប់ចោទពីមណ្ឌលឃុំឃាំងមកតុលាការ ដែលនេះជាការទទួលខុសត្រូវរបស់អគ្គនាយកដ្ឋានពន្ធនាគារ។

ម្យ៉ាងវិញទៀត ចំនួនករណីដែលមេធាវីតំណាងឱ្យជនជាប់ចោទច្រើនជាងម្នាក់បានធ្លាក់ចុះពី ៤០% នៅក្នុងឆ្នាំ២០១៦/២០១៧ មកត្រឹមតែ ៣៤,៣% នៅក្នុងឆ្នាំ ២០១៧/២០១៨។ ទោះបីនៅពេលខ្លះការចំណាយមានប្រសិទ្ធភាពក៏ពិតមែន តែស្ថានភាពដែលមេធាវីតំណាងឱ្យជនជាប់ចោទច្រើនជាងម្នាក់ បានបង្ហាញពីការព្រួយបារម្ភចំពោះសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ពួកគេ ឧទាហរណ៍នៅពេលដែលមានការការពារក្តីឱ្យជនជាប់ចោទច្រើននាក់ ឬអង្គហេតុរបស់ជនជាប់ចោទម្នាក់ក្នុងចំណោមសហជនជាប់ចោទមានភាពខុសគ្នា ឬមានភាពផ្ទុយគ្នាទៅនឹងអង្គហេតុរបស់សហជនជាប់ចោទផ្សេងទៀត។ ប្រសិនបើមេធាវីតែម្នាក់តំណាងឱ្យជនជាប់ចោទទាំងអស់ នឹងធ្វើឱ្យការការពារក្តីមានផលប៉ះពាល់អវិជ្ជមានទៅលើជនជាប់ចោទផ្សេងទៀតជាក់ជាមិនខាន ហើយជនជាប់ចោទនោះនឹងមិនអាចទទួលបានការការពារក្តីដោយប្រសិទ្ធភាព

[111] ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៨ ក្រុមការងារគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ បានជួបជាមួយអនុប្រធានសាលាឧទ្ធរណ៍ ឯកឧត្តម ប្លង់ សំណាង ឯកឧត្តម ញូង ធុល ព្រមទាំងអគ្គលេខាធិការរងរដ្ឋបាល លោកស្រី ស្រេង សូយ៉េត ដើម្បីពិភាក្សាលើរបកគំឃើញនៅក្នុងរបាយការណ៍ ឆ្នាំ២០១៦/២០១៧។

ហើយមិនទទួលបានតំណាងដោយមេធាវីគ្រប់គ្រាន់ឡើយ។ ករណីបែបនេះ គឺមានទំនាស់ផលប្រយោជន៍ ដូច្នេះជនជាប់ចោទម្នាក់ៗ គួរតែមានមេធាវីដាច់ដោយឡែកពីគ្នា[112]។

នៅក្នុងឆ្នាំ២០១៧/២០១៨ ទំនាស់ផលប្រយោជន៍ដែល ម.ស.ម.ក បានរកឃើញនៅក្នុងអំឡុងពេលធ្វើការសង្កេតការណ៍នៅសវនាការ គឺមានសំណុំរឿងតែ ៣% ប៉ុណ្ណោះ ដែលមេធាវីតែម្នាក់តំណាងឱ្យជនជាប់ចោទច្រើននាក់ ដែលចំនួននេះបានធ្លាក់ចុះទាបជាងឆ្នាំ២០១៦/២០១៧ (៤%)។ តួលេខនេះបង្ហាញអំពីនិន្នាការវិជ្ជមាន។

### *តួលេខទី ១៥៖ ការពន្យល់ប្រាប់សិទ្ធិ*

**តើចៅក្រមបានប្រាប់ និងពន្យល់ជនជាប់ចោទអំពីសិទ្ធិមានមេធាវី ឬសិទ្ធិការពារខ្លួន ដែរឬទេ?**




* ជនជាប់ចោទអវត្តមាន។

ដោយហេតុថា ៦៧% នៃសំណុំរឿងទាំង ២១៣ សំណុំរឿងដែល ម.ស.ម.ក បានសង្កេតការណ៍ ជនជាប់ចោទមានមេធាវីតំណាងរួចហើយ ដែលនេះបង្ហាញថាសិទ្ធិរបស់បុគ្គលក្នុងការទទួលបានមេធាវីភាគច្រើនត្រូវបានការពារ និងបង្ហាញថាមានការកើនឡើងតិចតួចចាប់តាំងពីឆ្នាំ២០១៦/២០១៧ ដែលតួលេខពេលនោះគឺ ៦៤%។ ភាគីសាលាឧទ្ធរណ៍បានអះអាងថា សាលាឧទ្ធរណ៍តែងតែអនុវត្តតាមនីតិវិធីច្បាប់ជាតិជានិច្ច ដូចជា សវនាការលើសំណុំរឿងនៃបទឧក្រិដ្ឋ និងសំណុំរឿងព្រហ្មទណ្ឌរបស់អនីតិជន គឺតែងតែមានមេធាវីតំណាងជានិច្ច លើកលែងតែសំណុំរឿងនៃបទមជ្ឈិមដែលជនជាប់ចោទមិនមែនជាអនីតិជនមិនត្រូវការមេធាវីតំណាងតែប៉ុណ្ណោះ[113]។

---

112 សូមមើលគោលការណ៍ណែនាំរបស់ ម.ស.ម.ក ស្តីពីតារាងសង្កេតការណ៍នៅសាលាឧទ្ធរណ៍ http://tmp.sithi.org/index.php?p=detail&id=97&l=en ទំព័រ ៤៧។

113 នៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១៩ ម.ស.ម.ក បានជួបជាមួយប្រធាន អនុប្រធានទាំងអស់ អគ្គព្រះរាជអាជ្ញា តំណាងចៅក្រម ព្រមទាំងអគ្គលេខាធិការរដ្ឋបាលនៅសាលាឧទ្ធរណ៍ ដើម្បីពិភាក្សាលើរបកគំហើញនៅក្នុងរបាយការណ៍នេះ។

ម្យ៉ាងវិញទៀត ក្នុងចំណោមសំណុំរឿងទាំង២១៣ សំណុំរឿង មាន ៣៤ សំណុំរឿង (ឬស្មើនឹង ១៦%) ដែលចៅក្រមពុំបានប្រាប់ និងពន្យល់ជនជាប់ចោទអំពីសិទ្ធិមានមេធាវី ឬសិទ្ធិការពារខ្លួនរបស់ជនជាប់ចោទ។ តួលេខនេះចាត់ទុកថាមានការកើនឡើងគួរឱ្យព្រួយបារម្ភពីឆ្នាំ២០១៦/២០១៧ ខណៈដែលមានតួលេខគឺ ១១%។ ជាលទ្ធផល សិទ្ធិនេះនៅតែមិនត្រូវបានគោរពពេញលេញ។

ក្នុងករណីជនជាប់ចោទពុំមានវត្តមាននៅក្នុងសវនាការ ជាញឹកញាប់អវត្តមាននេះដោយសារបញ្ហាភ័ស្តុភារ ក៏ដូចជា បញ្ហាផ្នែកការប្រាស្រ័យទាក់ទងរវាងចៅក្រមជាមួយមណ្ឌលកែប្រែ ឬកន្លែងឃុំឃាំង។ ដោយហេតុថាមានសាលាឧទ្ធរណ៍តែមួយប៉ុណ្ណោះសម្រាប់ប្រទេសទាំងមូល ជនជាប់ចោទដែលជាប់ឃុំនៅក្នុងមណ្ឌលកែប្រែតាមខេត្ត ចាំបាច់ត្រូវធ្វើដំណើរមកកាន់សាលាឧទ្ធរណ៍នៅថ្ងៃសវនាការ។ ប៉ុន្តែមានករណីជាច្រើន ដែលការដឹកជញ្ជូនជនជាប់ចោទពុំអាចធ្វើឡើងបាន ដោយសារតែតុលាការបញ្ជូនព័ត៌មានទៅខុសមណ្ឌលកែប្រែ ឬដោយសារតែមណ្ឌលកែប្រែពុំបានផ្តល់ព័ត៌មានបច្ចុប្បន្នភាព អំពីការផ្ទេរជនជាប់ឃុំពីមណ្ឌលកែប្រែមួយ ទៅមណ្ឌលកែប្រែមួយទៀត។ បញ្ហាភ័ស្តុភារទាំងអស់នេះ អាចត្រូវបានដោះស្រាយយ៉ាងងាយស្រួលដោយមិនត្រឹមតែត្រូវបង្កើតសាលាឧទ្ធរណ៍បន្ថែមទៀតនោះទេ ប៉ុន្តែក៏ត្រូវតែកែលម្អការរក្សាកំណត់ត្រា និងការប្រាស្រ័យទាក់ទងរវាងតុលាការជាមួយមណ្ឌលកែប្រែផងដែរ។ ក្តីបារម្ភនេះអាចកាត់បន្ថយបានតាមរយៈការបង្កើតសាលាឧទ្ធរណ៍តំបន់[114]។

## ៤.៤. សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ក.អ.ស.ព.ន<br>មាត្រា ១៤(២) | "ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវមានសិទ្ធិត្រូវបានសន្មតជាមុនថាគ្មានទោសរហូតដល់ពិរុទ្ធភាពរបស់ខ្លួន ត្រូវបានកំណត់ស្របតាមច្បាប់។" |
| រដ្ឋធម្មនុញ្ញ<br>មាត្រា ៣៨ | "ជនជាប់ចោទណាក៏ដោយ ត្រូវទុកថាជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន<br>មាត្រា ៥ | "គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធនឹងអនីតិជន ត្រូវជានាឱ្យមានការគោរពគោលការណ៍ដូចតទៅ៖ [...] សន្មតថាគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។" |

ការសន្មតទុកជាមុនថាគ្មានទោស គឺជាសិទ្ធិជាមូលដ្ឋាន និងត្រូវបានទទួលស្គាល់ជាសកលថាជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលសិទ្ធិនេះអនុវត្តនៅពេញរយៈពេលនៃនីតិវិធីនៃការស៊ើបអង្កេត និង

[114] របាយការណ៍រដ្ឋាភិបាលសម្រាប់វដ្តទី ៣នៃយូភីអ វាក្យខណ្ឌ ១៨C, ៤០ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សេចក្តីថ្លែងការណ៍បញ្ចប់បេសកកម្មរបស់ UNSRSHRC ទំព័រ ៤ វាក្យខណ្ឌ ២; ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ របាយការណ៍ UNSRSHRC វាក្យខណ្ឌ ៨១។

ការជំនុំជម្រះផ្នែកព្រហ្មទណ្ឌ រហូតដល់ការបញ្ចប់បណ្តឹងឧបាស្រ័យចុងក្រោយ។[115] មានន័យថាជនម្នាក់នឹងត្រូវបានសន្មតជាមុនថាគ្មានទោស រហូតទាល់តែពិរុទ្ធភាពរបស់ខ្លួន ត្រូវបានកំណត់ស្របតាមច្បាប់ និងតាមរយៈសាលដីកាស្ថាពរ។ គោលការណ៍ដែលថា បន្ទុកនៃភស្តុតាងស្ថិតនៅលើស្ថាប័នអយ្យការ មិនមែនជាបន្ទុករបស់ជនជាប់ចោទទេ គឺមានប្រភពចេញមកពីការសន្មតទុកជាមុនថាគ្មានទោស។

បើទោះបីជាជនជាប់ចោទមិននិយាយអ្វីទាំងអស់ ហើយមិនបង្ហាញភស្តុតាងអ្វីទាល់តែសោះក៏ដោយ ក៏ជនចាប់ចោទត្រូវបានឱ្យរួចផុតពីបទចោទ ប្រសិនបើអយ្យការមិនអាចបង្ហាញភស្តុតាងដាក់បន្ទុក ឬអាចនិយាយម្យ៉ាងទៀតថា ជនជាប់ចោទពុំមានកាតព្វកិច្ចត្រូវបង្ហាញភស្តុតាងដើម្បីបង្ហាញថាខ្លួនជាជនគ្មានទោសនោះឡើយ។ កាន់តែជាក់លាក់ទៀត ការសន្មតទុកជាមុនថាគ្មានទោសតម្រូវឱ្យ៖

i. តុលាការ ឬសាលាក្តីមិនត្រូវធ្វើការសម្រេចជាមុនចំពោះសំណុំរឿងដែលនាំមកចំពោះមុខខ្លួនឡើយ។

ii. ពិរុទ្ធភាពហួសពីវិមតិសង្ស័យ ចាំបាច់ត្រូវបង្ហាញភស្តុតាងដោយអយ្យការ។

iii. ការប្រព្រឹត្តចំពោះជនជាប់ចោទ មិនត្រូវធ្វើឡើងក្នុងលក្ខណៈដែលបង្ហាញថា ជនជាប់ចោទមានពិរុទ្ធភាពនោះឡើយ។

iv. ប្រព័ន្ធផ្សព្វផ្សាយគួរចៀសវាងការផ្សព្វផ្សាយព័ត៌មានទាំងឡាយណាដែលបំផ្លាញដល់ការសន្មតទុកជាមុនថាគ្មានទោសឡើយ។

v. អាជ្ញាធរសាធារណៈក៏គួរចៀសវាងការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈណាដែលអាចបំផ្លាញដល់ការសន្មតជាមុននេះដែរ[116]។

នៅពេលដែលជនជាប់ចោទចូលរួមក្នុងសវនាការក្នុងឯកសណ្ឋានជាអ្នកទោស[117] ការសន្មតទុកជាមុនថាគ្មានទោសត្រូវបានប៉ះពាល់ជាខ្លាំង។ ករណីនេះ ជាពិសេសនៅពេលដែលពុំមានការបង្ហាញឱ្យឃើញពីភាពខុសគ្នារវាងអ្នកត្រូវបានឃុំខ្លួនរង់ចាំសវនាការ និងទណ្ឌិត។ នៅពេលដែលអ្នកត្រូវបានឃុំខ្លួនរង់ចាំសវនាការបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានពន្ធនាគារនោះ ហើយការបង្ហាញខ្លួននេះគឺដូចគ្នាទៅនឹងទណ្ឌិតដែលត្រូវបានកាត់ទោសជាស្ថាពរហើយ។ ដោយសារតែពុំមានការបញ្ជាក់ពីភាពខុសគ្នារវាងអ្នកជាប់ឃុំទាំងពីរប្រភេទ ការអនុវត្តបែបនេះធ្វើឱ្យមានការសន្មតយ៉ាងជាក់ស្តែងថា ជនជាប់ចោទគឺពិតជាជនល្មើសដែលត្រូវបាន

---

[115] ការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ("ការិយាល័យឧត្តមស្នងការ"), សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ (ផ្នែកទី ១), ជំពូក ៦ ទំព័រ ២១៩,
https://www.ohchr.org/Documents/Publications/training9chapter6en.pdf។

[116] UN HRC សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣០; ECtHR, *Barberá, Messegué and Jabardo ទល់នឹងប្រទេសអេស្ប៉ាញ* ឆ្នាំ១៩៩៨ វាក្យខណ្ឌ ៧៧ http://hudoc.echr.coe.int/eng?i=001-57429។

[117] ចំណុចនេះសំដៅលើឯកសណ្ឋានពណ៌ខៀវរបស់ទណ្ឌិត ដែលក្រសួងមហាផ្ទៃបានចេញសេចក្តីប្រកាសថាឯកសណ្ឋានពណ៌ខៀវនេះគឺសម្រាប់ទណ្ឌិតដែលសាលក្រម ឬសាលដីកាបានចូលជាស្ថាពររួចហើយ។ សូមមើលព្រឹត្តិបត្រព័ត៌មានស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក ឯកសណ្ឋានជនជាប់ឃុំ និង សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ចុះនៅខែមិថុនា ឆ្នាំ២០១៧ http://tmp.sithi.org/?p=detail&id=108&l=kh#go។

ផ្ដន្ទាទោសរួចហើយ ហេតុដូច្នេះ អាចជះឥទ្ធិពលដល់សេចក្តីសម្រេចរបស់ចៅក្រម ក៏ដូចជា ការយល់ឃើញរបស់សាធារណជនផងដែរ។ សូម្បីតែនៅពេលជនជាប់ចោទកំពុងតែជាប់ឃុំ ការណ៍ដែលថាជនជាប់ចោទបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងឯកសណ្ឋានជាអ្នកទោស ក៏ធ្វើឱ្យមានការប៉ះពាល់ដល់គោលការណ៍យុត្តិធម៌ដូចគ្នាដែរ។ បញ្ហាដែលជនជាប់ចោទបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានជាអ្នកទោសនេះ ជាការទទួលខុសត្រូវរបស់អគ្គនាយកដ្ឋានពន្ធនាគារ។

ការប្រតិបត្តិល្អជាលក្ខណៈអន្តរជាតិនៅក្នុងយុត្តិធម៌ព្រហ្មទណ្ឌចង្អុលបង្ហាញឱ្យឃើញថា ជនជាប់ចោទគួរតែអាចស្លៀកសម្លៀកបំពាក់របស់ខ្លួនពេលបង្ហាញខ្លួននៅក្នុងតុលាការ។ វិធានបទដ្ឋានអប្បបរមាអង្គការសហប្រជាជាតិសម្រាប់ការប្រព្រឹត្តចំពោះជនជាប់ឃុំ "វិធាននេស៊ុន មេនឌីឡា (Nelson Mandela)"[118] អនុម័តដោយមហាសន្និបាទអង្គការសហប្រជាជាតិក្នុងឆ្នាំ ២០១៥ ដែលបង្ហាញពីការប្រតិបត្តិល្អៗ ត្រូវបានទទួលស្គាល់ជាអន្តរជាតិសម្រាប់ការប្រព្រឹត្តចំពោះជនជាប់ឃុំចែងថា "ជនជាប់ឃុំដែលពុំទាន់បានជំនុំជម្រះ ត្រូវបានអនុញ្ញាតឱ្យស្លៀកសម្លៀកបំពាក់របស់ខ្លួន ប្រសិនបើសម្លៀកបំពាក់នោះស្អាត និងសមស្រប។ ប្រសិនបើគាត់ស្លៀកពាក់ឯកសណ្ឋានពន្ធនាគារ ឯកសណ្ឋាននោះត្រូវខុសប្លែកពីឯកសណ្ឋាន ដែលត្រូវបានផ្តល់ឱ្យទណ្ឌិត"។ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") ជនរងការចោទប្រកាន់ត្រូវបានអនុញ្ញាតឱ្យស្លៀកសម្លៀកបំពាក់ផ្ទាល់ខ្លួននៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការព្រហ្មទណ្ឌ រហូតមានសេចក្តីសម្រេចជាស្ថាពរ។ ហេតុនេះ ជនជាប់ចោទគួរតែទទួលបានការអនុញ្ញាតឱ្យបង្ហាញខ្លួនក្នុងតុលាការដោយស្លៀកសម្លៀកបំពាក់របស់ខ្លួន។ យ៉ាងហោចណាស់ ឯកសណ្ឋានពន្ធនាគារដែលពួកគេស្លៀកពាក់ ចាំបាច់ត្រូវតែខុសប្លែកពីឯកសណ្ឋានរបស់ទណ្ឌិត។ ជាលទ្ធផលនៃការតស៊ូមតិរបស់ ម.ស.ម.ក មានការផ្លាស់ប្តូរជាសន្សឹមៗ ដោយក្នុងនោះមានជនជាប់ចោទកាន់តែច្រើនឡើងបានបង្ហាញខ្លួនក្នុងឯកសណ្ឋាន (ពណ៌ទឹកក្រូច) ខុសប្លែកពីឯកសណ្ឋានរបស់ទណ្ឌិត (ពណ៌ខៀវ)។ បន្ថែមលើនេះទៀត មានករណីជាច្រើនដែលជនជាប់ចោទបានបង្ហាញខ្លួនចំពោះមុខតុលាការនៅក្នុងសម្លៀកបំពាក់របស់ខ្លួនផ្ទាល់[119]។

[118] អង្គមហាសន្និបាតអង្គការសហប្រជាជាតិ, វិធានបទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិស្តីពីការប្រព្រឹត្តិចំពោះជនជាប់ឃុំ សេចក្តីសម្រេចលេខ ៧០/១៧៥ ឧបសម្ព័ន្ធ ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៥
http://cambodia.ohchr.org/sites/default/files/Softlaw/The%20Nelson%20Mandela%20Rules%20_Kh.pdf។

[119] នៅថ្ងៃទី ១៨ ខែមករា ឆ្នាំ២០១៨ ជនជាប់ចោទពីបទជួញដូរគ្រឿងញៀនដែលត្រូវបានសាលាដំបូងខេត្តតាកែវកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេលប្រាំឆ្នាំ ត្រូវបានបញ្ជូនទៅសាលាឧទ្ធរណ៍ដើម្បីចូលរួមសវនាការឧទ្ធរណ៍លើសំណុំរឿងរបស់ខ្លួនក្នុងសម្លៀកបំពាក់ស៊ីវិល។ លោក កឹម សុខា អតីតប្រធានគណបក្សសង្គ្រោះជាតិ ក៏បានបង្ហាញខ្លួនក្នុងសវនាការដោយស្លៀកសម្លៀកបំពាក់របស់គាត់ដែរ កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៨។

## *តួលេខទី ១៦៖ ការសន្មតទុកជាមុនថាគ្មានទោស* [120]




* ជនជាប់ចោទអវត្តមាន ឬពុំត្រូវបានឃុំខ្លួន។

តួលេខខាងលើបង្ហាញថាជនជាប់ចោទ ៨២ នាក់ក្នុងចំណោម ៣១៥ នាក់នៅតែបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានទណ្ឌិតនៅក្នុងពេលសវនាការ ដែលបង្ហាញថា ២៦% នៃសំណុំរឿងរបស់ជនជាប់ចោទដែលបានសង្កេតការណ៍ដោយ ម.ស.ម.ក។ នេះបង្ហាញអំពីកំណើនខ្ពស់ជាងឆ្នាំ២០១៦/២០១៧ ដែលមានតែ ៩% នៃជនជាប់ចោទបានបង្ហាញខ្លួនក្នុងឯកសណ្ឋានពន្ធនាគារ ដែលការអនុវត្តធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសន្មតទុកជាមុនថាគ្មានទោស ការណ៍នេះចៅក្រមគួរតែអនុញ្ញាតឱ្យជនជាប់ចោទប្តូរសំលៀកបំពាក់ជាអ្នកទោសចេញជំនួសដោយសំលៀកបំពាក់ស៊ីវិលវិញ មុនចូលរួមដំណើរសវនាការ។ បញ្ហាព្រួយបារម្ភយ៉ាងខ្លាំងនេះ បានធ្វើឱ្យមានការតស៊ូមតិជាច្រើន ដែលនាំឱ្យអនុប្រធានសាលាឧទ្ធរណ៍[121] លើកឡើងថាពួកគាត់នឹងធ្វើការពិភាក្សាបញ្ហានេះជាមួយនឹងក្រសួងមហាផ្ទៃ ក៏ដូចជាមួយនឹងមណ្ឌលកែប្រែដើម្បីកំណត់លទ្ធភាពក្នុងការអនុញ្ញាតឱ្យជនជាប់ចោទស្លៀកសម្លៀកបំពាក់ស៊ីវិលនៅក្នុងសវនាការ។

នៅពេលដែលជនជាប់ចោទបង្ហាញខ្លួនក្នុងឯកសណ្ឋានដូចគ្នាជាមួយឯកសណ្ឋានជាទណ្ឌិត នេះជាហេតុ ធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការសន្មតទុកជាមុនថាគ្មានទោសរបស់ពួកគេ។ ថ្វីបើការបែងចែកឯកសណ្ឋានកន្លងមកទទួលបានការស្វាគមន៍យ៉ាងណាក្តី ជាការចាំបាច់ណាស់ដែលការអនុវត្តក្នុងការអនុញ្ញាតឱ្យជនជាប់ចោទស្លៀកសម្លៀកបំពាក់ផ្ទាល់ខ្លួន នៅពេលបង្ហាញខ្លួនក្នុងតុលាការត្រូវបានយកទៅអនុវត្តជាទូទៅ។ ដើម្បីធានាបាននូវភាពស៊ីសង្វាក់គ្នា អាជ្ញាធរគួរចេញគោលការណ៍ណែនាំឱ្យបានច្បាស់លាស់ដោយគូសបញ្ជាក់ថា ជនជាប់ចោទដែលត្រូវបានឃុំខ្លួនរង់ចាំសវនាការ ឬអ្នកដែលស្ថិតក្នុងដំណាក់កាលជំនុំជម្រះ ប៉ុន្តែនៅពុំទាន់

[120] ទិន្នន័យនេះគឺផ្អែកលើចំនួនជនជាប់ចោទសរុប (៣១៥ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ២១៣ ដែលបានសង្កេតការណ៍។

[121] ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៨ ក្រុមការងារគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ បានជួបជាមួយអនុប្រធានសាលាឧទ្ធរណ៍ ឯកឧត្តម ប្លង់ សំណាង ឯកឧត្តម ញូង ធុល ព្រមទាំងអគ្គលេខាធិការរងរដ្ឋបាល លោកស្រី ស្រេង សូយ៉េត ដើម្បីពិភាក្សាលើរបកគំហើញនៅក្នុងរបាយការណ៍ ឆ្នាំ២០១៦/២០១៧។

មានសេចក្តីសម្រេចស្ថាពរនៅឡើយ ចាំបាច់ត្រូវទទួលបានការអនុញ្ញាតឱ្យបង្ហាញខ្លួនក្នុងតុលាការដោយស្លៀកសម្លៀកបំពាក់ស៊ីវិល។ ក្នុងជំនួបពិភាក្សារវាងភាគីសាលាឧទ្ធរណ៍ជាមួយ ម.ស.ម.ក ភាគីសាលាឧទ្ធរណ៍បានលើកឡើងថា សិទ្ធិទទួលបានការសន្និតទុកជាមុនថាគ្មានទោស គឺមិនពាក់ព័ន្ធនឹងការស្លៀកពាក់របស់ជនជាប់ចោទនោះទេ។ សិទ្ធិនេះ គឺទាក់ទងនឹងបន្ទុកនៃភស្តុតាងដែលត្រូវបង្ហាញដោយតំណាងអយ្យការ តែបើជនជាប់ចោទត្រូវបានសួរថា តើជនជាប់ចោទមានភស្តុតាងអ្វីដែលបញ្ជាក់ថាខ្លួនគ្មានទោស? នះការអនុវត្តបែបនេះទើបជាការរំលោភបំពានលើសិទ្ធិសន្និតទុកជាមុនថាគ្មានទោស។ ភាគីសាលាឧទ្ធរណ៍ក៏បានបញ្ជាក់ផងដែរថា បញ្ហាស្លៀកពាក់របស់ជនជាប់ចោទនេះមិនមែនជាការទទួលខុសត្រូវរបស់សាលាឧទ្ធរណ៍នោះទេ តែនេះជាការទទួលខុសត្រូវរបស់អគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ។[122]

## ៤.៥. សិទ្ធិបង្ហាញភស្តុតាង

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ក.អ.ស.ព.ន<br>មាត្រា ១៤<br>(៣)(ង) | "ក្នុងការសម្រេចសេចក្តីចោទប្រកាន់បទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិសួរចម្លើយ ឬសុំឱ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឱ្យសាក្សីដោះបន្ទុកចូលខ្លួនដើម្បីសួរចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ១៥៣ | "ចៅក្រមស៊ើបសួរអាចសាកសួរបុគ្គលគ្រប់រូប ដែលចម្លើយនោះអាចមានប្រយោជន៍នៅក្នុងការសម្តែងឱ្យឃើញការពិត [...] ចៅក្រមស៊ើបសួរក៏អាចសួរតទល់គ្នារវាងជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីផងដែរ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ១៥៤ | "មុននឹងឆ្លើយទៅនឹងសួរសំណួរ សាក្សីម្នាក់ៗ ត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថានិយាយតែការពិតប៉ុណ្ណោះ។ ទម្រង់នៃសម្បថ ត្រូវធ្វើដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃក្រមនេះ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ២៩៨ | "ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីអាចនាំចូលរួមក្នុងសវនាការនូវសាក្សីទាំងឡាយណាដែលព្រះរាជអាជ្ញាមិនបានកោះហៅដោយខ្លួនជាអ្នកចេញសោហ៊ុយ។ |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ៣២១ | "លើកលែងបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌ អាចជូនបានដោយសេរី។ តុលាការថ្លឹងថ្លែងដោយឥស្សរបិត្តអំពីតម្លៃភស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យ |

[122] នៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១៩ ម.ស.ម.ក បានជួបជាមួយប្រធាន អនុប្រធានទាំងអស់ អគ្គព្រះរាជអាជ្ញា តំណាងចៅក្រម ព្រមទាំងអគ្គលេខាធិការរដ្ឋបាលនៅសាលាឧទ្ធរណ៍ ដើម្បីពិភាក្សាលើរបកគំហើញនៅក្នុងរបាយការណ៍នេះ។

| | |
|---|---|
| | ដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន។ តុលាការសំអាងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនតែទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឬដែលត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ។ ការសារភាពក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរ ត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង។ ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្តនេះ គ្មានតម្លៃជាភស្តុតាងទេ។ ការឆ្លើយឆ្លងរវាងជនជាប់ចោទ និងមេធាវីរបស់ខ្លួន និងអាចយកមកធ្វើជាភស្តុតាងបានឡើយ។” |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ៣២៤ | “នៅពេលបើកកិច្ចពិភាក្សាដេញដោល ភាគីនីមួយៗអាចសុំឱ្យតុលាការស្តាប់ចម្លើយក្នុងឋានៈជាសាក្សីនូវបុគ្គលដែលមានវត្តមាននៅក្នុងបន្ទប់ ប៉ុន្តែបុគ្គលនោះមិនបានកោះហៅឱ្យបានត្រឹមត្រូវទេ។ ការស្តាប់ចម្លើយសាក្សីនេះ ត្រូវមានការយល់ព្រមពីប្រធានសវនាការ។ ក្រឡាបញ្ជីស្រង់អត្តសញ្ញាណ និងអញ្ជើញសាក្សីនេះឱ្យថយទៅនៅបន្ទប់រង់ចាំ។” |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ៣២៦ | “ប្រធានសវនាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ តាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ [....]។ ព្រះរាជអាជ្ញា មេធាវី និងភាគីទាំងអស់ អាចត្រូវបានអនុញ្ញាតឱ្យលើកសំណួរសួរ។ គ្រប់ការលើកសំណួរទាំងអស់ ត្រូវតែបានការអនុញ្ញាតពីប្រធានសវនាការ។ ក្រៅពីសំណួររបស់ព្រះរាជអាជ្ញា និងមេធាវី សំណួរផ្សេងៗទៀតត្រូវសួរតាមរយៈសវនាការ។ ក្នុងករណីមានការតវ៉ាប្រធានសវនាការសម្រេចចិត្តដោយឥស្សរចិត្តថា តើសំណួរនេះត្រូវតែសួរ ឬទេ។” |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ៣២៨ | “មុននឹងឆ្លើយទៅនឹងសំណួរ សាក្សីនីមួយៗ ត្រូវស្បថថា ខ្លួននិយាយតែការពិតស្របតាមសាសនា ឬជំនឿរបស់ខ្លួន។” |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ៣៩៤ | “ក្រោយពេលសួរចម្លើយជនជាប់ចោទរួច ប្រធានសវនាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី តាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ សាក្សី និងអ្នកជំនាញ នឹងត្រូវបានគេស្តាប់ចម្លើយ លុះត្រាតែតុលាការបង្គាប់ឱ្យស្តាប់ចម្លើយជនទាំងនេះ។” |
| ច្បាប់ស្តីពីយុត្តិធម៌<br>អនីតិជន<br>មាត្រា ៦ | “អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ៖ [.........] សិទ្ធិបង្ហាញភស្តុតាង។ សិទ្ធិស្នើសុំឱ្យកោះហៅសាក្សី និងសួរសាក្សី [...].” |

រាល់សេចក្តីសម្រេចទាំងអស់របស់តុលាការ ត្រូវតែផ្អែកទាំងស្រុងលើភស្តុតាងដែលបានបង្ហាញនៅក្នុងដំណាក់កាលនៃការជំនុំជម្រះ។ ហេតុដូច្នេះ នេះជាការសំខាន់ដែលភាគីនីមួយៗមានឱកាសដើម្បីបង្ហាញភស្តុតាង និងហៅសាក្សីនានាដែលគាំទ្រដល់សំណុំរឿងរបស់ខ្លួន។[123] នេះជារឿងសំខាន់ដូចគ្នាដែលភាគីនីមួយៗត្រូវបានផ្តល់ឱកាសដើម្បីសួរដេញដោលសាក្សី និងបដិសេធភស្តុតាងដែលខ្លួនមិនទទួលយក។ ថ្វីបើវិធាននៃភស្តុតាងតាមរយៈ សក្ខីកម្មជាលាយលក្ខណ៍អក្សរ (មានន័យថាភស្តុតាងដែលមិនបានផ្តល់ក្នុងអំឡុងពេលសវនាការ) មិនប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្តី ក៏ការធ្វើបែបនេះត្រូវអនុលោមតាមច្បាប់សិទ្ធិមនុស្សដែរ ហើយជនជាប់ចោទមានសិទ្ធិបដិសេធ និងដេញដោលសួរសាក្សី នៅពេលដែលសាក្សីនោះបានផ្តល់សក្ខីកម្ម ឬនៅដំណាក់កាលបន្ទាប់ទៀតនៃនីតិវិធីមុនសវនាការផ្ទាល់។[124] ជាចុងក្រោយ ដោយអនុលោមតាមច្បាប់សិទ្ធិមនុស្ស នៅពេលជនសង្ស័យ ឬជនត្រូវចោទផ្តល់ការសារភាព ការសារភាពនោះត្រូវធ្វើឡើងដោយពុំមានការបង្ខិតបង្ខំដោយផ្ទាល់ ឬដោយប្រយោលតាមផ្លូវកាយ ឬតាមផ្លូវចិត្តណាមួយឡើយ។[125] ប្រសិនបើបុគ្គលនោះអះអាងថាមានការរំលោភបំពានលើសិទ្ធិរបស់ខ្លួន បន្ទុកនៃការបង្ហាញភស្តុតាងត្រូវធ្លាក់លើភាគីដែលបានលើកពីការសារភាពនោះមកបង្ហាញថា ការសារភាពនោះពុំត្រូវបានធ្វើឡើងដោយការបង្ខិតបង្ខំ ហើយបញ្ហានេះពុំមែនជាបន្ទុករបស់ជនជាប់ចោទក្នុងការបង្ហាញថា ការសារភាពនោះត្រូវបានធ្វើឡើងដោយការបង្ខិតបង្ខំនោះឡើយ។[126] ភស្តុតាងទទួលបានដែលជាការរំលោភបំពានលើសិទ្ធិនេះ ជាភស្តុតាងមិនអាចទទួលយកបាននៅក្នុងសវនាការ។[127]

---

[123] មាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

[124] សូមមើលឧទាហរណ៍ ECtHR *សំណុំរឿង Mirilashvili ទល់នឹងប្រទេសរុស្ស៊ី* ឆ្នាំ២០០៨ វាក្យខណ្ឌ ១៦៣ http://hudoc.echr.coe.int/eng?i=001-90099។ ECtHR *សំណុំរឿង Asch ប្រទេសអូទ្រីស* ឆ្នាំ១៩៩១ វាក្យខណ្ឌ ២៧ http://hudoc.echr.coe.int/eng?i=001-57676។ ECtHR សំណុំរឿង Isgrò ទល់នឹងប្រទេសអ៊ីតាលី ឆ្នាំ១៩៩១ វាក្យខ័ណ្ឌ ៣៤ http://hudoc.echr.coe.int/eng?i=001-57653។ ECtHR *សំណុំរឿង Kostovski ទល់នឹងប្រទេសហូឡង់ដ៍* ឆ្នាំ១៩៨៩ វាក្យខណ្ឌ ៤១ http://hudoc.echr.coe.int/eng?i=001-57615។

[125] UN HRC សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៤១។ សូមមើលផងដែរ៖ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ *សំណុំរឿង Deolall ទល់នឹង Guyana* សេចក្តីសម្រេចលេខ ៩១២/២០០០ ឆ្នាំ២០០៤ វាក្យខណ្ឌ ៥.១ http://juris.ohchr.org/Search/Details/1149៖ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សំណុំរឿងសំណុំរឿង *Singarasa* ទល់នឹងប្រទេសស្រីលង្កា សេចក្តីសម្រេចលេខ ១០៣៣/២០០១ ឆ្នាំ២០០៤ វាក្យខណ្ឌ ៧.៤ http://juris.ohchr.org/Search/Details/1125 គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សំណុំរឿង *Khuseynova and Butaeva* ទល់នឹងប្រទេសតាជីគីស្ថាន សេចក្តីសម្រេចលេខ ១២៦៣/២០០៤ និង ១២៦៤/២០០៤ ឆ្នាំ២០០៨ វាក្យខណ្ឌ ៨.៣ http://juris.ohchr.org/Search/Details/1457។

[126] UN HRC សេចក្តីពន្យល់ទូទៅលេខ ៣២ ឆ្នាំ២០០៧ វាក្យខណ្ឌ ៤១។ សូមមើលផងដែរ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ *សំណុំរឿង Singarasa ទល់នឹងប្រទេសស្រីលង្កា* សេចក្តីសម្រេចលេខ ១០៣៣/២០០១ 2004 វាក្យខណ្ឌ ៧.៤ http://juris.ohchr.org/Search/Details/1125។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សំណុំរឿង *Khuseynova and Butaeva ទល់នឹងប្រទេសតាជីគីស្ថាន* សេចក្តីសម្រេចលេខ ១២៦៣/២០០៤ និង ១២៦៤/២០០៤ ឆ្នាំ២០០៨ វាក្យខណ្ឌ ៨.៣ http://juris.ohchr.org/Search/Details/1457។

[127] UN HRC សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៦, ៤១ គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ២៩ ឆ្នាំ២០០១ វាក្យសព្ទ ៧, ១៥

ជារឿងគួរកត់សម្គាល់មួយបានមកពីការប្រមូលទិន្នន័យលើសំណុំរឿងទាំង ២១៣ ដែលបានចុះសង្កេតការណ៍នោះគឺពុំមានការលើកឡើងថាភាគីណាមួយមិនត្រូវបានផ្តល់ឱកាសឱ្យហៅសាក្សីនោះឡើយ។ ទោះបីជាយ៉ាងនេះក៏ដោយ សិទ្ធិបង្ហាញភស្តុតាងនៅតែជាបញ្ហាប្រឈមដោយសារហេតុផលចម្បងពីរយ៉ាង។ អ្នកសង្កេតការណ៍នៅសវនាការបានកត់សម្គាល់ឃើញថាក្នុងចំណោមសំណុំរឿងមួយចំនួនតូច ដែលសាក្សីមានវត្តមានគឺសាក្សីបានស្ថិតនៅក្នុងបន្ទប់សវនាការមុនពេលត្រូវសាកសួរ គឺមានសំណុំរឿងចំនួន ៦ សំណុំរឿងក្នុងចំណោមសំណុំរឿង ២១៣ ពោលគឺមាន១ រៀងរាល់ ៣៦ សំណុំរឿង។ ការអនុវត្តបែបនេះ អាចធ្វើឱ្យសក្ខីកម្មរបស់សាក្សីទាំងនោះ រងឥទ្ធិពលតាមរយៈការស្តាប់ឮចម្លើយរបស់សាក្សីផ្សេងទៀតមុនពេលផ្តល់សក្ខីកម្ម។ ការអនុវត្តប្រសើរជាងនេះ គួរតែឱ្យសាក្សីចេញពីបន្ទប់សវនាការ និងមិនត្រូវត្រឡប់ទៅបន្ទប់សវនាការវិញ រហូតទាល់តែសាក្សីនោះត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្ម។

លើសពីនេះទៀត សាលាឧទ្ធរណ៍ត្រូវតែធានាថាភស្តុតាងដែលត្រូវយកមកថ្លឹងថ្លែងមានគុណតម្លៃគ្រប់គ្រាន់ (ភាពគួរជឿជាក់ និងភាពពិតប្រាកដ) និងធានាថា ភាគីទាំងអស់មានឱកាសក្នុងការជំទាស់នឹងភស្តុតាងនោះ។ ទិន្នន័យដែលបានប្រមូលនៅអំឡុងពេលសង្កេតការណ៍សវនាការបង្ហាញថា គុណភាពនៃភស្តុតាងដែលបានបង្ហាញ គឺជាការគួរឱ្យព្រួយបារម្ភជាខ្លាំង។ ភស្តុតាងជាច្រើនដែលបានបង្ហាញនៅក្នុងសវនាការដែលបានសង្កេតការណ៍គឺជាការសារភាព ឬភស្តុតាងជាឯកសារ។ គុណភាព និងចំនួននៃភស្តុតាងដែលបានបង្ហាញ និងពិចារណាក្នុងពេលសវនាការជំនុំជម្រះ គឺមានភាពចាំបាច់ដើម្បីធានាថាបុគ្គលគ្រប់រូបត្រូវបានតុលាការរកឃើញពីពិរុទ្ធភាពហួសពីវិមតិសង្ស័យ។ បន្ថែមពីលើភស្តុតាងជាឯកសារ ចៅក្រម និងព្រះរាជអាជ្ញាគួរតែមានភាពសកម្មក្នុងការស្វែងរក និងពិនិត្យភស្តុតាងប្រភេទដទៃទៀតដែលពាក់ព័ន្ធដូចជា សាក្សីផ្ទាល់ ភស្តុតាងវេជ្ជសាស្ត្រ និងភស្តុតាងកោសល្យវិច័យជាដើម។ ការសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក បង្ហាញឱ្យឃើញថាពុំមាននិន្នាការពិនិត្យលើភស្តុតាងប្រភេទនេះនៅក្នុងសាលាឧទ្ធរណ៍ឡើយ។

## ៤.៦. សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា | |
|---|---|
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ៣៥៧ | "សាលក្រមទាំងអស់ត្រូវមានពីរផ្នែក៖<br>• ផ្នែកសំអាងហេតុពោលគឺជាទឡ្ហីករណ៍នៃអង្គហេតុ និងអង្គច្បាប់ដែលនាំឱ្យតុលាការចេញសេចក្តីសម្រេច។<br>• ផ្នែកសម្រេច ពោលគឺសេចក្តីសម្រេចរបស់តុលាការ។ |

http://docstore.ohchr.org/SelfServices/FilesHandler.ashx?enc=6QkG1d/PPRiCAqhKb7yhsjYoiCfMKoIRv2FVaVzRkMjTnjRO%2Bfud3cPVrcM9YR0iix49nlFOsUPO4oTG7R/o7TSsorhtwUUG%2By2PtslYr5BldM8DN9shT8B8NpbsC%2B7bODxKR6zdESeXKjiLnNU%2BgQ%3D%3D។

| | |
|---|---|
| | អង្គហេតុត្រូវតែច្បាស់លាស់ និងគ្មានការសង្ស័យ។ តុលាការត្រូវតែពិនិត្យមើលបទចោទនីមួយៗ និងទឡ្ហីករណ៍ដែលបានលើកឡើងនៅពេលសវនាការ។<br>នៅក្នុងសំអាងហេតុ តុលាការត្រូវឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់គូភាគី។<br>ផ្នែកសេចក្តីសម្រេចត្រូវចុះនិទ្ទេសអំពីបទល្មើសដែលជនជាប់ចោទប្រព្រឹត្តខុសអត្ថបទច្បាប់ដែលអនុវត្តទោស និងទណ្ឌកម្មរដ្ឋប្បវេណី។” |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ៤០៣ | “វិធានស្តីពីទម្រង់ និងហត្ថលេខាសាលក្រមរបស់តុលាការសាលាដំបូង ត្រូវយកមកអនុវត្តលើសាលដីការបស់សាលាឧទ្ធរណ៍”។ |

សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ នៅមានជាប់ជាមួយនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងត្រូវបានរួមបញ្ចូលនៅក្នុងសិទ្ធិទទួលបានសេចក្តីប្រកាសសេចក្តីសម្រេចជាសាធារណៈ។ យោងតាមបទដ្ឋានអន្តរជាតិ បុគ្គលដែលត្រូវបានកាត់ឱ្យជាប់ទោសមានសិទ្ធិទទួលបានសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរក្នុងរយៈពេលមួយសមរម្យ ហើយសេចក្តីសម្រេចនេះ ត្រូវមានសំអាងហេតុត្រឹមត្រូវ ក្នុងការបើកផ្លូវប្តឹងជំទាស់ ដើម្បីឱ្យជនជាប់ចោទអនុវត្តសិទ្ធិរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពក្នុងការស្នើឱ្យតុលាការជាន់ខ្ពស់ពិនិត្យពីការចោទប្រកាន់ និងការផ្តន្ទាទោសមកលើខ្លួនដោយផ្អែកលើច្បាប់។[128] ក្នុងបរិបទកម្ពុជា សិទ្ធិនេះត្រូវបានគោរពដោយជនជាប់ចោទ និងអយ្យការ មានលទ្ធភាពប្តឹងសារទុក្ខលើសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ទៅកាន់តុលាការកំពូលបន្ថែមទៀត។

ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានចែងថាសាលក្រមទាំងអស់ដែលចេញដោយសាលាដំបូងត្រូវតែមានពីរផ្នែកៈ ផ្នែកសំអាងហេតុពោលគឺជា “ទឡ្ហីករណ៍នៃអង្គហេតុ និងអង្គច្បាប់ដែលនាំឱ្យតុលាការចេញសេចក្តីសម្រេច” និងសេចក្តីសម្រេចរបស់តុលាការ (មាត្រា ៣៥៧)។ សាលក្រមត្រូវតែច្បាស់លាស់ ហើយចៅក្រមត្រូវតែពិនិត្យមើលបទចោទនីមួយៗ និងទឡ្ហីករណ៍ដែលបានលើកឡើងនៅពេលសវនាការ”។ នៅក្នុងសំអាងហេតុ តុលាការត្រូវឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់គូភាគី (មាត្រា ៣៥៧)។ មាត្រា ៤០៣ នៃក្រមនេះ បានចែងថាបញ្ញត្តិទាំងនេះ ត្រូវតែអនុវត្តលើសាលដីការបស់សាលាឧទ្ធរណ៍។

នៅខែមីនា ឆ្នាំ២០១៨ សេចក្តីថ្លែងការណ៍របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោកស្រី រ៉ូណា ស្មីត បានគូសបញ្ជាក់អំពីសារៈសំខាន់នៃសិទ្ធិនេះ ដោយអំពាវនាវឱ្យមាន “ការធ្វើសេចក្តីសម្រេចក្នុងប្រព័ន្ធតុលាការកាន់តែមានភាពប្រសើរ និងមានតម្លាភាព” “ការ

---

[128] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ សំណុំរឿង *V. Francis ទល់នឹង Jamaica* សេចក្តីសម្រេចលេខ ៣២០/១៩៨៨ ឆ្នាំ១៩៩៣ វាក្យខណ្ឌ ១២.២ http://hrlibrary.umn.edu/undocs/html/320-1988.html។

សម្រេចចិត្តគួរតែស្របទៅនឹងភស្តុតាង និងការអនុវត្តច្បាប់" ដើម្បីលើកកម្ពស់ឱ្យមានភាពច្បាស់លាស់ផ្នែកច្បាប់កាន់តែជាក់ច្បាស់ និងធ្វើឱ្យប្រសើរឡើងការយល់ឃើញរបស់សារធារណជន។ លោកស្រី ក៏បានផ្តល់អនុសាសន៍ថា "ផែនការក្នុងការបោះពុម្ពផ្សាយសេចក្តីសម្រេច និងសំអាងហេតុផ្លូវច្បាប់គួរត្រូវបានអនុវត្តបន្តទៅមុខទៀត"[129]។ សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ សំដៅលើការចេញសាលក្រមព្រហ្មទណ្ឌប្រឆាំងលើនរណាម្នាក់ ត្រូវតែពន្យល់អំពីមូលហេតុ និងដំណើរការឈានដល់ការកាត់ទោស និងមូលហេតុដែលបុគ្គលនោះត្រូវបានរកឃើញថាមានពិរុទ្ធភាព និងភាពគ្មានទោស។ ដើម្បីធ្វើដូចនេះបាន ទាំងអង្គហេតុ និងអង្គច្បាប់ដែលជាសំអាងហេតុក្នុងការចេញសាលក្រម ត្រូវតែពន្យល់៖

- ***អង្គហេតុ៖*** សាលក្រមត្រូវតែបញ្ជាក់ឱ្យបានច្បាស់នូវអង្គហេតុដែលជាសំអាងហេតុក្នុងការកាត់ទោសលើជនជាប់ចោទ រួមមាន កាលបរិច្ឆេទ ទីកន្លែង និងហេតុការណ៍ជាក់ស្តែងផងដែរ។ ដើម្បីធ្វើបែបនេះ ចៅក្រមត្រូវយោងឱ្យបានត្រឹមត្រូវតាមភស្តុតាងនីមួយៗ ដែលជាសំអាងក្នុងធ្វើសេចក្តីសម្រេច ឧទាហរណ៍ ការសារភាព ឬសក្ខីកម្មជាក់លាក់របស់សាក្សី និងពន្យល់អំពីមូលហេតុដែលខ្លួនផ្អែកលើចំណុចទាំងនេះ។

- ***អង្គច្បាប់៖*** សាលក្រមក៏ត្រូវតែដាក់បញ្ចូលផងដែរនូវមូលដ្ឋានច្បាប់ដែលជាសំអាងហេតុនៃការកាត់ទោស ទាំងច្បាប់ព្រហ្មទណ្ឌ (ព្រហ្មទណ្ឌ) និងទំនួលខុសត្រូវបទព្រហ្មទណ្ឌ (ទម្រង់នៃទំនួលខុសត្រូវ៖ អ្នកប្រព្រឹត្តផ្ទាល់ អ្នកសមគំនិត ។ល។)។

ការចេញសាលក្រមដោយមានសំអាងហេតុត្រឹមត្រូវគឺមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីការពារពីការកាត់ទោសតាមទំនើងចិត្ត[130] ដោយហេតុថាការណ៍នេះតម្រូវឱ្យចៅក្រមពន្យល់អំពីការធ្វើសេចក្តីសម្រេចរបស់ខ្លួន និងធានាថាជនដែលត្រូវកាត់ទោសបានដឹងអំពីមូលហេតុ និងហេតុផលដែលខ្លួនត្រូវបានកាត់ទោស។ ក្នុងបរិបទកម្ពុជា សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុត្រូវអនុវត្តចំពោះសាលដីកាទាំងឡាយរបស់សាលាឧទ្ធរណ៍ ជនជាប់ចោទអាចប្តឹងសារទុក្ខលើសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ទៅកាន់តុលាការកំពូល។ គួរឱ្យសោកស្តាយ នៅស្ទើរតែគ្រប់សំណុំរឿងទាំងអស់ដែល ម.ស.ម.ក បានសង្កេតការណ៍ គឺចៅក្រមមិនបានផ្តល់ហេតុផលលម្អិតចំពោះសេចក្តីសម្រេចរបស់ខ្លួនឡើយ ផ្ទុយទៅវិញចៅក្រមគ្រាន់តែអាន និងប្រកាសសេចក្តីសម្រេចតែប៉ុណ្ណោះ។

---

[129] នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ សេចក្តីថ្លែងការណ៍បញ្ចប់បេសកកម្មរបស់ UNSRSHRC។

[130] "សៀវភៅស្តីពីការជំនុំជម្រះដោយយុត្តិធម៌" អង្គការលើកលែងទោសអន្តរជាតិ ទំព័រ ១៧៤ ផ្នែក ២៤.២, https://www.amnesty.org/download/Documents/8000/pol300022014en.pdf ("សៀវភៅស្តីពីការជំនុំជម្រះដោយយុត្តិធម៌របស់អង្គការលើកលែងទោសអន្តរជាតិ")។

ក្នុងឆ្នាំ២០១៤-២០១៥ ចៅក្រមមិនបានបញ្ជាក់លម្អិត និងច្បាស់លាស់អំពីច្បាប់ពាក់ព័ន្ធនៅពេលប្រកាសសាលដីកាគឺមានចំនួន ៨០% ហើយមិនបានលើកឡើងអំពីភស្តុតាងលម្អិតក្នុងសំណុំរឿង ៧៣%[131]។ នៅក្នុងសំណុំរឿងទាំងអស់ដែលម.ស.ម.ក បានសង្កេតការណ៍នៅចន្លោះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧ សំណុំរឿងចំនួន ៦៧,៥% បង្ហាញថាការសម្រេចសេចក្តីមានសំអាងមិនបញ្ជាក់លម្អិត និងហេតុច្បាស់លាស់។ សម្រាប់អំឡុងពេលធ្វើរបាយការណ៍ សំណុំរឿង ៩៥ ក្នុងចំណោម ២១៣ សំណុំរឿងដែល ម.ស.ម.ក បានសង្កេតការណ៍គឺ ម.ស.ម.ក មានវត្តមាននៅពេលប្រកាសសេចក្តីសម្រេច។ នៅក្នុងសំណុំរឿង ៩៥ សេចក្តីសម្រេចមានមូលដ្ឋានសំអាងហេតុមិនបញ្ជាក់លម្អិត និងច្បាស់លាស់ ចំនួន ៨៧,៤% ក្នុងចំណោមសំណុំរឿងទាំងនេះ។ ចំនួននេះបង្ហាញថាមានកំណើនយ៉ាងខ្លាំង ដោយហេតុថាសំណុំរឿងនៃសេចក្តីសម្រេចមានសំអាងហេតុមិនបញ្ជាក់លម្អិត និងច្បាស់លាស់បានធ្លាក់ចុះនៅចន្លោះឆ្នាំ ២០១៤/២០១៥ (៨០%) និង២០១៦/២០១៧ (៦៧,៥%)។ ដូចដែលបានបង្ហាញខាងលើ សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ គឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិជាមូលដ្ឋាននៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ជាប្រការចាំបាច់ដែលត្រូវបង្កើនការយកចិត្តទុកដាក់បន្ថែមទៀតលើបញ្ហានេះ ដើម្បីការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា។

*តួលេខទី ១៧៖ ការវិវឌ្ឍនៃសំណុំរឿងដែលសេចក្តីសម្រេចមានសំអាងហេតុមិនលម្អិត និងច្បាស់លាស់នៅចន្លោះឆ្នាំ២០១៤-២០១៨*




[131] "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា ការសង្កេតការណ៍នៅសាលាឧទ្ធរណ៍" ដោយ ម.ស.ម.ក ខែមិថុនា ឆ្នាំ២០១៨ ទំព័រ ៣៧ http://tmp.sithi.org/?p=detail&id=119&l=kh#go។

*តួលេខទី ១៨៖ ទិដ្ឋភាពទូទៅនៃសាលដីការបស់សាលាឧទ្ធរណ៍* [132]




* ក្រុមការងារអ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ពុំមានវត្តមាននៅពេលប្រកាសសាលដីកា។

ក្នុងសំណុំរឿង ៤១% ដែល ម.ស.ម.ក បានសង្កេតការណ៍នៅក្នុងអំឡុងពេលធ្វើបាយការណ៍ ជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធភាព។ ប៉ុន្តែចំណុចនេះក៏គួរពិនិត្យមើលថាជាងពាក់កណ្តាលនៃសំណុំរឿងទាំងនេះ (៥៦%) អ្នកសង្កេតការណ៍របស់ ម.ស.ម.ក មិនមានវត្តមាននៅពេលចេញសាលដីកាឡើយ។ ផ្ទុយពីឆ្នាំ ២០១៦/២០១៧ ជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធភាពនៅក្នុងនៃសំណុំរឿង ៦៧% ខណៈដែល ម.ស.ម.ក មិនមានវត្តមានដើម្បីសង្កេតការណ៍ការនៅពេលប្រកាសសាលដីកានៅក្នុងសំណុំរឿងចំនួន ២៨%។

អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ក៏បានកត់សម្គាល់ផងដែរថាក្នុងសំណុំរឿងមួយចំនួនសាលាឧទ្ធរណ៍បានតម្កល់សេចក្តីសម្រេចរបស់សាលាដំបូង ដែលនិន្នាការនេះបានបន្តកើតឡើងចាប់ពីឆ្នាំ ២០១៦/២០១៧។ ចំណុចនេះ បូករួមជាមួយនឹងកង្វះការអានសំអាងហេតុនៅក្នុងសេចក្តីសម្រេច បង្កើតឱ្យមានមូលហេតុគួរឱ្យព្រួយបារម្ភថា តើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទត្រូវបានគោរព ឬយ៉ាងណា។

ក្នុងសំណុំរឿងស្ទើរតែទាំងអស់ដែល ម.ស.ម.ក បានសង្កេតការណ៍នៅពេលចេញសាលដីកា ចៅក្រមមិនបានបញ្ជាក់លម្អិតអំពីហេតុផលចំពោះសេចក្តីសម្រេចរបស់ខ្លួនឡើយ។ ចៅក្រមពុំបានលើកឡើងលម្អិត និងច្បាស់លាស់អំពីវិធានច្បាប់ និងភស្តុតាងដែលជាមូលដ្ឋាននៃសាលដីការបស់ខ្លួនឡើយ។

ក្នុងពិភាក្សាវាងភាគីសាលាឧទ្ធរណ៍ជាមួយ ម.ស.ម.ក ភាគីសាលាឧទ្ធរណ៍បានអះអាងថា ការអានសំអាងហេតុ គឺច្បាប់មិនតម្រូវទេ ហេតុដូចនេះ ចៅក្រមអាចអានសំអាងហេតុក៏បាន ឬមិនអានសំអាងហេតុក៏

[132] ទិន្នន័យនេះគឺផ្អែកលើចំនួនជនជាប់ចោទសរុប (៣១៥ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ២១៣ ដែលបានសង្កេតការណ៍។

បាននៅពេលប្រកាសសាលដីកា ហើយប្រសិនបើភាគីនៃរឿងក្តីមិនមានវត្តមានទេ តើចាំបាច់ត្រូវអានសំអាងហេតុធ្វើអ្វី។ ភាគីសាលាឧទ្ធរណ៍ក៏បានលើកឡើងផងដែរថា របាយការណ៍នេះមិនគួរលើកពីការអនុវត្តនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ឬសាលាក្តីខ្មែរក្រហមមកទេ ពីព្រោះ អ.វ.ត.ក ជំនុំជម្រះលើបទឧក្រិដ្ឋកម្មអន្តរជាតិ។[133] ថ្វីបើមានលើកឡើងយ៉ាងនេះក្តី ក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា សាលក្រមទាំងអស់ត្រូវមានពីរផ្នែកៈ (១)ផ្នែកសំអាងហេតុពោលគឺជាទឡ្ហីករណ៍នៃអង្គហេតុ និងអង្គច្បាប់ដែលនាំឱ្យតុលាការចេញសេចក្តីសម្រេច។ (២)ផ្នែកសម្រេច ពោលគឺសេចក្តីសម្រេចរបស់តុលាការ [...][134]។ រីឯមាត្រា ៣៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា គ្រប់សាលក្រមត្រូវតែប្រកាសនៅពេលសវនាការសាធារណៈ។ ផ្នែកនៃសេចក្តីសម្រេចត្រូវអានដោយសំឡេងខ្លាំងៗដោយប្រធានសវនាការ។

### ៤.៧. សិទ្ធិរបស់អនីតិជន

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ក.អ.ស.ព.ន<br>មាត្រា ១៤(១) | ក.អ.ស.ព.ន មាត្រា ១៤ (១)៖ "សារព័ត៌មាន និងសាធារណជន អាចមិនឱ្យចូលរួមទាំងស្រុង ឬផ្នែកមួយនៃសវនាការ [...] នៅពេលដែលផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគីតម្រូវឱ្យធ្វើដូច្នេះ [...] ប៉ុន្តែការចេញសាលក្រមទាំងអស់ អំពីរឿងព្រហ្មទណ្ឌ រដ្ឋប្បវេណីត្រូវប្រកាសជាសាធារណៈ លើកលែងតែផលប្រយោជន៍អនីតិជន ត្រូវផ្សេងពីនេះ ឬរឿងក្តីអំពីទំនាក់ទំនងគ្រួសារ ឬអាណាព្យាបាលរបស់កុមារ។" |
| អនុសញ្ញាស្តីពីសិទ្ធិកុមារ<br>មាត្រា ៤០(២)(ខ)(vii) | "រដ្ឋភាគីត្រូវធានា ជាពិសេសថា [...] ត្រូវគោរពយ៉ាងពេញលេញនូវសិទ្ធិនៃជីវិតឯកជនរបស់កុមារ នៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធី។" |
| អនុសញ្ញាស្តីពីសិទ្ធិកុមារ<br>មាត្រា ៤០(៤) | "ចំណាត់ថ្នាក់មួយចំនួន ដូចជា ការថែទាំ របៀបណែនាំ និងដីកាតាមដានពិគ្រោះយោបល់ ការសាកល្បងឱ្យនៅក្រៅឃុំ ការថែទាំដោយឪពុក-ម្តាយធម៌ កម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមធ្យោបាយផ្សេងៗទៀតជំនួសការថែទាំតាមស្ថាប័ន ត្រូវធ្វើឱ្យមានដើម្បីធានាថា កុមារទទួលបាននូវចំណាត់ការដែលសមស្រប ចំពោះសុខុមាលភាពរបស់ខ្លួន និងមានសមាមាត្រទៅនឹងស្ថានភាពរបស់កុមារ និងបទល្មើស។" |

[133] នៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១៩ ម.ស.ម.ក បានជួបជាមួយប្រធាន អនុប្រធានទាំងអស់ អគ្គព្រះរាជអាជ្ញា តំណាងចៅក្រម ព្រមទាំងអគ្គលេខាធិការរដ្ឋបាលនៅសាលាឧទ្ធរណ៍ ដើម្បីពិភាក្សាលើរបកគំហើញនៅក្នុងរបាយការណ៍នេះ។

[134] មាត្រា ៣៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

| | |
|---|---|
| **រដ្ឋធម្មនុញ្ញ<br>មាត្រា ៣១** | "ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុង [...] កតិកាសញ្ញា ព្រមទាំង អនុសញ្ញាទាំងឡាយទាក់ទងនឹង [...] សិទ្ធិកុមារ។" |
| **រដ្ឋធម្មនុញ្ញ**<br>មាត្រា ៤៨ | "រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ។" |
| **ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ១០០** | "កាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ឪពុក ម្តាយ ដល់អ្នកតំណាងស្របច្បាប់ ឬអ្នកទទួលភារកិច្ចលើអនីតិជន។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ២១២ | "អនីតិជនអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្តោះអាសន្នទេ។ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននេះឱ្យឪពុកម្តាយអ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្ន រង់ចាំសេចក្តីសម្រេចរបស់តុលាការ។" |
| **ក្រមព្រហ្មទណ្ឌ<br>មាត្រា ៣៩** | "អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ។ ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។" |
| ក្រមព្រហ្មទណ្ឌ<br>មាត្រា ៤០ | "វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភមានដូចតទៅ៖ ការប្រគល់អនីតិជនឱ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងមានទំនុកចិត្ត ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន ការប្រគល់ អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស ការប្រគល់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។" |
| **ច្បាប់ស្តីពីយុត្តិធម៌<br>អនីតិជន<br>មាត្រា ៥** | "គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធនឹងអនីតិជន ត្រូវធានាឱ្យមានការគោរពគោលការណ៍ដូចតទៅ៖ ត្រូវយកចិត្តទុកដាក់ និងពិចារណារាល់សកម្មភាពពាក់ព័ន្ធនឹងឧត្តមប្រយោជន៍របស់អនីតិជន ជាពិសេស ធានានូវសិទ្ធិរស់រានមានជីវិត និងការរីកចម្រើនលូតលាស់ជាអតិបរមា [...] ត្រូវផ្តល់ឱកាសឱ្យអនីតិជនសម្តែងមតិដោយសេរី ហើយទស្សនៈនោះត្រូវបានយកទៅពិចារណា ថ្លឹងថ្លែងស្របទៅតាមអាយុ ការរីកចម្រើនផ្នែករូបកាយ បញ្ញាស្មារតី និងកម្រិតនៃការយល់ដឹងរបស់អនីតិជនចំពោះសកម្មភាពរបស់ |

| | |
|---|---|
| | ខ្លួន។ ត្រូវអនុវត្តទៅតាមនីតិវិធីកុមារមេត្រី[135]។ ត្រូវអនុវត្តការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន និងការសម្រេចផ្តន្ទាទោសអនីតិជនជាវិធានចុងក្រោយ និងមានរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន [...]" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន<br>មាត្រា ៦ | "អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើស ត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅៈ<br>• សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី<br>• សិទ្ធិមិនទទួលការបង្ខិតបង្ខំឱ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង<br>• សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន<br>• សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល<br>• សិទ្ធិទទួលបានការឱ្យដំណឹងអំពីបទចោទប្រកាន់<br>• សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់<br>• សិទ្ធិទទួលបានជំនួយពីមេធាវីដោយស្របតាមលក្ខខណ្ឌនៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីដោយ ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី<br>• សិទ្ធិឱ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្តី ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន<br>• សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់<br>• សិទ្ធិបង្ហាញភស្តុតាង<br>• សិទ្ធិស្នើសុំឱ្យកោះហៅសាក្សី និងសួរសាក្សី<br>• សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ<br>• សិទ្ធិស្នើសុំឱ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ<br>• សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស<br>• សិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន។" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន<br>មាត្រា ៣៩ | "ការឃុំខ្លួនអនីតិជនបណ្តោះអាសន្នជាវិធានការចុងក្រោយ [...]" |

[135] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៤ ចំណុច ៧។

| | |
|---|---|
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៤៧ | "ការពិភាក្សាដេញដោល និងការប្រកាសសាលក្រមរឿងក្តីអនីតិជន ត្រូវធ្វើឡើងក្នុងសវនាការអសាធារណៈ [...]" |
| **ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៤៨** | "[...] ក្នុងកាលៈទេសៈពិសេស មេធាវីរបស់អនីតិជន ភ្នាក់ងារសង្គមកិច្ច ឬព្រះរាជអាជ្ញា អាចស្នើសុំឱ្យតុលាការប្រើប្រាស់របាំងក្នុងពេលសវនាការ ឬប្រើប្រាស់វិធីសមស្របណាមួយក្នុងការស្តាប់ចម្លើយ។" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៤៩ | "ក្នុងករណីតុលាការឃើញថា អនីតិជនជាប់ចោទមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំនៅពេលប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចឱ្យអនីតិជនរួចផុតពីបទចោទប្រកាន់ ហើយបង្គាប់ឱ្យដោះលែងអនីតិជនដែលជាប់ឃុំឃាំងជាបន្ទាន់ ទោះបីមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះឱ្យទៅអ្នកតំណាងដែលច្បាប់បានកំណត់ [...]" |
| **ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៥៤** | "សាលក្រមត្រូវប្រកាសនៅពេលសវនាការ ក្រោយពីធ្វើការពិភាក្សាដេញដោយ ឬនៅពេលសវនាការលើកក្រោយ។ ជាគោលការណ៍សាលក្រមត្រូវប្រកាសជាអសាធារណៈនៅចំពោះមុខអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ភ្នាក់ងារសង្គមកិច្ច និងភាគីដែលមានប្រយោជន៍នៅក្នុងរឿងក្តី។ សាលក្រមអាចប្រកាសកំបាំងមុខអនីតិជនបានក្នុងករណីដែលការប្រកាសសាលក្រមចំពោះមុខធ្វើឱ្យខូចដល់ឧត្តមប្រយោជន៍របស់អនីតិជននោះ។" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៥៧ | "[...] ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេលរង់ចាំការជំនុំជម្រះ សាលាឧទ្ធរណ៍ ឬតុលាការកំពូលត្រូវពិចារណាដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឱ្យមានសេរីភាព។ ក្នុងករណីរឿងក្តីត្រូវបានលើកពេលជំនុំជម្រះ សាលាឧទ្ធរណ៍ ឬតុលាការកំពូលត្រូវពិចារណាផងដែរអំពីការដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឱ្យមានសេរីភាព។" |

យោងតាមអនុសញ្ញាស្តីពីសិទ្ធិកុមារដែលបានកំណត់និយមន័យកុមារថា ជាបុគ្គលទាំងឡាយណាដែលមានអាយុក្រោម ១៨ ឆ្នាំ[136] រដ្ឋភាគីត្រូវព្យាយាមលើកកម្ពស់ឱ្យមានការបង្កើតច្បាប់ នីតិវិធី អាជ្ញាធរ និងស្ថាប័នដែលត្រូវអនុវត្តជាពិសេសចំពោះកុមារជាជនជាប់ចោទ ឬកុមារដែលត្រូវបានទទួលស្គាល់ថាបានបំពានច្បាប់ព្រហ្មទណ្ឌ ហើយជាពិសេស៖

[136] អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ១៖ "សម្រាប់គោលបំណងនៃអនុសញ្ញានេះ កុមារគឺជាមនុស្សមានអាយុក្រោម ១៨ ឆ្នាំ លើកលែងតែក្រោមច្បាប់ដែលត្រូវអនុវត្តចំពោះកុមារ នីតិភាពត្រូវបានកំណត់ទាបជាងនេះ។"

i. ការកំណត់អាយុអប្បបរមាដែលនៅក្រោមអាយុនេះកុមារត្រូវបានសន្មតថាពុំមានសមត្ថភាពអាចបំពានច្បាប់ព្រហ្មទណ្ឌបាន និង
ii. នៅពេលណាដែលសមស្រប និងអាចទៅរួច វិធានការដើម្បីដោះស្រាយជាមួយកុមារមិនត្រូវធ្វើតាមនីតិវិធីតុលាការនោះទេ ដោយសារថាកុមារត្រូវបានការការពារពេញលេញចំពោះសិទ្ធិមនុស្ស និងការការពារផ្នែកច្បាប់[137]។ ម្យ៉ាងទៀតថា ច្បាប់សិទ្ធិមនុស្សអន្តរជាតិលើកកម្ពស់ការប្រើប្រាស់នីតិវិធីក្រៅតុលាការ ក្នុងករណីដែលកុមារត្រូវបានប្ដឹងចោទប្រកាន់ ឬទទួលស្គាល់ថាបានបំពានច្បាប់ព្រហ្មទណ្ឌនៅពេលណាសមស្រប និងជាពិសេសក្នុងករណីនៃបទល្មើសតូចតាច ដូចជាការលួចអីវ៉ាន់នៅតាមហាងលក់ទំនិញ ឬបទល្មើសប៉ះពាល់ទ្រព្យសម្បត្តិដទៃទៀត។[138]

បន្ថែមលើនេះទៀត ចំណាត់ការមួយចំនួន ដូចជា ការថែទាំ របៀបណែនាំ និងដីកាតាមដាន ការពិគ្រោះយោបល់ ការសាកល្បងឱ្យនៅក្រៅឃុំ ការថែទាំដោយអាណាព្យាបាល កម្មវិធីអប់រំ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងមធ្យោបាយផ្សេងៗទៀត ជំនួសការថែទាំតាមស្ថាប័ន ត្រូវធ្វើឱ្យមានដើម្បីធានាថាកុមារទទួលបាននូវចំណាត់ការដែលសមស្របចំពោះសុខុមាលភាពរបស់ខ្លួន និងសមាមាត្រទៅនឹងស្ថានភាពរបស់កុមារ និងបទល្មើស។[139]

អនីតិជន ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ មានសិទ្ធិទទួលបាននូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទាំងអស់ដែលត្រូវអនុវត្តចំពោះមនុស្សពេញវ័យ ក៏ដូចជាមានសិទ្ធិទទួលបានការការពារបន្ថែម ដោយត្រូវពិចារណាសព្វជ្រុងជ្រោយទៅលើអាយុ ភាពចាស់ទុំ និងការអភិវឌ្ឍផ្នែកសតិបញ្ញារបស់កុមារ។ ក.អ.ស.ព.ន និងអនុសញ្ញាស្ដីពីសិទ្ធិកុមារ ("អ.ស.ក") ដែលបានចូលជាធរមានក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩២ មានចែងនូវមាត្រាជាក់លាក់ស្ដីពីការប្រព្រឹត្តចំពោះអនីតិជនក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ។ លិខិតូបករណ៍គតិយុត្តទាំងអស់នេះ បានទទួលការគាំទ្រពីវិធាន និងគោលការណ៍ណែនាំអន្តរជាតិជាច្រើន។ ដូចមានបញ្ជាក់ខាងលើហើយថា បទប្បញ្ញត្តិផ្នែកច្បាប់ជាច្រើនក្នុងច្បាប់កម្ពុជា មានចែងបន្ថែមទៀតអំពីការប្រព្រឹត្តចំពោះអនីតិជនដែលខុសប្លែកពីការប្រព្រឹត្តចំពោះមនុស្សពេញវ័យលើវិស័យសំខាន់ៗជាច្រើន។ ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ត្រូវបានអនុម័តក្នុងឆ្នាំ២០១៦ ដើម្បីធានាសិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជនដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

---

137 មាត្រា ៤០ (៣) នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ។

138 គណៈកម្មាធិការស្ដីពីសិទ្ធិកុមារ សេចក្ដីពន្យល់ទូទៅលេខ ១០ ឆ្នាំ២០០៧ វាក្យខណ្ឌ ២៤ ២៥ https://www2.ohchr.org/english/bodies/crc/docs/CRC.C.GC.10.pdf ("អនុសញ្ញាស្ដីពីសិទ្ធិកុមារ សេចក្ដីពន្យល់ទូទៅលេខ ១០") គណៈកម្មាធិការស្ដីពីសិទ្ធិកុមារ គឺជាស្ថាប័នផ្លូវការបង្កើតឡើងដោយ មាត្រា ៤៣ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារដើម្បីពិនិត្យលើវឌ្ឍនភាពដែលរដ្ឋភាគីសម្រេចបានទាក់ទងនឹងអនុសញ្ញាស្ដីពីសិទ្ធិកុមារ និងដើម្បីផ្ដល់មតិយោបល់ និងអនុសាសន៍លើអនុសញ្ញាស្ដីពីសិទ្ធិកុមារ (មាត្រា ៤៥ (ឃ))។

139 អនុសញ្ញាស្ដីពីសិទ្ធិកុមារ មាត្រា ៤០ (៤)។

### *តួលេខទី ១៩៖ អាយុជនជាប់ចោទនៅក្នុងពេលបើកសវនាការ*[140]




នៅគ្រប់សំណុំរឿងទាំងអស់ដែលពាក់ព័ន្ធនឹងអនីតិជនដែល ម.ស.ម.ក បានសង្កេតការណ៍នៅក្នុងអំឡុងពេលធ្វើបាយការណ៍ ជនជាប់ចោទមានអាយុចាប់ពី ១៦-១៧ឆ្នាំ។ នេះបង្ហាញអំពីភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ បើធៀបនឹងឆ្នាំ២០១៦/២០១៧ ដែលមានជនជាប់ចោទចំនួន ៤ នាក់ជាអនីតិជនមានអាយុក្រោម ១៥ ឆ្នាំ។

ក្នុងអំឡុងពេលធ្វើបាយការណ៍ ក្នុងចំណោមជនជាប់ចោទទាំង ៣១៥ នាក់ ពាក់ព័ន្ធក្នុងសំណុំរឿងដែល ម.ស.ម.ក បានសង្កេតការណ៍មានជនជាប់ចោទចំនួន ៩ នាក់ហើយដែលជាអនីតិជននៅក្នុងពេលប្រព្រឹត្តបទល្មើស។ ជនជាប់ចោទចំនួន ៧ ក្នុងចំណោមនោះ ត្រូវបានឃុំខ្លួន។

### *តួលេខទី ២០៖ ចំនួនអនីតិជនត្រូវបានឃុំខ្លួននៅចន្លោះឆ្នាំ២០១៤-២០១៨*




ឧត្តមប្រយោជន៍របស់កុមារ ចាំបាច់ត្រូវតែជាការពិចារណាជាចម្បងនៅពេលចេញសេចក្តីបញ្ជា ឬបង្គាប់ឱ្យមានការផ្តន្ទាទោសលើអនីតិជនដែលត្រូវបានរកឃើញថា បានបំពានច្បាប់ព្រហ្មទណ្ឌ។[141] ការឃុំខ្លួន

[140] ទិន្នន័យនេះគឺផ្អែកលើចំនួនជនជាប់ចោទជាអនិតិជនសរុប (៩ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ៨ ដែលបានសង្កេតការណ៍។
[141] មាត្រា ៣(១) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។ *សូមមើលផងដែរ* គណៈកម្មាធិការស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ១០ និង ៧១។

អនីតិជន គឺត្រូវបានចាត់ទុកថាជាជម្រើសចុងក្រោយបំផុត ហើយគួរត្រូវបានយកមកអនុវត្តតែក្នុងករណីពិសេសតែប៉ុណ្ណោះ។[142] ច្បាប់ជាតិ ក៏ចែងឱ្យមានវិធានផ្សេងទៀតក្រៅពីការកាត់ទោសជាប់ពន្ធនាគារផងដែរ។[143]

ហេតុនេះ តួលេខខាងលើបង្ហាញពីការព្រួយបារម្ភយ៉ាងខ្លាំង ព្រមទាំងការមិនអនុលោមតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិដោយហេតុថា ការឃុំខ្លួនអនីតិជនជាបណ្តោះអាសន្ន ហាក់ធ្វើឡើងជាទម្លាប់ជាជាងជាវិធានការចុងក្រោយបំផុត។ សាលាឧទ្ធរណ៍ ពុំបានទាញប្រយោជន៍ពីជម្រើសការកាត់ទោសជាជម្រើសជំនួស ដូចមានចែងក្នុងមាត្រា ៤០ នៃក្រមព្រហ្មទណ្ឌ និងនៅក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ក្នុងមាត្រា ២៨ នៃជំពូក ១០ ស្តីពីការបង្វែរ ដូចជាការដាក់អនីតិជនទៅក្នុងទីភ្នាក់ងារសេវាសង្គម ឬទៅកាន់អង្គការឯកជនមាននីតិសម្បទា ឬដាក់ក្នុងមន្ទីរពេទ្យ ឬស្ថាប័នឯកទេសជាដើម។ សាលាឧទ្ធរណ៍ក៏មិនបានអនុវត្តស្របតាមមាត្រា ៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនដែលតម្រូវឱ្យជនទាំងឡាយក្នុងមុខងារសាធារណៈដែលជាប់ទាក់ទងជាមួយអនីតិជន ត្រូវធ្វើសកម្មភាពដើម្បីឧត្តមប្រយោជន៍របស់អនីតិជន និងជាពិសេស គឺសិទ្ធិទទួលបានការអភិវឌ្ឍរបស់អនីតិជន ហើយដែលចែងថា ការចាប់ខ្លួន ឬការឃុំខ្លួនអនីតិជន គួរត្រូវបានប្រើប្រាស់ជាជម្រើសចុងក្រោយបំផុត។

នៅក្រោមច្បាប់សិទ្ធិមនុស្ស អនីតិជនមានសិទ្ធិទទួលបានការគោរពចំពោះភាពជាឯកជនរបស់ខ្លួននៅគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធី។[144] សិទ្ធិនេះ រួមមានចាប់តាំងពីការចូលមកពាក់ព័ន្ធជាដំបូងជាមួយមន្ត្រីអនុវត្តច្បាប់រហូតដល់សេចក្តីសម្រេចជាស្ថាពរ ឬប្រសិនបើត្រូវបានកាត់ឱ្យជាប់ទោស ការរួចផុតពីការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ការឃុំខ្លួន ឬការដកហូតសេរីភាព។[145] មូលដ្ឋានហេតុផលដែលធ្វើឱ្យមានការអនុវត្តបែបនេះ គឺដើម្បីចៀសវាងការបង្កគ្រោះថ្នាក់តាមរយៈការបង្ហាញព័ត៌មានជាសាធារណៈមិនសមស្រប ឬការធ្វេសប្រហែស។ ហេតុនេះ គ្មានព័ត៌មានណាមួយត្រូវបានបង្ហាញជាសាធារណៈទាក់ទងជាមួយអត្តសញ្ញាណរបស់ជនល្មើសជាកុមារឡើយ។[146] ភាពជាឯកជនរបស់ជនរងគ្រោះ ឬជនដែលរងការចោទប្រកាន់ជាអនីតិជន អាចត្រូវបានការពារបន្ថែមទៀតតាមរយៈការដាក់អនីតិជនឱ្យនៅខាងក្រោយរបាំង ឬប្រើប្រាស់មធ្យោបាយជាជម្រើសជំនួសដទៃទៀតក្នុងការផ្តល់សក្ខីកម្ម។ ការប្រើប្រាស់ឧបករណ៍នានា ដូចជាប្រព័ន្ធឆ្លើយឆ្លងតាមវីដេអូ ឬសវនាការបិទទ្វារ គួរត្រូវបានពិចារណាយកមកអនុវត្ត។

[142] មាត្រា ៣៧(ខ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

[143] ក្រមព្រហ្មទណ្ឌ មាត្រា ៤០។

[144] អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៤០(២)(vii)។

[145] អនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ១០ វាក្យខណ្ឌ ៦៤។

[146] អនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ១០ វាក្យខណ្ឌ ៦៤។

## *តួលេខទី ២១៖ ការការពារឯកជនភាពរបស់អនីតិជន*[147]

**តើមានវិធានការការពារឯកជនភាពរបស់ជនជាប់ចោទជាអនីតិជននៅក្នុងសវនាការដែរ ឬទេ?**




ពុំមានការអនុវត្តនូវវិធានការណាមួយត្រូវបានធ្វើឡើង ដើម្បីគោរពភាពជាឯកជនរបស់អនីតិជននៅក្នុងសំណុំរឿង ដែលពាក់ព័ន្ធជាមួយអនីតិជនដែលយើងបានសង្កេតការណ៍ឡើយ ហើយនេះជាទង្វើមិនស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ លើសពីនេះទៅទៀត គ្រប់សវនាការទាំងអស់សុទ្ធតែបើកចំហសម្រាប់សាធារណជន។ នេះជាបញ្ហាសំខាន់ដែលសិទ្ធិឯកជនភាពរបស់អនីតិជននៅពេលសវនាការរឿងក្តីព្រហ្មទណ្ឌនេះត្រូវបានលើកយកមកពិភាក្សាយ៉ាងទូលំទូលាយជាមួយអនុប្រធានសាលាឧទ្ធរណ៍នៅក្នុងខែមេសា ឆ្នាំ២០១៧[148] ហើយសាលាឧទ្ធរណ៍បានលើកឡើងថានឹងពិនិត្យឡើងវិញលើការអនុវត្តនេះ ដោយមិនត្រឹមតែការពារឯកជនភាពរបស់អនីតិជនជាជនជាប់ចោទប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការពារឯកជនភាពរបស់អនីតិជនជាជនរងគ្រោះ និងជាសាក្សីផងដែរ ដើម្បីអនុលោមតាមបទដ្ឋានជាតិ និងអន្តរជាតិ។ គួរឱ្យសោកស្តាយខ្លាំងបំផុត បើទោះបីជាមានកិច្ចខិតខំប្រឹងប្រែងបែបនេះក៏ដោយ ប៉ុន្តែសិទ្ធិរបស់អនីតិជននៅតែប្រឈមនឹងមិនបានធានាពេញលេញជាប្រចាំនៅសាលាឧទ្ធរណ៍។

---

[147] ទិន្នន័យនេះគឺផ្អែកលើចំនួនជនជាប់ចោទជាអនិតិជនសរុប (៩ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ៨ ដែលបានសង្កេតការណ៍។

[148] ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៨ ក្រុមការងារគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ បានជួបជាមួយអនុប្រធានសាលាឧទ្ធរណ៍ ឯកឧត្តម ប្លង់ សំណាង ឯកឧត្តម ញូង ធុល ព្រមទាំងអគ្គលេខាធិការរងរដ្ឋបាល លោកស្រី ស្រេង សូយ៉េត ដើម្បីពិភាក្សាលើរបកគំឃើញនៅក្នុងរបាយការណ៍ ឆ្នាំ២០១៦/២០១៧។

### *តួលេខទី ២២៖ ការវិវឌ្ឍនៃការការពារឯកជនភាពរបស់អនីតិជនចាប់តាំងពីឆ្នាំ២០១៤* [149]




នៅអំឡុងពេលការជួបពិភាក្សារវាងក្រុមការងារ ម.ស.ម.ក ជាមួយភាគីសាលាឧទ្ធរណ៍ ភាគីសាលាឧទ្ធរណ៍បានបញ្ជាក់ថា ទាក់ទងនឹងរឿងក្តីអនីតិជន សាលាឧទ្ធរណ៍មានបំពាក់នូវឧបករណ៍ឆ្លើយឆ្លងតាមវីដេអូដែលទទួលបានពីអង្គការយូនីសេហ្វ (UNICEF) ដើម្បីការពារឯកជនភាពរបស់កុមារ ដូច្នោះវាមិនមានភាពអវិជ្ជមានដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះឡើយ។ ភាគីសាលាឧទ្ធរណ៍ក៏បានស្នើដល់ ម.ស.ម.ក កត់ត្រារាល់លេខសំណុំរឿង និងឈ្មោះចៅក្រមដែលអនុវត្តមិនទាន់បានពេញក្នុងការលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ រួមទាំងសំណុំរឿងអនីតិជនដែលមិនបានការពារឯកជនភាពរបស់ពួកគេនៅពេលសវនាការ និងរាយការណ៍ជូនប្រធានសាលាឧទ្ធរណ៍បានគ្រប់ពេល ដើម្បីធ្វើការដោះស្រាយបញ្ហានោះឱ្យបានទាន់ពេល។ម្យ៉ាងវិញទៀត ចំពោះការអនុវត្តនីតិវិធីបង្វែរសម្រាប់អនីតិជន គឺមិនទាន់អាចអនុវត្តបានទេ ពីព្រោះយន្តការគាំទ្រដំណើរការនេះមិនទាន់មាននៅឡើយ។[150]

---

[149] ទិន្នន័យនេះគឺផ្អែកលើចំនួនជនជាប់ចោទជាអនិតិជនសរុប (៩ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ៨ ដែលបានសង្កេតការណ៍។

[150] នៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១៩ ម.ស.ម.ក បានជួបជាមួយប្រធាន អនុប្រធានទាំងអស់ អគ្គព្រះរាជអាជ្ញា តំណាងចៅក្រម ព្រមទាំងអគ្គលេខាធិការរដ្ឋបាលនៅសាលាឧទ្ធរណ៍ ដើម្បីពិភាក្សាលើរបកគំហើញនៅក្នុងរបាយការណ៍នេះ។

# ៥ .សេចក្តីសន្និដ្ឋាន

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលត្រូវបានធានានៅចំពោះមុខសាលាឧទ្ធរណ៍ រួមមានសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី និងសិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ។ លើសពីនេះទៅទៀត សាលាឧទ្ធរណ៍ក៏បានលើកកម្ពស់ការការពារប្រឆាំងនឹងការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែល និងការហាមឃាត់ការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ផងដែរ។ គួររម្លឹកផងដែរថាឆ្នាំ២០១៧/២០១៨ បានបង្ហាញនូវភាពប្រសើរឡើងគួរឱ្យកត់សម្គាល់នៅក្នុងការអនុវត្តនូវការការពារខ្លួនប្រឆាំងការឆ្លើយដាក់បន្ទុកលើខ្លួនឯង (សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព) ក្នុងសំណុំរឿងដែល ម.ស.ម.ក បានសង្កេតការណ៍។

ប៉ុន្តែយ៉ាងណាក៏ដោយ ការសង្កេតការណ៍នេះក៏បានរកឃើញការអនុវត្តមិនបានពេញលេញចំពោះសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាមូលដ្ឋានមួយចំនួនផងដែរ រួមមានសិទ្ធិក្នុងការទទួលបានការជំនុំជម្រះជាសាធារណៈ ដោយហេតុថាពុំមានសវនាការណាមួយក្នុងចំណោមសវនាការដែល ម.ស.ម.ក បានសង្កេតការណ៍បានបិទផ្សាយជូនដំណឹងអំពីកាលវិភាគសវនាការនៅលើក្តារខៀនព័ត៌មានក្រៅបន្ទប់សវនាការឡើយ ដែលធ្វើឱ្យសារធាណជនទូទៅមិនបានដឹងអំពីសវនាការ។ ជាងនេះទៅទៀត សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ គឺមិនដូចគ្នាទៅនឹងឆ្នាំ២០១៦/២០១៧ ឡើយ ដែលត្រូវបានចាត់ទុកថាសិទ្ធិនេះមិនបានធានាឱ្យបានពេញលេញនៅឡើយ ដោយហេតុថា ចំនួនភាគរយនៃសំណុំរឿងដែលជនជាប់ចោទត្រូវបានប្រាប់អំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ បានធ្លាក់ចុះពី ៨៦% មកត្រឹម ៦៩% បើធៀបទៅនឹងសំណុំរឿងដែលបានសង្កេតការណ៍កាលពីឆ្នាំកន្លងទៅ។ សិទ្ធិមានមេធាវីរបស់ជនជាប់ចោទជានីតិជនសម្រាប់បទមជ្ឈិមមិនតែងតែត្រូវបានគោរពជានិច្ចនោះទេ ដែលការណ៍នេះច្បាប់ជាតិអនុញ្ញាតឱ្យចៅក្រមដំណើរការសវនាការបានប្រសិនបើជនជាប់ចោទមិនត្រូវការមេធាវីតំណាង តែអនុវត្តបែបនេះមិនស្របតាមបទដ្ឋាននៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលចែងថាសិទ្ធិមានមេធាវីគឺសម្រាប់គ្រប់ប្រភេទបទល្មើសព្រហ្មទណ្ឌទាំងអស់។ ប្រហែលជា ២៥% នៃជនជាប់ចោទជានីតិជនក្នុងសំណុំរឿងនៃបទមជ្ឈិមដែល ម.ស.ម.ក បានសង្កេតការណ៍ពុំមានមេធាវីតំណាងឡើយ។

លើសពីនេះទៅទៀត នៅក្នុងសំណុំរឿងចំនួន ៣៤ នៃសំណុំរឿងចំនួន ២១៣ សំណុំរឿងដែល ម.ស.ម.ក បានសង្កេតការណ៍ ចៅក្រមពុំបានប្រាប់ និងពន្យល់ជនជាប់ចោទអំពីសិទ្ធិមានមេធាវីឡើយ ដែលនេះគឺជានិន្នាការមួយគួរឱ្យព្រួយបារម្ភ។ ស្រដៀងគ្នានេះដែរ សិទ្ធិសន្មតទុកជាមុនថាគ្មានទោសនៅតែមិនបានធានាពេញលេញនៅឡើយដោយហេតុថាជនជាប់ចោទ ចំនួន២៦% បង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានទណ្ឌិតនៅក្នុងពេលសវនាការ។ ភាគច្រើនដូចគ្នាទៅនឹងឆ្នាំមុនៗដែរ ការគោរពចំពោះសិទ្ធិទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុគឺនៅតែជាបញ្ហាស្ទើរគ្រប់សវនាការទាំងអស់ដែល ម.ស.ម.ក បានសង្កេតការណ៍ការប្រកាសសាលដីកាក្នុងពេល ម.ស.ម.ក ធ្វើការសង្កេតការណ៍ ចៅក្រមពុំបានបញ្ជាក់លម្អិត និងច្បាស់លាស់

ពីមាត្រាច្បាប់ និងភស្តុតាងដែលខ្លួនប្រើប្រាស់ជាមូលដ្ឋានដើម្បីឈានដល់ការសម្រេចចេញសាលដីការបស់ខ្លួនឡើយ ដែលករណីនេះបានកើនឡើងយ៉ាងខ្លាំងជាង ២០១៦/២០១៧។ ផ្ទុយមកវិញ ចៅក្រមគ្រាន់តែបញ្ជាក់ថាសេចក្តីសម្រេចរបស់សាលាដំបូង ត្រូវបានរក្សាទុកដដែល ឬត្រូវបានច្រានចោលដោយពុំមានពន្យល់ប្រាប់មូលហេតុឱ្យបានលម្អិត និងច្បាស់លាស់ឡើយ។ ជាចុងក្រោយសិទ្ធិរបស់ជនជាប់ចោទជាអនីតិជនដែលត្រូវបានការពារជាពិសេសនៅក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់កម្ពុជា ជារឿយៗពុំបានយកចិត្តទុកដាក់ឱ្យបានគ្រប់គ្រាន់នៅឡើយនោះទេ ដោយហេតុថាពុំមានការអនុវត្តនូវវិធានការជាក់លាក់ណាមួយត្រូវបានដាក់ចេញដើម្បីការពារសិទ្ធិរបស់អនីតិជនឡើយ ជាពិសេស គឺឯកជនភាពរបស់ពួកគេ។

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗ ដែលត្រូវបានសាលាឧទ្ធរណ៍គោរពតាមយ៉ាងខ្ជាប់ខ្ជួនចាប់តាំងពីឆ្នាំ២០១៤ មក រួមមាន៖

- សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការការពារក្តី
- សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ
- ការហាមឃាត់ការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ និង
- ការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល។

ប៉ុន្តែគួរឱ្យសោកស្តាយ សិទ្ធិផ្សេងទៀតក្នុងចំនួនដូចគ្នានេះដែរ មិនត្រូវបានគោរពឱ្យពេញលេញនៅឡើយចាត់តាំងពីឆ្នាំ២០១៤ មកដែរ៖

- សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ
- សិទ្ធិបង្ហាញភស្តុតាង
- សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ និង
- សិទ្ធិរបស់អនីតិជន។

បញ្ហានេះ បានបង្កឱ្យមានក្តីបារម្ភយ៉ាងខ្លាំង ជាពិសេស គឺត្រង់ចំណុចដែលថាបញ្ហាទាំងនោះបានដឹងឮដោយអាជ្ញាធររួចទៅហើយនៅក្នុងករណីជាច្រើន។

នៅពេលយើងប្រៀបធៀបនូវរបកគំហើញពីចន្លោះឆ្នាំ ២០១៤/២០១៥ ជាមួយនឹងរបកគំហើញនៅក្នុងរបាយការណ៍ពេលបច្ចុប្បន្ន ចំណុចរកឃើញជាច្រើនមានលក្ខណៈប្រហាក់ប្រហែលគ្នា ដែលសិទ្ធិមួយចំនួនត្រូវបានការពារ និងសិទ្ធិមួយចំនួនទៀតមិនត្រូវបានគោរពពេញលេញនៅឡើយ។ ប៉ុន្តែរបកគំហើញពីចំណុចដែលខុសគ្នា៖ ទីមួយ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ដែល ម.ស.ម.ក បានរកឃើញថាត្រូវបានការពារនៅក្នុងឆ្នាំ២០១៤/២០១៥ និងឆ្នាំ២០១៦/២០១៧ ដែលត្រូវបានប្តូរទៅផ្នែកដែល "ប្រឈមនឹងការការពារមិនបានពេញលេញ" ដោយសារតែចំនួនភាគរយនៃសំណុំរឿងដែលជនជាប់ចោទ ត្រូវបានប្រាប់អំពីការចោទប្រកាន់ទាំងអស់ដែលពាក់ព័ន្ធប្រឆាំងនឹងពួកគេបានធ្លាក់ចុះពី ៨៥% (២០១៤/២០១៥) និង

៨៦% (២០១៦/២០១៧) មកត្រឹមតែ ៦៩% ប៉ុណ្ណោះ។ នេះអាចបណ្តាលមកពីកត្តាមួយចំនួន រួមមាន ចំនួន ឬប្រភេទនៃសំណុំរឿងដែល ម.ស.ម.ក បានសង្កេតការណ៍ ប៉ុន្តែទោះជាយ៉ាងណាក្តី នេះនៅតែជារបកគំហើញដែលមានបញ្ហាដោយសារតែសិទ្ធិដឹងអំពីការចោទប្រកាន់ គឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ជាសិទ្ធិជាមូលដ្ឋានសំខាន់បំផុត។

ទីពីរ និងកាន់តែមានលក្ខណៈវិជ្ជមាន ការការពារសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព (ការការពារខ្លួនប្រឆាំងការឆ្លើយដាក់បន្ទុកលើខ្លួនឯង) ដែលត្រូវបានកំណត់ថា "ប្រឈមនឹងការការពារមិនបានពេញលេញ" នៅក្នុងឆ្នាំ២០១៤/២០១៥ និងឆ្នាំ២០១៦/២០១៧ ប៉ុន្តែមានភាពល្អប្រសើរគួរឱ្យកត់សម្គាល់នៅក្នុងឆ្នាំ២០១៧/២០១៨ មានសំណុំរឿងជាច្រើនដែលការសារភាពទទួលបានដោយពុំមានការបង្ខិតបង្ខំក្នុងទម្រង់ណាមួយឡើយ បានកើនឡើងរហូតដល់ ៩៥% (ផ្ទុយគ្នាបើធៀបនឹង ៨៨% នៅក្នុងឆ្នាំ២០១៦/២០១៧)។ ទោះជាយ៉ាងណាក៏ដោយ គួរកត់សម្គាល់ថាមានជនជាប់ចោទចំនួន ២១ នាក់បានលើកឡើងថាការសារភាពទោសរបស់ពួកគេ ត្រូវបានទទួលតាមរយៈស្ថានភាពបង្ខិតបង្ខំ រួមទាំង ការគំរាមកំហែង និងអំពើហិង្សាដោយនគរបាលយុត្តិធម៌ ដែលចំណុចនេះនៅតែជាបញ្ហាគួរឱ្យព្រួយបារម្ភខ្លាំងនៅឡើយ។ សំណុំរឿងបែបនេះ ត្រូវតែមានការស៊ើបអង្កេតជាបន្ទាន់ឱ្យបានហ្មត់ចត់ដោយអាជ្ញាធរមានសមត្ថកិច្ច។

ភស្តុតាងទាំងនេះបង្ហាញឱ្យឃើញថា ចាំបាច់ត្រូវតែមានវិធានការជាបន្ទាន់ដើម្បីការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា។ ផ្នែកខាងក្រោមនេះ គឺជាអនុសាសន៍សំខាន់ៗដើម្បីជួយរដ្ឋាភិបាល និងអាជ្ញាធរបន្តអនុវត្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន។

# ៦. អនុសាសន៍

ជាទូទៅ បញ្ហាភាគច្រើនដែលត្រូវបានគូសបញ្ជាក់ក្នុងរបាយការណ៍នេះអាចដោះស្រាយបានតាមរយៈវិធានការងាយៗ ចំណាយអស់តិច និងអាចអនុវត្តបានយ៉ាងឆាប់រហ័ស។ ឧទាហរណ៍ ការសម្របសម្រួលកែលម្អទាក់ទងជាមួយការដឹកជញ្ជូនជនជាប់ចោទពីមណ្ឌលកែប្រែទៅចូលរួមសវនាការ ការសុំឱ្យសាក្សីចាកចេញពីបន្ទប់សវនាការមុនពេលចូលមកផ្តល់សក្ខីកម្មក្នុងសវនាការ និងការតម្រូវឱ្យចៅក្រមត្រូវពន្យល់ប្រាប់ជនជាប់ចោទអំពីសិទ្ធិរបស់គេជាដើម។ បញ្ហាមួយចំនួនទៀតនឹងធ្វើឱ្យកាន់តែប្រសើរឡើងបានយ៉ាងងាយស្រួលតាមរយៈការបណ្តុះបណ្តាលចៅក្រម និងមេធាវីទាក់ទងជាមួយការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ជាចុងក្រោយនេះ ម.ស.ម.ក ស្វាគមន៍ចំពោះការចេញព្រះរាជក្រឹត្យបង្កើតសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ តំបន់បាត់ដំបង និងតំបន់ព្រះសីហនុ។ ព្រោះថាការបង្កើតសាលាឧទ្ធរណ៍បន្ថែមនេះនឹងអាចដោះស្រាយបញ្ហាមួយចំនួនដែលបានលើកឡើងខាងលើ។ តាមរយៈការចាត់វិធានការចំពោះមុខដើម្បីដោះស្រាយកង្វល់ទាំងអស់នេះ សាលាឧទ្ធរណ៍អាចបង្កើតយុត្តិសាស្ត្រ ដើរតួជាគំរូដល់សាលាដំបូងផ្សេងៗទៀត ព្រមទាំងអាចជះឥទ្ធិពលជាវិជ្ជមានលើគុណភាពជាទូទៅនៃការផ្តល់យុត្តិធម៌ក្នុងប្រទេសកម្ពុជា និងអាចចូលរួមចំណែកគួរជាទីកត់សម្គាល់ដើម្បីពង្រឹងនីតិរដ្ឋ។

## ៦.១. អនុសាសន៍ទូទៅ

៦.១.១.ក្រសួងយុត្តិធម៌គួរមានការពិភាក្សាជាទៀងទាត់ជាមួយចៅក្រមសាលាឧទ្ធរណ៍ ស្តីពីការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌បែបអនុវត្តជាក់ស្តែង ផ្អែកតាមទស្សនាទានស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌អនុលោមតាមបទដ្ឋានជាតិ និងអន្តរជាតិ។

៦.១.២.ក្រសួងយុត្តិធម៌គួរបង្កើត និងដាក់ឱ្យអនុវត្តទម្រង់បទដ្ឋានមួយសម្រាប់សេចក្តីសម្រេចដើម្បីប្រើប្រាស់នៅក្នុងតុលាការទាំងអស់។ ព័ត៌មានដូចខាងក្រោមត្រូវបានបញ្ចូលដើម្បីធានាឱ្យបានថារបាយការណ៍សង្ខេបដែលអានដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះនោះជារបាយការណ៍ពេញលេញដូចជា៖

- បទល្មើសដែលជនជាប់ចោទត្រូវបានចោទ និងច្បាប់ពាក់ព័ន្ធ
- កាលបរិច្ឆេទ ពេលវេលា ទីតាំងនៃបទល្មើស និងភាគីដែលពាក់ព័ន្ធ
- សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលជនជាប់ចោទមានសិទ្ធិបានទទួល ដូចមានចែងក្នុងទំព័រទី ១២ នៃរបាយការណ៍នេះ។ ជាពិសេស សិទ្ធិរបស់ជនជាប់ចោទទទួលបានការសន្មតជាមុនថាគ្មានទោស រហូតដល់សេចក្តីសម្រេចស្ថាពរ និងបន្ទុកភស្តុតាងដែលត្រូវជាបន្ទុករបស់អយ្យការ។

៦.១.៣.ចៅក្រមគួរសួរទៅជនជាប់ចោទដោយផ្ទាល់ ថាតើយល់អំពីបទចោទប្រកាន់ និងអំពីសិទ្ធិរបស់ខ្លួនដែរឬទេ។ ការខកខានក្នុងការអានព័ត៌មានខាងលើនៅពេលចាប់ផ្តើមការជំនុំជម្រះ នាំឱ្យមានមូលដ្ឋានប្តឹងតវ៉ានឹងសេចក្តីសម្រេចឱ្យមានពិរុទ្ធភាព។

## ៦.២. អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ

៦.២.១.សាលាឧទ្ធរណ៍ និងក្រសួងយុត្តិធម៌ គួរធានាឱ្យបានថាកាលវិភាគប្រចាំថ្ងៃរបស់សវនាការទាំងអស់ត្រូវបានបិទផ្សាយនៅលើក្តារខៀនព័ត៌មានខាងក្រៅបន្ទប់សវនាការ ហើយបន្តធានាលទ្ធភាពរបស់សាធារណជនអាចចូលមកក្នុងបន្ទប់សវនាការបានទាំងអស់ លើកលែងតែក្នុងករណីពិសេស ដែលអាចរួមមានករណីអនីតិជន ពេលដែលព័ត៌មានទាំងអស់នេះត្រូវបានបិទផ្សាយនៅលើក្តារខៀនព័ត៌មាន ឈ្មោះរបស់អនីតិជនមិនគួរត្រូវបានសរសេរចេញមកឡើយ ហើយគួរតែហៅអនីតិជនដោយប្រើអក្សរដើមនៃឈ្មោះដើម្បីការពារឯកជនភាពរបស់គេ។

## ៦.៣. អនុសាសន៍ទាក់ទងនឹងសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់

៦.៣.១.ចៅក្រមសាលាឧទ្ធរណ៍គួរប្រាប់ជនជាប់ចោទអំពីបទចោទប្រកាន់ប្រឆាំងនឹងពួកគេ និងផ្តល់ព័ត៌មានដែលពាក់ព័ន្ធ ដូចជា ការបរិច្ឆេទ ទីកន្លែង ភាគីពាក់ព័ន្ធ និងច្បាប់ដែលត្រូវយកមកអនុវត្ត។ ការប្រាប់នេះគឺសំខាន់បំផុត ក្នុងករណីដែលបទចោទប្រកាន់អាចត្រូវបានប្តូរ ឬត្រូវបានកែប្រែ ចាប់តាំងពីការឃាត់ខ្លួន/ការចោទប្រកាន់ដំបូង។

៦.៣.២.ចៅក្រមសាលាឧទ្ធរណ៍គួរផ្តល់ការពន្យល់ឱ្យបានច្បាស់អំពីសិទ្ធិទទួលបានការជំនុំជម្រះរបស់ជនជាប់ចោទ។

៦.៣.៣.ចៅក្រមសាលាឧទ្ធរណ៍គួរសួរជនជាប់ចោទដោយផ្ទាល់ថា តើជនជាប់ចោទយល់អំពីបទចោទប្រកាន់ប្រឆាំងនឹងពួគេ និងសិទ្ធិរបស់ពួកគេហើយឬនៅ។

## ៦.៤. អនុសាសន៍ទាក់ទងនឹងសិទ្ធិមានវត្តមាននៅពេលសវនាការ និងមានមេធាវី

៦.៤.១.សាលាឧទ្ធរណ៍ និងអគ្គនាយកដ្ឋានពន្ធនាគារត្រូវពិគ្រោះយោបល់ និងសម្របសម្រួលជាមួយគ្នាដើម្បីដោះស្រាយបញ្ហាភស្តុភារ និងបញ្ហាការប្រាស្រ័យទាក់ទងឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបានទាក់ទងជាមួយទីតាំងឃុំខ្លួនរបស់ជនជាប់ចោទចោទ ជាពិសេសគឺ៖

- អគ្គនាយកដ្ឋានពន្ធនាគារចាំបាច់ត្រូវធានាឱ្យបានថាព័ត៌មានស្តីពីការផ្ទេរជនជាប់ឃុំត្រូវបានបញ្ជូនមកឱ្យអយ្យការជាទៀងទាត់។

- សាលាឧទ្ធរណ៍ចាំបាច់ត្រូវជានាឱ្យបានថាព័ត៌មានទាក់ទងជាមួយកាលបរិច្ឆេទ និងពេលវេលាសវនាការ ត្រូវបានបញ្ជូនទៅដល់មណ្ឌលកែប្រែដែលជាកន្លែងជនជាប់ចោទត្រូវបានឃុំខ្លួនឱ្យបានត្រឹមត្រូវ។

៦.៤.២.ចៅក្រមសាលាឧទ្ធរណ៍គួរពន្យារពេលសវនាការ ប្រសិនបើជនជាប់ចោទពុំមានវត្តមានក្នុងសវនាការ បើទោះបីជា ជនជាប់ចោទនោះមានមេធាវីតំណាងក៏ដោយ លើកលែងតែជនជាប់ចោទបានបោះបង់សិទ្ធិមានវត្តមាននៅសវនាការរបស់ខ្លួនយ៉ាងជាក់ច្បាស់ និងជាផ្លូវការ។

## ៦.៥. អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស

៦.៥.១.ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃត្រូវចេញ និងផ្សព្វផ្សាយនូវគោលការណ៍ណែនាំយ៉ាងច្បាស់លាស់ដោយគូសបញ្ជាក់ថា ជនជាប់ឃុំដែលរង់ចាំសវនាការ ឬជនដែលត្រូវបានជំនុំជម្រះហើយ ប៉ុន្តែសាលក្រម ឬសាលដីកាស្ថាពរមិនទាន់ស្ថាពរ ចាំបាច់ត្រូវបានអនុញ្ញាតឱ្យបង្ហាញខ្លួនក្នុងសវនាការដោយស្លៀកសម្លៀកបំពាក់ស៊ីវិល។

៦.៥.២.ចៅក្រមសាលាឧទ្ធរណ៍គួរអនុញ្ញាតជនជាប់ចោទដែលត្រូវបាននាំមកតុលាការ ដែលស្លៀកសំលៀកបំពាក់ទណ្ឌិតឱ្យប្តូរសំលៀកបំពាក់នោះចេញ ហើយជំនួសដោយសំលៀកបំពាក់ស៊ីវិលវិញមុននឹងចូលរួមដំណើរការសវនាការរបស់ខ្លួន។

៦.៥.៣.ចៅក្រមសាលាឧទ្ធរណ៍ចាំបាច់ ត្រូវប្រាប់ដល់ជនជាប់ចោទឱ្យបានជាក់ច្បាស់អំពីសិទ្ធិត្រូវបានសន្មតថាគ្មានទោសរបស់ជនជាប់ចោទរហូតដល់ពេលចេញសាលដីកាស្ថាពរ ត្រូវប្រាប់ឱ្យជនជាប់ចោទបានដឹងថាបន្ទុកភស្តុតាងគឺជាកាតព្វកិច្ចរបស់អយ្យការ និងប្រាប់ឱ្យបានដឹងថាជនជាប់ចោទមានសិទ្ធិនៅស្ងៀម ហើយការនៅស្ងៀមនេះនឹងមិនត្រូវបានប្រើប្រាស់ប្រឆាំងរូបគាត់ឡើយ។

៦.៥.៤.លើកកម្ពស់ឱ្យមានការប្រើប្រាស់ជម្រើសផ្សេងពីការឃុំខ្លួនបណ្តោះអាសន្ន រួមទាំង មានការត្រួតពិនិត្យតាមផ្លូវតុលាការ[151] ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិលេខ ១៦.៣.២។

៦.៥.៥.ជូនដំណឹងដល់សាធារណជនអំពីសិទ្ធិទទួលបានជំនួយផ្លូវច្បាប់ពីរដ្ឋ រួមទាំង តាមរយៈការបិទផ្សាយនៅនឹងអគារប៉ុស្តិ៍នគរបាល ពន្ធនាគារ និងតុលាការ។

[151] នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ សេចក្តីថ្លែងបញ្ចប់បេសកកម្មរបស់ UNSRSHRC ទំព័រ ៤។

## ៦.៦. អនុសាសន៍ទាក់ទងនឹងសិទ្ធិបង្ហាញភស្តុតាង

៦.៦.១.ចៅក្រមសាលាឧទ្ធរណ៍ត្រូវប្រាប់ដល់ជនជាប់ចោទ អំពីសិទ្ធិបង្ហាញភស្តុតាងនៅក្នុងលក្ខខណ្ឌដូចគ្នាជាមួយភស្តុតាងដែលត្រូវបានបង្ហាញដើម្បីប្រឆាំងនឹងខ្លួនឯង។

៦.៦.២.ចៅក្រមសាលាឧទ្ធរណ៍ត្រូវបង្គាប់សាក្សីឱ្យចាកចេញពីបន្ទប់សវនាការ ហើយមិនត្រូវវិលមកកាន់បន្ទប់សវនាការវិញឡើយ រហូតទាល់តែដល់ពេលដែលគេហៅចូលមកធ្វើសក្ខីកម្ម ជាមធ្យោបាយមួយដើម្បីបញ្ជាក់ថាសាក្សីពុំបានរងឥទ្ធិពលពីភស្តុតាង ឬសក្ខីកម្មដទៃទៀតដែលត្រូវបានបង្ហាញក្នុងអំឡុងពេលសវនាការ។

៦.៦.៣.ចៅក្រមសាលាឧទ្ធរណ៍ចាំបាច់ត្រូវវាយតម្លៃដោយប្រុងប្រយ័ត្នថា តើភស្តុតាងដែលត្រូវបានបង្ហាញចំពោះមុខសវនាការអាចបង្កើតមូលដ្ឋានហួសពីវិមតិសង្ស័យដែលបញ្ជាក់ថា ជនជាប់ចោទមានពិរុទ្ធភាព។ ប្រសិនបើមានការបកស្រាយភស្តុតាងដែលស៊ីសង្វាក់ជាមួយនឹងភាពគ្មានពិរុទ្ធរបស់ជនជាប់ចោទ ដូច្នេះត្រូវឱ្យជនជាប់ចោទរួចផុតពីបទចោទ។

៦.៦.៤.រៀបចំឯកសារណែនាំច្បាស់លាស់ពាក់ព័ន្ធនឹងការបកស្រាយ និងការវាយតម្លៃភស្តុតាង ដោយផ្អែកលើការងាររបស់ អ.វ.ត.ក[152] និងចៅក្រមទាំងអស់ទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ។

## ៦.៧. អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ

៦.៧.១.ធានាថាសាលដីកាជាលាយលក្ខណ៍អក្សរត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដោយអាចកែសម្រួលនូវព័ត៌មានមួយចំនួននៅពេលចាំបាច់ដើម្បីការពារអត្តសញ្ញាណរបស់ជនជាប់ចោទ ជនរងគ្រោះ ឬសាក្សី ឬដោយសារតែមូលហេតុផ្សេងទៀត។

៦.៧.២.អនុវត្តតាមការប្រតិបត្តិរបស់ អ.វ.ត.ក[153] ដោយបង្កើតក្របខ័ណ្ឌដែលចៅក្រមមានកាតព្វកិច្ចប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីមូលហេតុដែលឈានដល់ការសម្រេចទោស និងត្រូវធានាថាសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដែលមានសំអាងហេតុត្រូវបានប្រគល់ជូនជនជាប់ចោទ។

---

[152] ការអនុវត្ត របស់ អ.វ.ត.ក អាចបញ្ជាក់អះអាងនូវការណែនាំមានប្រយោជន៍ ជាពិសេស វិធានផ្ទៃក្នុងរបស់ខ្លួន ក៏ដូចជាវាក្យសព្ទ ២០៤ ដល់ ២០៩ នៃសាលដីកាស្ថាពរបណ្តឹងសាទុក្ខនៃសំណុំរឿង ០០២/០១ សូមមើល "សាលដីកាស្ថាពរបណ្តឹងសាទុក្ខ" អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ សំណុំរឿងលេខ ០០២/១៩ ខែកញ្ញា ឆ្នាំ២០០៧/អវតក/អជតក https://www.eccc.gov.kh/sites/default/files/documents/courtdoc/2016-12-15%2011%3A24/161202%20Case%20002%2001%20Appeal%20Judgement_KH_web%20version.pdf។

[153] *សូមមើល ជាពិសេស* "សាលដីកាស្ថាពរបណ្តឹងសាទុក្ខ" អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ សំណុំរឿងលេខ ០០២/១៩ កញ្ញា ២០០៧/អវតក/អជតក

## ៦.៨. អនុសាសន៍ទាក់ទងនឹងការការពារសិទ្ធិរបស់អនីតិជន

៦.៨.១.ពន្លឿន និងពង្រឹងការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ជាពិសេស មាត្រា ៤៧ ដែលចែងថាដំណើរការជំនុំជម្រះ និងការចេញសាលក្រមត្រូវតែធ្វើឡើងនៅក្នុងសវនាការអសាធារណៈ។

៦.៨.២.គួរអនុវត្តតាមការប្រតិបត្តិល្អបំផុតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងអនុញ្ញាតឱ្យអនីតិជនស្លៀកសម្លៀកបំពាក់ស៊ីវិលរបស់ខ្លួនចូលមកក្នុងតុលាការនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធីព្រហ្មទណ្ឌ។

៦.៨.៣.កម្រិតការឃុំខ្លួននៅមុនពេលសវនាការលើអនីតិជន សម្រាប់តែករណីលើកលែងដែលពុំមានជម្រើសផ្សេងទៀត និងធានាថានៅក្នុងករណីបែបនេះ វិធានចាំបាច់ទាំងអស់ត្រូវបានអនុវត្តដើម្បីការពារសិទ្ធិរបស់អនីតិជន។

៦.៨.៤.ធានាថាចៅក្រម និងព្រះរាជអាជ្ញាបានឆ្លងកាត់ការបណ្តុះបណ្តាលជាក់លាក់អំពីបញ្ហាទាក់ទិននឹងយុត្តិធម៌របស់អនីតិជន។

៦.៨.៥.ពិនិត្យរកជម្រើសផ្សេងៗក្រៅពីការផ្តន្ទាទោសដាក់ពន្ធនាគារសម្រាប់អនីតិជន និងអនុវត្តគោលការណ៍ណែនាំក្នុងការកាត់ទោសទាក់ទងជាមួយអនីតិជន ដោយក្នុងនោះត្រូវផ្តោតការយកចិត្តទុកដាក់លើការស្តារនីតិសម្បទារបស់អនីតិជន ជាជាងការផ្តន្ទាទោសតែមួយមុខ។

៦.៨.៦.សាលាឧទ្ធរណ៍គួរប្រើប្រាស់ប្រព័ន្ធឆ្លើយឆ្លងតាមវីដេអូដែលបច្ចុប្បន្នមានរួចហើយនៅតុលាការ ហើយត្រូវធានាយ៉ាងណាឱ្យមន្ត្រីរបស់ខ្លួនបានទទួលការបណ្តុះបណ្តាលពីការប្រើប្រាស់ប្រព័ន្ធនេះ។ ក្រសួងយុត្តិធម៌ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តកម្មវិធីបង្វែរដោយក្នុងនោះជនល្មើសជាអនីតិជន បានទទួលការគាំទ្រ និងស្តារនីតិសម្បទានៅក្នុងសហគមន៍ ជាជម្រើសជំនួសឱ្យការកាត់ទោសជាផ្លូវការ។ ករណីនេះ ចាំបាច់ត្រូវអនុវត្តសម្រាប់ជនចាប់ចោទប្រព្រឹត្តបទល្មើសលើកដំបូងគ្រប់រូប លើកលែងតែបទល្មើសឧក្រិដ្ឋធ្ងន់ធ្ងរបំផុត។

៦.៨.៧.ក្រសួងយុត្តិធម៌ត្រូវពិនិត្យឡើងវិញលើបទដ្ឋានគតិយុត្តិជាធរមាន រួមទាំងច្បាប់ពាក់ព័ន្ធជាមួយការប្រព្រឹត្តទៅរបស់តុលាការ ដើម្បីធានាឱ្យអនុលោមតាមបទដ្ឋានអន្តរជាតិស្តីពីប្រព័ន្ធយុត្តិធម៌អនីតិជន ដោយក្នុងនោះ រួមមានទាំងវិធានបទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិសម្រាប់គ្រប់គ្រង

---

https://www.eccc.gov.kh/sites/default/files/documents/courtdoc/2016-11-23%2013%3A53/FOR%20INTERNET%20Case%20002_01%20Appeal%20JudgementKH.pdf។

វិស័យយុត្តិធម៌អនីតិជន («វិធានក្រុងប៉េកាំង»)[154] គោលការណ៍ណែនាំរបស់មូលនិធិសហប្រជាជាតិដើម្បីកុមារសម្រាប់កំណែទម្រង់ផ្នែកច្បាប់ស្តីពីយុត្តិធម៌អនីតិជន[155] សៀវភៅជំនួយស្មារតីការអនុវត្តរបស់មូលនិធិសហប្រជាជាតិដើម្បីកុមារសម្រាប់អនុសញ្ញាស្តីពីសិទ្ធិកុមារ[156] និងរបាយការណ៍កំណែទម្រង់ច្បាប់ និងការអនុវត្តច្បាប់របស់មូលនិធិសហប្រជាជាតិដើម្បីកុមារទាក់ទងនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ។[157]

[154] អាចស្វែងរកបានតាមរយៈ៖ http://cambodia.ohchr.org/~cambodiaohchr/sites/default/files/UN%20Beijing%20Rules-Kh.pdf ។

[155] អាចស្វែងរកបានតាមរយៈ៖ http://www.unicef.org/policyanalysis/files/Juvenile_justice_16052011_final.pdf។

[156] ជាពិសេសនៅទំព័រ ១០៧ អាចស្វែងរកបានតាមរយៈ៖ http://www.unicef.org/publications/index_43110.html។

[157] ជាពិសេសនៅទំព័រ ៨៧ អាចស្វែងរកបានតាមរយៈ៖ https://www.unicef-irc.org/publications/pdf/law_reform_crc_imp.pdf។

## ៧. ឯកសារគន្លងនិទ្ទេស

### ៧.១. នីតិជាតិ

ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (២០០៧)
http://sithi.org/temp.php?url=law_detail.php&id=190&lg=kh។
រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣ ដូចដែលបានធ្វើវិសោធនកម្ម) http://www.national-assembly.org.kh/group-article/11។
ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (២០០៩)
http://sithi.org/temp.php?url=law_detail.php&id=154&lg=kh។
ច្បាប់ស្តីពីយុត្តិធម៌អនីតិជន (២០១៦) http://sithi.org/temp.php?title=Law-On-Juvenile-Justice&url=law_detail.php&lg=kh&id=283។
ច្បាប់ស្តីពីពន្ធនាគារនៃព្រះរាជាណាចក្រកម្ពុជា (២០១១)។
http://cambodia.ohchr.org/~cambodiaohchr/sites/default/files/Prison%20law%202011%20-%20KHM.pdf។
ប្រកាសលេខ ២១៧ ស្តីពីការគ្រប់គ្រងពន្ធនាគារ (ថ្ងៃទី ១៣ ខែមីនា ឆ្នាំ ១៩៩៨)
http://sithi.org/admin/upload/law/section12_003_1998.pdf។
បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល (១៩៩២)
https://www.wto.org/english/thewto_e/acc_e/khm_e/WTACCKHM3A3_LEG_11.pdf។

### ៧.២. លិខិតូបករណ៍គោលនយោបាយកម្ពុជា

ក្រុមប្រឹក្សាភិបាលស្តារនីតិសម្បទា និងអភិវឌ្ឍកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា *ឯកសារបញ្ជាក់គោលជំហរលទ្ធផលការងារគោលនយោបាយរបស់រដ្ឋាភិបាលៈ*
http://www.cdc-crdb.gov.kh/cdc/7cg_meeting/position_paper_eng2004/7cg_02_1.htm។
ក្រុមប្រឹក្សាកំណែទម្រង់ផ្នែកច្បាប់ និងយុត្តិធម៌ *យុទ្ធសាស្ត្រកំណែទម្រង់ផ្នែកច្បាប់ និងយុត្តិធម៌* អនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងកិច្ចប្រជុំពេញអង្គកាលពីថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០០៣ http://cdc-crdb.gov.kh/cdc/documents/NSDP_2014-2018.pdf។
ក្រុមប្រឹក្សាកំណែទម្រង់ផ្នែកច្បាប់ និងយុត្តិធម៌ *ផែនការសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ផ្នែកច្បាប់ និងយុត្តិធម៌* អនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងកិច្ចប្រជុំពេញអង្គកាលពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៥ http://cdc-crdb.gov.kh/cdc/documents/NSDP_2014-2018.pdf។

នាយករដ្ឋមន្ត្រី ហ៊ុន សែន *សុន្ទរកថាអំពីយុទ្ធសាស្ត្រចតុកោណសម្រាប់ការអភិវឌ្ឍ ការងារ សមធម៌ និងប្រសិទ្ធភាព ដំណាក់កាលទី ២* កិច្ចប្រជុំគណៈរដ្ឋមន្ត្រីលើកទី ១ នៃអណត្តិទី ៤ នៃរដ្ឋសភា ទីស្តីការគណៈរដ្ឋមន្ត្រី រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨។

## ៧.៣. នីតិអន្តរជាតិ

**សន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ**

អង្គមហាសន្និបាទអង្គការសហប្រជាជាតិ *អនុសញ្ញាស្តីពីសិទ្ធិកុមារ* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ https://www2.ohchr.org/english/bodies/crc/docs/CRC.C.GC.10.pdf។

អង្គមហាសន្និបាទអង្គការសហប្រជាជាតិ *អនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាប*, ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៨៤ https://cambodia.ohchr.org/sites/default/files/book/CAT-KH.pdf។

អង្គមហាសន្និបាទអង្គការសហប្រជាជាតិ *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ១៩៦៦ http://cambodia.ohchr.org/sites/default/files/Treaty/ICCPR_2009K.pdf។

អង្គមហាសន្និបាទអង្គការសហប្រជាជាតិ *សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស* ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៤៨ http://cambodia.ohchr.org/sites/default/files/Softlaw/BOOKLET_Kh%20V6Low.pdf។

**ឧបករណ៍ច្បាប់អន្តរជាតិដទៃទៀត**

អង្គការសហប្រជាជាតិ *គោលការណ៍មូលដ្ឋានស្តីពីឯករាជ្យភាពនៃប្រព័ន្ធតុលាការ* អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី ៧ ស្តីពីការបង្ការបទល្មើស និងប្រព្រឹត្តទៅលើជនល្មើស រៀបចំឡើងនៅទីក្រុងមីឡាន ពីថ្ងៃទី ២៦ ខែសីហា ដល់ថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ១៩៨៥ គាំទ្រដោយសេចក្តីសម្រេចនៃអង្គមហាសន្និបាតលេខ ៤០/៣២ ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ១៩៨៥ និង លេខ ៤០/១៤៦ ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ១៩៨៥ https៖//www.ohchr.org/EN/ProfessionalInterest/Pages/IndependenceJudiciary.aspx។

អង្គការសហប្រជាជាតិ *គោលការណ៍មូលដ្ឋានស្តីពីមេធាវី* អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី ៨ ស្តីពីការបង្ការបទល្មើស និងការប្រព្រឹត្តទៅលើជនល្មើសរៀបចំឡើង នៅទីក្រុង ហាវ៉ាណា ប្រទេសគុយបា នៅថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ១៩៩០ http://hrlibrary.umn.edu/instree/i3bprl.htm។

អង្គមហាសន្និបាទអង្គការសហប្រជាជាតិស្តីពី *វិធានបទដ្ឋានអប្បបរមាអនុវត្តចំពោះការប្រព្រឹត្តទៅលើទណ្ឌិត* ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ១៩៥៥។ https៖//www.ohchr.org/EN/ProfessionalInterest/Pages/TreatmentOfPrisoners.aspx។

អង្គមហាសន្និបាទអង្គការសហប្រជាជាតិ *សេចក្តីណែនាំរបស់អង្គការសហប្រជាជាតិស្តីពីការបង្ការអនីតិជនប្រព្រឹត្តបទល្មើស (សេចក្តីណែនាំរីយ៉ាត)* អនុម័តដោយសេចក្តីសម្រេចនៃអង្គមហាសន្និបាទលេខ ៤៥/១១២ ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ១៩៩០ http://www.un.org/documents/ga/res/45/a45r112.htm។

អង្គមហាសន្និបាទអង្គការសហប្រជាជាតិ *វិធានអង្គការសហប្រជាជាតិស្តីពីការការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព* ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ១៩៩០ https៖//www.ohchr.org/EN/ProfessionalInterest/Pages/JuvenilesDeprivedOfLiberty.aspx។

អង្គមហាសន្និបាទអង្គការសហប្រជាជាតិ *វិធានបទដ្ឋានអប្បបរមានៃបទដ្ឋានអង្គការសហប្រជាជាតិសម្រាប់គ្រប់គ្រងយុត្តិធម៌អនីតិជន* ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ១៩៨៥ https៖//www.ohchr.org/EN/ProfessionalInterest/Pages/BeijingRules.aspx។

គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ *សេចក្តីពន្យល់ទូទៅលេខ ១៣ រដ្ឋបាលយុត្តិធម៌* ចុះថ្ងៃទី ១៣ ខែមេសា ឆ្នាំ ១៩៨៤

https://tbinternet.ohchr.org/_layouts/treatybodyexternal/TBSearch.aspx?Lang=en&TreatyID=8&DocTypeID=11។

គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ *សេចក្តីពន្យល់ទូទៅលេខ ២៩ ស្តីពីស្ថានភាពក្នុងគ្រាអាសន្ន* ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០១ http://docstore.ohchr.org/SelfServices/FilesHandler.ashx?enc=6QkG1d/PPRiCAqhKb7yhsjYoiCfMKoIRv2FVaVzRkMjTnjRO%2Bfud3cPVrcM9YR0iix49nlFOsUPO4oTG7R/o7TSsorhtwUUG%2By2PtslYr5BldM8DN9shT8B8NpbsC%2B7bODxKR6zdESeXKjiLnNU%2BgQ%3D%3D។

គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ *សេចក្តីពន្យល់ទូទៅលេខ ៣២ ស្តីពីសិទ្ធិស្មើភាពគ្នាចំពោះមុខតុលាការ និងអង្គជំនុំជម្រះ និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌* ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០០៧ http://docstore.ohchr.org/SelfServices/FilesHandler.ashx?enc=6QkG1d/PPRiCAqhKb7yhsrdB0H1l5979OVGGB%2BWPAXhRj0XNTTvKgFHbxAcZSvX1OsJj/iyRmVA4IiMvUt2NlGKqqg2nh1qOE2hX5xoGtKE2v2YSQVV1Rv5NitNbSYwp។

គណៈកម្មាធិការស្តីពីសិទ្ធិកុមារ, *សេចក្តីពន្យល់ទូទៅលេខ ១០៖ សិទ្ធិកុមារនៅក្នុងយុត្តិធម៌អនីតិជន* ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០០៧ (CRC/C/GC/10) https://www2.ohchr.org/english/bodies/crc/docs/CRC.C.GC.10.pdf។

##ករណីសិក្សាច្បាប់

### ជាតិ

ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០០៧ https://www.ccc.gov.kh/admin/uploads/dec_2007_003.pdf។

### អន្តរជាតិ

តុលាការសិទ្ធិមនុស្សអឺរ៉ុប *សំណុំរឿង Asch ទល់នឹងប្រទេសអូទ្រីស* ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ១៩៩១ https://hudoc.echr.coe.int/eng#%7B%22fulltext%22:[%22Asch%20v.%20Austria%201991%22],%22documentcollectionid2%22:[%22GRANDCHAMBER%22,%22CHAMBER%22],%22itemid%22:[%22001-57676%22]%7D។

តុលាការសិទ្ធិមនុស្សអឺរ៉ុប *សំណុំរឿង Barberá, Messeguè and Jabardo ទល់នឹងប្រទេសអេស្ប៉ាញ* ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៩៨ https://hudoc.echr.coe.int/eng#%7B%22itemid%22:[%22001-57429%22]%7D។

